អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះសាលាដំបូង
Trial Chamber
Chambre de Premiere instance

ឯកសារដើម
ORIGINAL/ORIGINAL
ថ្ងៃ ខែ ឆ្នាំ (Date): 25-May-2017, 10:16
CMS/CFO: Sann Rada

# កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃកិច្ចដំណើរការនីតិវិធី

## ជំនុំជម្រះក្ដីនៅដំណាក់កាលពីរ

## សាធារណៈ

សំណុំរឿងលេខ ០០២/១៩-០៩-២០០៧/អវតក/អជសដ

**ថ្ងៃទី២៧ ខែឧសភា ឆ្នាំ២០១៥**

**ម៉ោង ០៩:០១នាទី**

**សវនាការលើកទី២៨៧**

**ចៅក្រមសាលាដំបូង៖**

ចៅក្រម និល ណុន ជាប្រធាន

ចៅក្រម ក្លូឌា ហ្វេនស៍
*(Judge Claudia FENZ)*

ចៅក្រម យ៉ា សុខន

ចៅក្រម ហ្សង់ម៉ាក ឡាវែន៍
*(Judge Jean-Marc LAVERGNE)*

ចៅក្រម យូរ ឧត្តរា

ចៅក្រម ធូ មណី (បម្រុង)

**ក្រឡាបញ្ជីសាលាដំបូង៖**

លោកស្រី សែ កុលវុឌ្ឍី

លោក ម៉ាធូវ ម៉ាកាធី *(Mr.Matthew Mccarthy)*

**ការិយាល័យសហព្រះរាជអាជ្ញា៖**

លោក នីកូឡាស គូមជែន
*(Mr.Nicolas Koumjian)*

លោក ឌេល លីសាក់ *(Mr.Dale LYSAK)*

លោក សេង ប៊ុនឃាង

កញ្ញា សុង ឆវ័ន្ត

**ជនជាប់ចោទ៖**

លោក នួន ជា

លោក ខៀវ សំផន

**មេធាវីការពារជនជាប់ចោទ នួន ជា៖**

លោក សុន អរុណ

លោក លីវ សុវណ្ណា

លោក វ៉ិចទ័រ កូប៉េ *(Mr.Victor KOPPE)*

**មេធាវីការពារជនជាប់ចោទ ខៀវ សំផន៖**

លោក គង់ សំអុន

លោកស្រី អង់តា ហ្គីសសេ*(Ms.Anta GUISSE)*

**មេធាវីប្រចាំការលោក ខៀវ សំផន៖**

លោកស្រី ទូច វរល័ក្ស

លោក ខលវីន សោនដឺស៍

*(Mr. Calvin SAUNDERS)*

**មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី៖**

លោកស្រី ម៉ារី ហ្គីរ៉ូដ៍*(Ms.Marie GUIRAUD)*

លោកស្រី ម៉ុច សុវណ្ណារី

លោក វ៉េន ពៅ

**ផ្នែកគ្រប់គ្រងតុលាការ៖**

លោក អ៊ុច អរុណ

លោកស្រី ស្ល សុទ្ធាវី

**បញ្ជីឈ្មោះអ្នកនិយាយ៖**

ភាសាដែលបានប្រើ លើកលែងតែមានការបញ្ជាក់ផ្សេងទៀតនៅក្នុងប្រតិចារឹក

| អ្នកនិយាយ | ភាសា |
|---|---|
| ចៅក្រម និល ណុន (ប្រធានអង្គជំនុំ) | ខ្មែរ |
| លោកស្រី ក្លូឌា ហ្វេសន៍ | អង់គ្លេស |
| លោក ឌេល លីសាក់ | អង់គ្លេស |
| កញ្ញា សុង ឆវ័ន្ត | ខ្មែរ |
| លោក វ៉ិចទ័រ កូប៉េ | អង់គ្លេស |
| លោកស្រី អង់តា ហ្គីសសេ | បារាំង |
| លោកស្រី ម៉ារី ហ្គីរ៉ូដ៍ | បារាំង |
| លោកស្រី ម៉ុច សុវណ្ណារី | ខ្មែរ |
| លោកស្រី ហ៊ុន សុត្ថានី (2-TCCP-255) | ខ្មែរ |
| លោកស្រី អ៊ុន រ៉ន (2-TCCP-230) | ខ្មែរ |

# ឧបសម្ព័ន្ធ

**ការសួរសំណួរនៅដើមបណ្តឹងរដ្ឋប្បវេណី៖ លោកស្រី ហ៊ុន សិត្ថានី** (2-TCCP-255)


សួរបន្តដោយលោកស្រី ម៉ុច សុវណ្ណារី ផ្តើមពី ........................................ទំព័រ ២
សួរដោយលោកស្រី ម៉ារី ហ្គីរ៉ូដ៍ ផ្តើមពី ........................................ទំព័រ ១៦
សួរដោយកញ្ញា សុង ឆវ័ន្ត ផ្តើមពី ........................................ទំព័រ ១៧
សួរដោយលោក ឌេល លីសាក់ ផ្តើមពី ........................................ទំព័រ ២០
សួរដោយលោក វ៉ិចទ័រ កូប៉េ ផ្តើមពី........................................ទំព័រ ២៩
សួរដោយលោកស្រី អង់តា ហ្គិសសេ ផ្តើមពី ........................................ទំព័រ ៥៤


**ការសួរសំណួរនៅដើមបណ្តឹងរដ្ឋប្បវេណី៖ លោកស្រី អ៊ុន វ៉ន** (2-TCCP-255)


សួរដោយប្រធានអង្គជំនុំ ផ្តើមពី ........................................ទំព័រ ៦២
សួរដោយលោកស្រី ម៉ុច សុវណ្ណារី ផ្តើមពី ........................................ទំព័រ ៦៤

# កិច្ចដំណើរការនីតិវិធី

*(ចៅក្រមចូលក្នុងបន្ទប់សវនាការ)*

[០៩:០១:៤១]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ។ សវនាការនៅថ្ងៃនេះ អង្គជំនុំជម្រះបន្តធ្វើសវនាការស្ដាប់សក្ខីកម្មដើមបណ្ដឹងរដ្ឋប្បវេណី ហ៊ុន សិត្ថានី ហើយនិងអាចចាប់ផ្ដើមស្ដាប់សក្ខីកម្មដើមបណ្ដឹងរដ្ឋប្បវេណីដែលមានរហស្សនាម 2-TCCP-230។

ក្រឡាបញ្ជីសវនាការ លោកស្រី សែ កុលវុឌ្ឍី ឡើងរាយការណ៍អំពីស្ថានភាពវត្តមាន អវត្តមានភាគី និងបុគ្គលដែលអង្គជំនុំជម្រះកោះអញ្ជើញឲ្យចូលរួមនៅក្នុងកិច្ចដំណើរការសវនាការថ្ងៃនេះ។

**ក្រឡាបញ្ជី៖**

សូមគោរពលោកប្រធាន សម្រាប់សវនាការនៅថ្ងៃនេះ ក្រឡាបញ្ជីកត់សម្គាល់ឃើញថា គ្រប់ភាគីទាំងអស់នៃរឿងក្ដីនេះ មានវត្តមាន។ ដោយឡែក លោក នួន ជា មានវត្តមាននៅបន្ទប់ឃុំខ្លួនខាងក្រោមសាលសវនាការនេះ។ ដោយលោកស្នើសុំលះបង់សិទ្ធិមានវត្តមានផ្ទាល់ពីបន្ទប់សវនាការ។ លិខិតលះបង់សិទ្ធិរបស់លោក នួន ជា បានប្រគល់ដល់ក្រឡាបញ្ជីរួចហើយ ហើយដើមបណ្ដឹងរដ្ឋប្បវេណីដែលត្រូវមកផ្ដល់សក្ខីកម្មបន្តបញ្ចប់នៅថ្ងៃនេះ គឺលោកស្រី ហ៊ុន សិត្ថានី។ លោកស្រីមានវត្តមានរួចហើយនៅក្នុងបន្ទប់សវនាការ។ ហើយនៅថ្ងៃនេះដែរ យើងមានដើមបណ្ដឹងរដ្ឋប្បវេណីបម្រុងមួយរូបដែលមានរហស្សនាម 2-TCCP-230។ សូមអរគុណលោកប្រធាន។

**ប្រធានអង្គជំនុំ៖**

ឥឡូវនេះ អង្គជំនុំជម្រះសម្រេចលើសំណើសុំរបស់ជនជាប់ចោទ នួន ជា ជាមុនសិន។ អង្គជំនុំជម្រះបានទទួលលិខិតសុំលះបង់សិទ្ធិចូលរួមសវនាការដោយផ្ទាល់ ក្នុងបន្ទប់សវនាការនេះរបស់ជនជាប់ចោទ នួន ជា ចុះថ្ងៃទី២៧ ខែឧសភា ឆ្នាំ២០១៥ ដែលបានបញ្ជាក់ថា ដោយគាត់មានបញ្ហាសុខភាពឈឺចង្កេះ ឈឺក្បាល មិនអាចអង្គុយយូរបាន មិនអាចផ្ចង់អារម្មណ៍បានយូរ និងដើម្បីមានលទ្ធភាពចូលរួមសវនាការនៅថ្ងៃមុខឲ្យមានប្រសិទ្ធភាព ខ្លួនសូមលះបង់សិទ្ធិចូលរួមនិងមានវត្តមានដោយផ្ទាល់ក្នុងបន្ទប់សវនាការ នៅថ្ងៃទី២៧ ខែឧសភា ឆ្នាំ២០១៥។

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

[០៩:០៣:៥៤]

មេធាវីការពារក្ដីរបស់ខ្លួនបានប្រាប់អំពីផលប៉ះពាល់នៃសិទ្ធិនេះ ថាការប៉ះពាល់នៃសិទ្ធិនេះ -- ការលះបង់សិទ្ធិនេះមិនអាចបកស្រាយថា ជាការលះបង់សិទ្ធិរបស់ខ្លួនក្នុងការកាត់សេចក្ដីដោយយុត្តិធម៌ ឬក៏សិទ្ធិក្នុងការជំទាស់នឹងភស្តុតាងក្នុងការដាក់បង្ហាញ ឬដាក់ជូនតុលាការនេះ គ្រប់ពេលវេលានៃសវ-នាការលើរូបខ្លួនឡើយ។

បានឃើញកំណត់ហេតុពិនិត្យសុខភាពជនជាប់ចោទ នួន ជា ដែលធ្វើឡើងដោយគ្រូពេទ្យប្រចាំការពិនិត្យ ព្យាបាល ថែទាំសុខភាពជនជាប់ចោទនៅ អ.វ.ត.ក ចុះថ្ងៃទី២៧ ខែឧសភា ឆ្នាំ២០១៥ បានកត់សម្គាល់ថា ស្ថានភាពសុខភាពរបស់ នួន ជា មានអាការៈធឹងធោង និងឈឺចង្កេះជាប្រចាំ មិនអាចអង្គុយយូរបាន និងផ្ដល់អនុសាសន៍ថា សូមអង្គជំនុំជម្រះអនុញ្ញាតឱ្យលោក នួន ជា ចូលរួមតាមដានកិច្ចដំណើរការសវនាការពីបន្ទប់ខាងក្រោមសាលសវនាការនេះ។ ផ្អែកលើមូលដ្ឋាននេះ និងយោងលើបទប្បញ្ញត្តិនៃវិធាន៨១(៥) នៃវិធានផ្ទៃក្នុង អ.វ.ត.ក អង្គជំនុំជម្រះយល់ និងអនុញ្ញាតឱ្យជនជាប់ចោទ នួន ជា បន្តចូលរួមនិងតាមដានកិច្ចដំណើរការសវនាការពីចម្ងាយពីបន្ទប់ឃុំខ្លួនមួយស្ថិតក្រោមសាលសវនាការនេះ តាមរយៈឧបករណ៍សោតទស្សន៍សម្រាប់រយៈពេលសវនាការពេញមួយថ្ងៃនេះ។

បង្គាប់ឱ្យបុគ្គលិកផ្នែកសោតទស្សន៍ភ្ជាប់ប្រព័ន្ធសោតទស្សន៍សម្រាប់ជនជាប់ចោទ នួន ជា អាចចូលរួមនិងតាមដានកិច្ចដំណើរការសវនាការពីចម្ងាយ ពីបន្ទប់ខ្លួនមួយស្ថិតនៅក្រោមសាលសវនាការនេះក្នុងអំឡុងពេលនៃកិច្ចដំណើរការសវនាការសម្រាប់ថ្ងៃនេះ។

ហើយជាបន្តទៅនេះ អង្គជំនុំជម្រះផ្ដល់វេទិកាជូនទៅក្រុមសហមេធាវីនាំមុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណី ដើម្បីមានឱកាសបន្តការតាំងសំណួរដេញដោលចំពោះដើមបណ្ដឹងរដ្ឋប្បវេណី។

[០៩:០៥:៣២]

**លោកស្រី ម៉ុច សុវណ្ណារី៖**

ចាស សូមអរគុណ លោកប្រធាន។ ជាដំបូង នាងខ្ញុំសូមគោរព លោកប្រធាន លោក លោកស្រី ចៅក្រមអង្គសវនាការទាំងមូល។

**ការតាំងសំណួរដោយសហមេធាវីដើមបណ្ដឹងរដ្ឋប្បវេណី**

**សួរបន្តដោយលោកស្រី ម៉ុច សុវណ្ណារី៖**

**ស៖** ហើយសូមជម្រាបសួរ អ្នកស្រីដើមបណ្ដឹងរដ្ឋប្បវេណីជាថ្មីម្ដងទៀត។ មុននឹងខ្ញុំបន្តសំណួរ

សួរអ្នកស្រី ទាក់ទងជាមួយនឹងលក្ខណ្ឌការងារដែលអ្នកស្រីទទួលរងនៅការដ្ឋានទំនប់១មករា ខ្ញុំចង់សួរសំណួរពីរបីសំណួរទៀត ទាក់ទងជាមួយនឹងក្រុមកុមារដែលអ្នកស្រីហៅថា ជាក្រុមចល័តទី២។ កាលពីម្សិលមិញ អ្នកស្រីបានប្រាប់ថា មានកុមារដែលត្រូវបានគេបង្ខំឱ្យទៅធ្វើការនៅទីនោះដែរ។ អ៊ីចឹង ខ្ញុំចង់សួរអ្នកស្រីថា តើកុមារទាំងអស់នោះ គេឱ្យពួកគាត់ធ្វើអ្វីដែរ?

**លោកស្រី ហ៊ុន សិត្ថានី៖**

**ឆ៖** កុមារទាំងអស់នោះ គឺគេឱ្យធ្វើការដូចមនុស្សចាស់ ញ៉ាំអីក៏ដូចមនុស្សចាស់។ គេមិនបានគិតគូរពីសិទ្ធិរបស់កុមារអីទេ។ គេមិនខ្វាយខ្វល់ទេ គេដឹងតែប្រើ មានរបបដូចមនុស្សចាស់អ៊ីចឹង។ គេមិនគិតថា ក្មេង អាយុតិច កម្លាំងតិចអី គេមិនគិតទេ រែកដីវាដាក់ប៉ុនណារួច ទៅប៉ុណ្ណឹង។ គេគ្មានការយោគយល់ គេគ្មានការអាណិតអីទេ។

**ស៖** ចាស សូមអរគុណអ្នកស្រី។ តើអ្នកស្រីអាចបញ្ជាក់បានទេថា អ្នកស្រីបានធ្លាប់បានឃើញ ឬក៏បានឮ ឬក៏បានដឹងថា ដោយសារស្ថានភាពការងារធ្ងន់ធ្ងរពេក ធ្វើឱ្យកុមារទាំងអស់នោះអាចនឹងធ្លាក់ខ្លួនឈឺ ឬក៏មានរបួសដោយសារការរែកដី ឬក៏ការកាប់ដីដែរឬទេ?

[០៩:០៧:២៣]

**ឆ៖** តាមធម្មតា ក្មេងធ្វើការដូចមនុស្សចាស់ គឺគ្មានសុខភាពវាមិនល្អទេ ចេះតែប្រឹងទៅនឹងគេទៅនឹងឯង។ ឈឺក៏គ្មានអ្នកណាមកសួរមកនាំអីដែរ ដឹងតែធ្វើម៉េច ឱ្យចេញឱ្យអស់ពីរោង។ ការងារពេលណាក៏ដោយ ដឹងតែសម្រុកទាំងចាស់ទាំងក្មេង។ មីក្រូចាក់ក្ដែងៗ គឺសម្រុកៗការងារ ដឹងតែសម្រុករហូត។

**ស៖** ចាស សូមអរគុណអ្នកស្រី។ អ៊ីចឹង បើសិនជាខ្ញុំយល់មិនខុសទេ គឺអ្នកស្រីបានឃើញថាមានកុមារឈឺ ដោយសារការងារទាំងអស់នោះ។ តើមាន -- គេមានបានចាត់វិធានការណាមួយ ដូចជាឱ្យពេទ្យទៅមើល ឬក៏បញ្ជូនកុមារហ្នឹងទៅព្យាបាល ឬក៏យកចិត្តទុកដាក់អ្វីពិសេសចំពោះកុមារនោះដែរឬទេ?

**ឆ៖** រឿងថាពិសេស គឺគ្មានទេ គឺមានតែពេទ្យចាក់ថ្នាំដបទឹកក្រូចពីដើមហ្នឹង ថ្នាំក្រហមៗហ្នឹង ឈឺអីក៏ចាក់ថ្នាំហ្នឹងៗ ឱ្យតែឈ្មោះថាចាក់ទៅ ឱ្យគេចាក់ទៅ ឱ្យតែបាននៅនឹងរោង។

**ស៖** សូមអរគុណអ្នកស្រី។ ខ្ញុំត្រឡប់មកសួរសំណួរទាក់ទងជាមួយនឹងលក្ខខណ្ឌការងាររបស់អ្នកស្រីនៅការដ្ឋាននោះវិញ។ អ្នកស្រីបានបញ្ជាក់ម្សិលមិញថា អ្នកស្រីបានទៅធ្វើការនៅទីនោះ នៅបី

កន្លែងខុសៗគ្នា។ ទី១ អ្នកស្រីបានទៅធ្វើការនៅក្បែរវត្តត្រពាំងជ្រៃ, មួយទៀត គឺនៅក្បែរថ្នល់ជាតិ ហើយមួយទៀតគឺទៅទប់ទឹកស្ទឹង។ អ៊ីចឹងខ្ញុំចង់សួរអ្នកស្រីថា តើអ្នកស្រីអាចរៀបរាប់ជូនតុលាការបាន ទេថា នៅពេលដែលអ្នកស្រីទៅធ្វើការងារនៅបីកន្លែងហ្នឹង ថាតើគេតម្រូវឱ្យអ្នកស្រីធ្វើអ្វីខ្លះ? អាចរៀប រាប់បានទេ?

**ឆ៖** នៅកន្លែងការងារហ្នឹងគឺ រែកដី កាប់ដី ប្តូរគ្នាទៅ កាយដាក់បង្គីខ្លះទៅ ធ្វើម៉េចៗថាកុំឱ្យ យើងទំនេរនោះណា។ ធ្វើនឹងប្រណាំងប្រជែងគ្នាតាមភូមិ ប្រឹងអស់ពីសមត្ថភាព ប្រឹងហួសកម្លាំងយ៉ាង ម៉េចក៏ដោយ ឈឺក្បាលវិលមុខបន្តិចបន្តួច ហៅគ្នាឯងហ្នឹងជួយដកសក់ទៅ លុញខ្លួនទៅ ធ្វើម៉េចឱ្យតែ បានងើបទៅធ្វើការកើតទៀត កុំឱ្យតែយើងឈប់។ វាហួសសត្វហួសធាតុហើយកាលនោះ អ្នកដែលទ្រាំ រស់បាននោះគឺវាអស្ចារ្យណាស់ជីវិត ញ៉ាំមិនគ្រប់មិនគ្រាន់ក៏ដោយ ត្រូវតែប្រឹងដើម្បីរស់ ទៅធ្វើការទៅ។ បើមិនស៊ូទេ យើងគ្មានថ្ងៃរស់ទេ ទាំងចាស់ទាំងក្មេងទៅដល់កន្លែងនោះហើយ សុទ្ធតែគេពិសោធការងារ ហើយ យើងទ្រាំបានឬមិនបាន យើងត្រូវតែប្រឹង។ រែកដីតិចខ្លាចចាញ់គេ អ៊ីចឹងខំដាក់ពេញៗបង្គី ខ្លាច ចាញ់ភូមិគេ ខ្លាចអង្គការមើលមិនឃើញ។ ឈឺចុកចង្កេះ ចុកខ្នង ខ្ញុំចុកតាំងពីក្មេង តាំងពីជំនាន់រែកដី រហូតដល់សព្វថ្ងៃហ្នឹង ប្រឹងដើម្បីអី ប្រឹងដើម្បីរស់ ខំដើម្បីរស់។

[០៩:១២:៣៤]

**ស៖** សូមអរគុណអ្នកស្រី។ ខ្ញុំមានសំណួរបន្ទាប់មកទៀតទាក់ទងជាមួយនឹងអ្នកស្រីថា ខំប្រឹង ធ្វើការងារ ប្រឹងបានប៉ុនណា គឺប្រឹងបានប៉ុណ្ណឹង។ អ៊ីចឹងខ្ញុំចង់សួរអ្នកស្រីថា តើគេបានកំណត់ម៉ោងធ្វើ ការងារដល់កម្មករដែលធ្វើការនៅការដ្ឋាននោះថា កម្មករគេបានតម្រូវឱ្យត្រូវធ្វើការពីថ្មើរម៉ោន ទៅថ្មើរ ម៉ោន ហើយតើមានពេលសម្រាកគ្រប់គ្រាន់ដែរឬទេ?

**ឆ៖** កាលពីនៅរែកដីជិត នៅត្រពាំងជ្រៃហ្នឹង យើងអាចល្ងុះៗហ្នឹងគេទៅធ្វើការហើយ កញ្ចែ គេផ្លុំពីម៉ោងបួន ឱ្យយើងរៀបចំខ្លួន ធ្វើការពីម៉ោងប្រាំព្រឹក រហូតដល់ម៉ោង ដប់មួយហូបបាយ។ ម៉ោង មួយចុះទៀត ម៉ោងប្រាំសម្រាក ម៉ោងប្រាំមួយល្ងាចចុះទៀតរហូតដល់ម៉ោងដប់យប់។ វេទនា ដល់ពេល ទៅធ្វើនៅជិតថ្នល់ជាតិនោះ ពីត្រពាំងជ្រៃចេញទៅដល់ថ្នល់ជាតិហ្នឹងឆ្ងាយ។ កញ្ចែគេហៅតាំងពីម៉ោងបី បីកន្លះយ៉ាងយូរ។ ម្នាក់ៗល្វើយគ្មានអ្នកណាចង់ងើបទេ ងើបឡើងសុទ្ធតែធ្មេច ហើយតាមផ្លូវធ្មេចតោង គ្នា ជួនដួលពភីសពភ្លូសទៅ។ មេកងគេស្តីឱ្យ “ម៉េចបានដើរដួល”។ មេកងហ្នឹងមិនដឹងមូលហេតុទេ ព្រោះថ្ងៃគេៗលួចទៅគេងនៅឯណាក៏យើងមិនដឹងដែរ។ ដែលយើងនេះកំណត់ពេលវេលា គឺគេកំណត់

ឲ្យច្បាស់លាស់ គេជាប្រធានកង ប្រធានក្រុមគេមានសិទ្ធិធំណាស់ គេទៅសម្ងំលួចគេងនៅឯណាក៏យើងមិនដឹង បាត់ៗហើយយើងទៅរកគេឯណា មានតែគេទេរកយើងឃើញ យើងរកគេមិនឃើញទេ។ ម៉ោងបួនងើបដើរទៅ។ ដឹងស្រាប់ហើយពេលគេងម៉ោងបួនហ្នឹង ពេលគេងស្រួលណាស់ជិតភ្លឺហ្នឹងនោះ ចុះបើការងារដល់ហើយ កញ្ចែច្រេចៗហើយបើមិនងើបម៉េចនឹងកើត។

[០៩:១៥:០៥]

ខោអាវ គឺស៊ិកតាំងពីលួចចាំរួចស្រេចហើយ បើងើបឡើងរកស្លៀកពាក់ទៀតនោះ ធ្វើអីក៏មិនកើតដែរ។ ថ្ងៃណាអស់កម្លាំងខ្លាំង គេងទាំងខោអាវដី គ្មានបានងូតទេ។ ងើបឡើងទៅទៀតក៏មាន ទៅធ្វើការនោះគឺសម្រុកការងារ គឺមីក្រូគេចាក់រាល់ថ្ងៃ ឮតែសម្រែកស្រែកថា "បងប្អូនសម្រុកការងារ" ឮតែសម្រុករហូត។ ជីកក្បែរថ្នល់ហ្នឹង សម្រុករហូតការដ្ឋានចប់ហ្នឹង គឺរែកទាល់តែយប់រហូត។ អ្នកខ្វាក់មាន់ អ្នករែកដីយប់មិនកើត ពេលញ៉ាំបាយហើយហ្នឹង គេឲ្យរែកដីភ្លាម។ បង្ខំតែម្ដង គេថាញ៉ាំបាយឲ្យលឿន គេឲ្យហូបបាយហ្នឹងឲ្យលឿននឹងន្ទាលនឹងរែកដីទៀត។ គ្នាចាប់ផ្ដើមរែកទៀតហើយ។ ហូបបាយថាកន្លះម៉ោងចុះ គ្នារែកទាំងកណ្ដាលថ្ងៃហ្នឹង គិតទៅម៉ោងដប់ពីររហូតទៅ យើងអ្នកអត់ខ្វាក់មាន់ យើងសម្រាកអាចម៉ោងមួយ យើងអាចចុះបាន តែគ្នាដែលខ្វាក់មាន់នោះ ឲ្យគ្នារែកទាំងកណ្ដាលថ្ងៃត្រង់។ យប់គេឲ្យអ្នកខ្វាក់មាន់ហ្នឹងអង្គុយកាយដាក់បង្គីឲ្យគេ ធ្វើបាបឲ្យគ្នារែកថ្ងៃហើយ ឲ្យគ្នាទៅកាយដីដាក់បង្គីយប់ទៀត។ មើលទៅការអាណិតជំនាន់នោះគឺគ្មានទេ។ ហេតុអីបានធ្វើអ៊ីចឹង? ម៉េចគេធ្វើបាបមនុស្សខ្លាំងមនុស្ស។

[០៩:១៧:១៨]

**ស៖** ចាស សូមអរគុណអ្នកស្រី។ ខ្ញុំមានសំណួរមួយទៀតទាក់ទងនឹងរបបអាហារហូបចុកនៅពេលដែលអ្នកស្រីធ្វើការនៅកន្លែងនោះ។ តើរបបអាហារគេផ្គត់ផ្គង់របៀបម៉េចដែរ? ហើយតើគ្រប់គ្រាន់ដែរឬទេ?

**ឆ៖** បើនិយាយពីរឿងហូបចុកវិញចប់ហើយ។ ដឹងស្រាប់ហើយខែ៤ ខែ៥ហ្នឹងរុយប៉ុនណា! បាយគេនាំគ្នាសែងទៅហ្នឹងគឺរុយតាម អ៊ូៗជាងឃ្មុំទៅទៀត។ បាយខាងលើមុខលើហ្នឹង សុទ្ធតែអាចម៍រុយ។ សម្លសែងទៅ ខ្ញុំមិនកុហកទេ ដួសមួយវែកណាក៏រុយដែរ បើយើងឥឡូវនេះមិនដឹងថាស្អីទេ។ កាលនោះឆ្អឹះតែខ្លួនរុយចេញទេ សូម្បីតែដួសឲ្យដោយទឹកសម្លមកជាមួយរុយហ្នឹងក៏គ្មានដែរ ធ្វើម៉េចឆ្អឹះតែរុយចេញ។ ដួសទៅចែកបន្តិចៗម្នាក់ទៅ បើបាយគេឲ្យញ៉ាំឆ្អែត តែម្ហូបរៀងចាំហើយ។ ចាស់ក្មេងគឺដូចគ្នា។

**ស៖** អ្នកស្រីបានមានប្រសាសន៍អម្បាញ់មិញថា អត់មានអនាម័យ មានរុយច្រើនរោមនៅលើម្ហូបហ្នឹង។ អ្នកស្រីដឹងថា មូលហេតុអីបានជាបណ្ដាលឲ្យមានរុយច្រើនរបៀបហ្នឹង? មកពីកន្លែងការដ្ឋានអត់មានអនាម័យ ឬក៏មកពីមូលហេតុអ្វីផ្សេង?

**ឆ៖** កន្លែងការដ្ឋានហ្នឹងគ្មានអនាម័យទេ បត់ជើងតូចបត់ជើងធំហ្នឹងរាយពាសពេញដីទាំងអស់ហ្នឹង។ រុយសុទ្ធតែរុយក្បាលខៀវ មិនមែនអារុយតូចៗទេ។ អត់ហើយ ម្នាក់ៗចេះតែហុតហើយសម្ដនោះ។ បើនិយាយពីភាពកខ្វក់វិញ គឺថាចប់តែម្ដងមិនដឹងគេបកថាម៉េចទេ បើគគ្រិចយ៉ាងហ្នឹង។

**ស៖** ចាស សូមអរគុណអ្នកស្រី។ នៅតំបន់ដែលអ្នកស្រីធ្វើការហ្នឹង តើមានបង្គន់អនាម័យសម្រាប់ឲ្យបុគ្គលិក -- សម្រាប់ឲ្យប្រជាជនដែលធ្វើការនៅការដ្ឋាននោះប្រើប្រាស់ដែរឬទេ?

**ឆ៖** ក្រោយមក ប្រហែលជាដល់ខែ -- ទៅដំបូងប៉ុន្មានខែហ្នឹងគឺគ្មានទេ ដល់ខែ ប្រហែលជាចុងខែ៤អីហ្នឹង ឃើញតាមភូមិ គេដាក់ឲ្យទៅធ្វើបង្គន់ឈើសែងហ្នឹង។ ហើយមានអ្នកទៅធ្វើជីរហ្នឹងយកផេះ យកអីទៅលាយលាមកហ្នឹងសម្រាប់ធ្វើជីរ យកមកភូមិទៀត។ គេលាយហើយដាក់ហាលលើដីហ្នឹង គេច្រកយកមកភូមិ យកមកបាចស្រូវនៅឯភូមិ។ ទឹកហូបអី នាំគ្នាហូបទឹកស្ទឹង។ ចម្រុះគ្នារាប់រយរាប់ពាន់នាក់ពីលើមក តែចេះតែហូបទៅ ធ្វើម៉េចបើអត់ហើយ។

[០៩:២១:៣៧]

**ស៖** អ៊ីចឹងមានន័យថា ទឹកដែលបរិភោគហ្នឹងគឺទឹកស្ទឹង គេអត់បានដាំទឹកឲ្យមានអនាម័យដើម្បីយកមកឲ្យប្រជាជនដែលធ្វើការហ្នឹងបរិភោគទេ។ អ៊ីចឹងបើសិនជាកម្មាភិបាលខ្មែរក្រហម គេមិនបានផ្គត់ផ្គង់ទឹកដែលមានអនាម័យដល់ប្រជាជនអ៊ីចឹង តើមានបើកសិទ្ធិឲ្យប្រជាជនធ្វើការចម្អិនទឹកញ៉ាំដោយខ្លួនឯងដែរឬទេ?

**ឆ៖** ខាងមីងគឺគ្មានទេ មានពេលឯណាទៅដាំទឹកញ៉ាំនោះ មានឆ្នាំងឯណា មានអុសឯណាដោះស្រាយរៀងៗខ្លួន រកឯណាបានញ៉ាំៗទៅ គឺគេដោះស្រាយតែបាយហ្នឹងឲ្យហ្នឹងវាពិសេសណាស់ទៅហើយ។ ធ្មេចភ្នែកណ៎ះ ញ៉ាំទឹកហ្នឹង មិនមែនបើកភ្នែកញ៉ាំកើតទេ គឺធ្មេចភ្នែកបានញ៉ាំកើត បើកភ្នែកញ៉ាំមិនកើតទេ។ កុំជឿអ្នកណាថាដាំទឹកញ៉ាំអី ខ្ញុំមិនជឿសោះ ព្រោះខ្ញុំមិនដែលឃើញ។ ទឹក មនុស្សរាប់ពាន់រាប់ម៉ឺន បីតំបន់ចូលគ្នា គិតទៅ តើវាប៉ុនណា។

**ស៖** សូមអរគុណអ្នកស្រី។ ខ្ញុំចង់សួរបន្តទៀតថា បើសិនជា -- ខ្ញុំចង់សួរបន្តទៀតថា ដោយ-សារមូលហេតុថា ការងារនៅ ទីនោះគឺគេតម្រូវឲ្យយើងធ្វើការធ្ងន់ ហើយអាហារបរិភោគមិនគ្រប់គ្រាន់

គ្មានអនាម័យ ហើយគ្មានទឹកបរិភោគគ្រប់គ្រាន់ ហើយយើងសម្រាកក៏មិនបានគ្រប់គ្រាន់អ៊ីចឹង។ ហើយលក្ខខណ្ឌការងារវាធ្ងន់ធ្ងរ ហើយវាតឹងតែងអ៊ីចឹង។ អ៊ីចឹងតើអ្នកស្រីធ្លាប់មានឃើញថាមានកម្មករដែលធ្វើការនៅទីនោះធ្លាក់ខ្លួនឈឺដែរឬទេ?

[០៩:២៣:៣៩]

**ឆ៖** នៅកន្លែងនោះធ្វើការ បើភូមិខ្ញុំម្នាក់ស្លាប់ (ប្រុស) អ្នកមូលដ្ឋានហ្នឹងស្លាប់ ដូចគេថាចាញ់ទឹកចាញ់ដី ហើយពលកម្មហ្នឹងខ្លាំង។ ម្នាក់ៗនុំងធ្វើការ ដូចថា សឹងថាមានម្នាក់ឯង គ្នាប្រឹងនៅលើវ។ ការងារអីក៏ដោយ អ្នកណាប្រើអីគេធ្វើកើតទាំងអស់ ដាប់ថ្ម ពិសេសកន្លែងដាប់ថ្មហ្នឹង និយាយពីប្រឹងជាងគេជាងឯង ចុងក្រោយគឺស្លាប់។

**ស៖** សូមអរគុណអ្នកស្រី។ គាត់ម្នាក់ដែលបានស្លាប់ហ្នឹង គាត់បានខំប្រឹងអស់ពីចិត្តដើម្បីគោរពតាមបទបញ្ជារបស់អង្គការ។ គាត់ប្រឹងទាល់តែស្លាប់ខ្លួនអ៊ីចឹងៗ នៅពេលដែលគាត់ស្លាប់ហើយ តើកម្មាភិបាលដែលទទួលខុសត្រូវលើគាត់ ដែលមើលគាត់ហ្នឹងថា តើគេមានប្រារព្ធពិធីណាមួយ -- ហើយគេធ្វើយ៉ាងម៉េចចំពោះសាកសពរបស់គាត់? តើគេមានរៀបចំអីមួយថា អ៊ូ! លើកៗសរសើរគាត់ថា គាត់ខំប្រឹងធ្វើដើម្បីអង្គការ។ តើគេមានបានធ្វើសកម្មភាពទាំងអស់ហ្នឹងដែរឬទេ?

**ឆ៖** បើនិយាយពីរឿងពិធីសពគឺគ្មានទេ។ គឺមានតែអ្នកជិតខាងទេ ដែលយំយែកស្តាយស្រណោះក្មេងហ្នឹងនោះ។ គ្មានអ្នកណា កម្មាភិបាលណាទេ សូម្បីតែប្រធានភូមិនោះក៏មិនសួររវីរវល់ផង។ គ្រាន់តែបានទៅឈរមើលខ្មោចប៉ុណ្ណឹង។ មានតែមីងហ្នឹង ហើយនិងអ្នកភូមិទេដែលស្គាល់ជិតស្និទ្ធនោះ ដែលនាំគ្នាយំយែកអាណិតក្មេងហ្នឹងនោះ។ អាណិតថាគ្នាច្បាស់លាស់ចំពោះអង្គការប៉ុណ្ណឹងហើយ ប្រឹងលះបង់ប៉ុណ្ណឹងហើយ ឲ្យគ្នាស្លាប់ទៀត។ គ្មានអ្នកណាអើយពើអី គ្មានអ្នកណារវីរវល់អី គឺគ្មានទេ គឺគ្មានសោះតែម្តង។ ស្លាប់ក៏ដោយ រស់ក៏ដោយ ធ្វើម៉េចស្រវាតែរៀងខ្លួនទៅ អ្នកស្លាប់កប់ចោល ហើយ។ ម្តាយយំបោកខ្លួន កូនតែពីរនាក់ ស្លាប់មួយទៀត។

[០៩:២៦:០៧]

**ស៖** ចាស សូមអរគុណអ្នកស្រី។ អ៊ីចឹងសូមបន្តសំណួរ ហើយខ្ញុំចង់យោងទៅលើឯកសារដែលជាព័ត៌មានដែលអ្នកស្រីបានផ្តល់ជូនតុលាការ។ នៅក្នុងឯកសារ E3/4790, ERN ជាភាសាខ្មែរ 00582096, ERN ជាភាសាបារាំង 00967208 និង ERN ជាភាសាអង់គ្លេស 00940142។ នៅក្នុងហ្នឹងអ្នកស្រីបានបញ្ជាក់ថា នៅពេលដែលយើងធ្វើការ គឺគេមានខ្សែត្រៀមនៅកន្លែងរែកដី រួចហើយមាន

កម្មាភិបាលខ្មែរក្រហមគេយាម ១០ម៉ែត្រ -- ក្នុង១០ម៉ែត្រ គឺមានខ្មែរក្រហមគេយាម។ អ៊ីចឹង ខ្ញុំចង់សួរថា នៅពេលដែលយាមយើងធ្វើការហ្នឹង តើគេមានកាន់អាវុធដែរទេ?

**ឆ៖** ពេលយាមហ្នឹង គឺគេកាន់អាវុធ។ គេនៅឈរការពារខ្លាចរត់។ ខ្លាចមានអ្នករត់ចោលការដ្ឋាន។ ខ្លាចមានអ្នកទៅលួចសម្ងំខ្ជិលរែកដី។ បើចង់បត់ដៃបត់ជើងអី ចុះទៅ ជួនកាលទៅបត់ជើងនៅមុខគេហ្នឹងហ្មងទៅ។ អើ! មិនដឹងទៅណាហើយបើគេយាម។ យើងប៉ានទៅណា។ ឈឺបត់ជើងតូចអីទៅដល់គេឈរអ៊ីចឹង នោមនឹងជើងហ្នឹង មិនដឹងទៅណាហើយ។ ទៅឆ្ងាយពីគេបន្តិចទៅ គេស្រែកឲ្យឲ្យមកវិញៗ។ អ៊ីចឹងមិនដឹងទៅណា អ្នកឯងឈរត្រង់ហ្នឹង នោមត្រង់ហ្នឹងទៅ។

[០៩:២៨:០៧]

**ស៖** ចាស សូមអរគុណអ្នកស្រី។ អ្នកស្រីថាមានគេដាក់ខ្សែត្រៀមនៅកន្លែងរែកដីហ្នឹង គេអត់ឲ្យយើងចេញក្រៅខ្សែត្រៀមហ្នឹងទេ គេហាមឃាត់យើង។ អ៊ីចឹងតើអ្នកស្រីធ្លាប់មានឃើញហេតុការណ៍ណាដែលមានអ្នកប្រជាជនដែលធ្វើការហើយ ហើយគាត់បានចេញក្រៅខ្សែត្រៀមហ្នឹង រួចហើយតើកម្មាភិបាលខ្មែរក្រហមហ្នឹង គាត់បានធ្វើអ្វីចំពោះអ្នកដែលចេញក្រៅខ្សែត្រៀមកន្លែងរែកដីហ្នឹងដែរទេ?

**ឆ៖** ចំពោះអ្នកថ្មី គឺខ្លាចគេណាស់កូន មិនប៉ានទេ។ បើអ្នកចាស់ គេអាចមានសិទ្ធិ។ បើថាប្រជាជនថ្មី មិនប៉ានសោះៗតែម្តង។ ខ្លាចណាស់ ខ្លាចៗជាទីបំផុត។ បើអ្នកប្រជាជនចាស់ហ្នឹងគេមានសិទ្ធិជាង អាចទៅសុំទៅ ចេញទៅខុសពីហ្នឹងប្រហែល១០-២០ម៉ែត្រអីបាន អ្នកចាស់។ បើថាអ្នកថ្មី រួញខ្លួនហើយកូន រួញដូចដុកឌឿអ៊ីចឹង មិនប៉ានទេ។ តែគេហាមត្រឹមណា គឺត្រឹមហ្នឹងហើយ មិនប៉ានទៅជិតទេ។

**ស៖** សូមអរគុណអ្នកស្រី។ ទាក់ទងដល់ចំណុចប្រជាជនចាស់និងប្រជាជនថ្មី ដែលអ្នកស្រីទើបតែមានប្រសាសន៍អម្បាញ់មិញនេះ ខ្ញុំនឹកឃើញកាលពីម្សិលមិញ អ្នកស្រីបានបញ្ជាក់ថា ប្រជាជនថ្មី គឺមិនមានសិទ្ធិនៅក្នុងការកាន់មុខតំណែងអីនៅក្នុងការដ្ឋានហ្នឹងទេ។ ឧទាហរណ៍ដូចជា មេកងមេអីជាដើម គឺអត់មានសិទ្ធិទេ។ អ៊ីចឹងតើអ្នកស្រីអាចជម្រាបតុលាការបានទេថា តើនៅសម័យនោះ នៅក្នុងការដ្ឋាននោះ ថាតើកម្មាភិបាលខ្មែរក្រហម គេប្រព្រឹត្តចំពោះប្រជាជនថ្មី ហើយនិងប្រជាជនចាស់ហ្នឹងមានលក្ខណៈខុសគ្នា ឬក៏ដូចគ្នារបៀបណាដែរ? បើខុសគ្នា តើខុសគ្នារបៀបណាដែរ អ្នកស្រីអាចពន្យល់ហើយរៀបរាប់បានទេ?

[០៩:៣០:១១]

**ឆ៖** រឿងនេះ គឺថាប្រជាជនចាស់ គេខុសអីបន្តិចបន្តួច គេអាចតវ៉ា គេតតាំងគ្នាទៅ គេអនុគ្រោះឱ្យគ្នាទៅ។ បើអ្នកថ្មីវិញ គឺមិនអាចមានប៉ប៉ុនសរសៃសក់ក៏មិនបានដែរ គឺការគាបសង្កត់ធ្ងន់ណាស់ ធ្ងន់ធ្ងរណាស់ សឹងតែរយះទ្រូង។ យើងមិនបានប្រព្រឹត្ត គេចោទយើងក៏ដោយ យើងនៅស្ងៀម យើងបៀមក្នុងខ្លួនហ្នឹង។ សុខចិត្តស្ងៀម ស្ងៀមដូចគេចុក ស្ងៀមៗយកមែនហ្នឹងណ៎ា ហើយចាញ់គេក៏ដោយឱ្យតែមានជីវិត។

**ស៖** សូមអរគុណអ្នកស្រី។ ខ្ញុំសូមយោងទៅឯកសារដដែល ដែលអ្នកស្រីបានផ្ដល់ជូនតុលាការនៅក្នុងទំព័រ ERN ជាភាសាខ្មែរ 00582097, ERN ជាភាសាបារាំង 00967209 និង ERN ជាភាសាអង់គ្លេស 00940142 ដល់ 43។ ខ្ញុំសូមដកស្រង់យកនូវអ្វីដែលអ្នកស្រីបានផ្ដល់ជូនទៅតុលាការ ហើយខ្ញុំនឹងសួរសំណួរបន្ថែម។ "ជីកនៅក្បែរថ្នល់ជាតិមិនទាន់រួចរាល់ទេ គេដកកម្លាំងទៅជួយទប់ស្ទឹងជីនិតគេទុកតែពួកចល័តប្រុសៗនៅដាប់ថ្ម គ្នាដំបៅជើងពីប្រអប់ជើង ស្នងជើង ដល់ជង្គង់។ ដំបៅគ្រប់គ្នាព្រោះដាក់ថ្ម ថ្មខ្ទាតត្រូវ ស្លៀកខោខ្លី បើខោវែងរហែកដល់លើជង្គង់អស់ទាំងអស់ទៅហើយ"។ ខ្ញុំចង់ដឹងថា ការដែលក្រុមចល័តប្រុសៗដែលគេធ្វើការ ហើយគេរងរបួសទាំងអស់ហ្នឹង តើហេតុការណ៍ហ្នឹងអ្នកស្រីបានឃើញដោយផ្ទាល់ភ្នែក ឬក៏បានដឹង ឬក៏បានឮ? តើអ្នកស្រីបានដឹង បានឮ ដោយរបៀបណាដែរ?

[០៩:៣២:៣៩]

**ឆ៖** រឿងនេះជារឿងពិត ព្រោះក្មេងទាំងអស់ហ្នឹងនៅក្នុងភូមិរបស់ខ្ញុំ។ គ្នាដាប់ថ្មហ្នឹងឯង តាំងពីខោវែង រហូតដល់ខោខ្លីហ្នឹង បានដំបៅជើង ព្រោះថ្មហ្នឹងឯង ថ្មដា ក្រាលនៅបាតទំនប់ហ្នឹង ប្រឹងជីកទៅក្នុងទៀត។ នាំគ្នាដាប់ ដាប់ហើយ វាខ្ទាតអាថ្មហ្នឹងមក ដំបៅហ្នឹងជើង រួចមានខោឯណា បើខោតែមួយហ្នឹង។ បើសិនជាមានខោវែង បើសិនជាមានអង្គការមើលឃើញអី គិតគូរគ្នាអី បែបជាមិនអីទេ។ ដំបៅប៉ុនៗមេដៃ មេជើង ហៀរពេញជើងទាំងអស់។ សួរថា មានថ្នាំអីបិត គឺគ្មានទេ ពេលសម្រាកហ្នឹង ដើរចូលក្នុងព្រៃទៅ មើលស្លឹកណាចត់ៗ នាំគ្នាទំពាយកមកអង្គុយបិតជើង។ មីងៗអី ចូលទៅក្នុងព្រៃអ៊ីចឹងទៅ ឃើញយកបេះយកមកផ្ញើ "អើយនាងហើយ នាំគ្នាទំពាបិទទៅ បើគ្មានថ្នាំអី" មានថ្នាំអី បើមានតែអាថ្នាំដបទឹកក្រូចពីដើមហ្នឹង ថ្នាំទឹកៗហ្នឹង។ ថ្នាំម្សៅ ថ្នាំអីឯណាមាន យកមកបិទដំបៅ គ្មានទេ។ ដំបៅស្អុះអស់ហើយ ជើងហ្នឹង។ មានអីការពារ សូម្បីតែអ្នករែកដីហ្នឹងក៏មានតែមួយចង្កេះ ផ្អេះនឹងខ្លួនដូចតែគ្នា។ អ្នកមានខោពីរហ្នឹងសុទ្ធតែសំណាងហើយ។ សារុងប៉ះ មិនដឹងជាប៉ុន្មានរយបំណះទេ សម្រាប់

ស្លៀកគេយប់។ ថ្ងៃគក់ខោទៅ ពេលល្ងាចមកវិញហ្នឹង គឺគក់ទៅ ហាលទៅ។ ញីតែទឹកហ្នឹងឯង មានសាប៊ូមានអីឯណា។ យើងស្អាតបាតពេក គេតិះដៀល វណ្ណៈនាយទុន សក្តិភូមិអី សព្វបែបសព្វយ៉ាងហើយ ពួអស់ហើយ។ មិនដឹងសក្តិភូមិម៉េច នាយទុនអីអាម៉េចទេ លោកអើយលោក។ បើវណ្ណៈគេ គេមានតែពីរទេ គឺវណ្ណៈកម្មករ និងកសិករ តែពីរហ្នឹងឯង ចុះយើងស្អាតបាតអី។ បើឃើញយើងគគ្រិចហ្នឹង បានពេញចិត្តគេ ឃើញយើងស្អាតមិនបានទេ។

[០៩:៣៥:១០]

**ស៖** សូមអរគុណអ្នកស្រី។ អ្នកស្រីបានជម្រាបជូនតុលាការអម្បាញ់មិញទាក់ទងនឹងសម្លៀកបំពាក់។ ខ្ញុំចង់សួរអ្នកស្រីថា តាំងពីពេលដែលអ្នកស្រីទៅធ្វើការនៅទំនប់ -- នៅការដ្ឋានទំនប់ ១មករាហ្នឹងមក ថាតើកម្មាភិបាលខ្មែរក្រហមដែលគ្រប់គ្រងនៅទីនោះ ថាតើគេបានផ្គត់ផ្គង់សម្លៀកបំពាក់ដល់លោកស្រី ឬក៏ដល់កម្មករផ្សេងៗទៀតហ្នឹងរបៀបម៉េចដែរ? តើគ្រប់គ្រាន់ដែរឬទេ?

**ឆ៖** ខ្ញុំទៅកាលនោះគេឲ្យកំណាត់សម្រាប់កាត់ខោមួយ កាត់អាវមួយ និងខ្លួនឯងមានខោចាស់មួយ និងអាវចាស់មួយសម្រាប់ផ្លាស់ប្តូរហ្នឹង។ ស្លៀកចាំ ហើយថែជាទីបំផុត ថ្វីត្បិតតែយើងធ្វើការរាល់ថ្ងៃ ខោអាវមានតែពីរកំប្លេហ្នឹងស្លៀកចាំ។ រឿងទុក្ខវេទនាគឺវេទនា -- គិតទៅស្រីៗមានរដូវ មកប្រឡាក់ខោ នៅជិតស្ទឹងនាំគ្នាចុះទឹកស្ទឹង ដើម្បីកុំឲ្យគេឃើញឈាមរដូវហ្នឹងប្រឡាក់ខោនាំគ្នាចុះទឹកស្ទឹង ឡើងមករែកដីទាំងសើម ប្រឡាក់ទៅចុះទៀតទៅ គ្មានអីទ្រាប់ គ្មានអីគិតគូរដល់ខ្លួនឯងទេ ហេតុតែឃើញប្រឡាក់អីចឹងឆ្គឹះប្រាប់គ្នាទៅ "ខោឯងប្រឡាក់ហើយ" យើងឃើញគេប្រាប់គេទៅនាំគ្នាចុះទឹកស្ទឹងទាំងអស់គ្នាទៅ។ ឡើងមកវិញឃើញទទឹកកកក់ ជម្រះខ្លួនដោយទឹកស្ទឹង ញ៉ាំហ្នឹង ងូតហ្នឹង លាងខ្លួនហ្នឹង។

**ស៖** សូមអរគុណអ្នកស្រី។ ខ្ញុំចង់សួរអ្នកស្រីបន្តទៀតថា តើកម្មាភិបាលខ្មែរក្រហមដែលគ្រប់គ្រងនៅហ្នឹង គេបានដឹងថាប្រជាជនដូចជាអ្នកស្រី ករណីអ្នកស្រីហ្នឹងមានការខ្វះខាតរបៀបហ្នឹងដែរឬទេ? ហើយបើសិនជាគេដឹងហើយ តើគេមានចាត់វិធានការណាមួយដើម្បីជួយដោះស្រាយបញ្ហាដែលអ្នកស្រីហើយនិងប្រជាជន -- ស្ត្រីដទៃទៀតជួបប្រទះដែរទេ?

**ឆ៖** ធ្វើដូចៗតែគ្នាហ្នឹងកូនអើយ។ អ្នកដែលគេគ្រប់គ្រងយើងហ្នឹងគេមិនដឹងខ្យល់អីទេ គេមិនដឹងអីទេ។ គេមិនដឹងមែន មិនដឹងថាយើងពិបាកយ៉ាងម៉េច អីយ៉ាងម៉េច គឺគ្មានទេ ស្រីៗគឺដូចតែគ្នាហ្នឹង។ កាលពីនៅឆ្ងាយពីស្ទឹង រែកទាំងខោប្រឡាក់ហ្នឹង មិនខ្វល់ទេ យើងក៏ដូចគេៗក៏ដូចយើង ទាល់តែបានទៅស្ទឹងហ្នឹងទេ បានពេលប្រឡាក់ខោនាំគ្នាចុះទៅក្នុងទឹកស្ទឹងហ្នឹងទៅ។ កុំឲ្យវាប្រឡាក់កាន់តែច្រើនឡើងៗ

ដឹងស្រាប់ហើយ ឈាមរដូវមិនដែលមកតិចៗទេ។

[០៩:៣៩:២២]

**ស៖** ចាស សូមអរគុណអ្នកស្រី។ ខ្ញុំចង់យោងទៅលើព័ត៌មានដែលអ្នកស្រីបានផ្តល់ជូនតុលាការម្តងទៀត នៅក្នុងឯកសារដដែល នៅក្នុងទំព័រដែលមានលេខ ERN ជាភាសាខ្មែរ00582095, ERN ជាភាសាអង់គ្លេស 00967207ដល់08, ERN ជាភាសាអង់គ្លេស 00940144។ អ្នកស្រីបានបញ្ជាក់នៅក្នុងព័ត៌មានបន្ថែមនោះថា “បុរសនិងនារី គឺហាមដាច់ខាតមិនឱ្យនិយាយគ្នាតែពីរនាក់ទេ បងប្អូន បង្កើតក៏ដោយ”។ អ៊ីចឹងខ្ញុំចង់ឱ្យអ្នកស្រីជួយពន្យល់បន្ថែម ថាតើអ្នកណាជាអ្នកចេញបទបញ្ជារបៀបនេះ? ហើយថាតើគេមានបានប្រាប់ប្រជាជនដែរឬទេ ថាហេតុអ្វីបានជាគេចេញបទបញ្ជារបៀបនេះ សូម្បីតែបងប្អូនបង្កើតដែលមានភេទផ្ទុយគ្នាក៏មិនអាចនិយាយគ្នាបាន?

**ឆ៖** មានប្រធានភូមិក៏ប្រាប់ ហើយយើងមកការដ្ឋានហ្នឹងក្រុម មេក្រុមយើងហ្នឹងក៏ប្រាប់ គឺហាមដាច់ខាត គេខ្លាចខុសសីលធម៌។ សូម្បីតែបងប្អូនបង្កើតនឹងគ្នាហ្នឹង ក៏មិនអាចឈរនិយាយគ្នាបានដែរ។ តែគេឃើញ គឺគេប្រាប់ថាគេចាប់អ៊ីចឹងតែម្តង គេមិនឱ្យទេ ពេលម៉ោងធ្វើការហ្នឹង ព្រោះយោធានៅយាមកៀកៗកន្លែងយើងចាក់ដីហ្នឹង។ បានជាខ្ញុំដឹងពិតប្រាកដ ព្រោះយោធាចាប់ពីរនាក់បងប្អូនហ្នឹងចាប់លើកទី១ គេថាគ្រាន់តែព្រមានទេ។ មកដល់គេចាប់ដៃពីរនាក់ហ្នឹង កុំឱ្យឈរនិយាយគ្នា “មិត្តឯងមានការអី?” ប្រាប់ថា “ខ្ញុំបងប្អូនបង្កើត” “បងប្អូនបង្កើតក៏ដោយ ចុះទៅឱ្យឆាប់! ចុះទៅក្រោម ចុះទៅកន្លែងរែកដី តែមានលើកទី២ អត់បានទេ!”។ ខ្ញុំរែកដីដើរកាត់តាមនុ៎ង គ្រាន់តែព្រឺព្រាក់សាច់អស់ហើយអ្ហឺ! ចិត្តអាក្រក់ម្ល៉េះ គ្រាន់តែបងប្អូនបង្កើតជួបគ្នានិយាយគ្នាមិនបាន។ អារម្មណ៍ចេះតែគិតថា ទៅថ្ងៃមុខទៀតមិនដឹងយ៉ាងម៉េចទេ តឹងឡើងៗយ៉ាងនេះ។

[០៩:៤២:១៧]

**ស៖** ចាស សូមអរគុណអ្នកស្រី។ នៅក្នុងរយៈពេលដែលអ្នកស្រីធ្វើការនៅការដ្ឋានទំនប់១មករាហ្នឹងតើអ្នកស្រីធ្លាប់ឃើញមានថ្នាក់ដឹកនាំជាន់ខ្ពស់របស់ខ្មែរក្រហម ឬក៏គណៈប្រតិភូរបស់ប្រទេសក្រៅណាដែលគេមកធ្វើទស្សនកិច្ចនៅការដ្ឋានដែលអ្នកស្រីកំពុងធ្វើការហ្នឹងដែរឬទេ? ធ្លាប់មានឃើញទេ?

**ឆ៖** ធ្លាប់ឃើញ យើងនៅរែកដីហ្នឹង ឃើញឡាវ ព្រោះគេប្រកាសតាមមីក្រូ គេថាគណៈប្រតិភូឡាវ ស្រីៗធាត់ៗធំ គេមានសម្លៀកបំពាក់ស្អាតៗ យួរកាបូបដើរកាត់កន្លែងយើងធ្វើការហ្នឹង។ ហើយម្តងទៀតនោះជនជាតិនេប៉ាល់ ខ្មៅធំៗ។ ហើយខ្ញុំបានទៅទទួលម្តង អ្នកមូលដ្ឋានគេប្រាប់ថា “តាពក”។

ថា តាពក ទៅការដ្ឋានហ្នឹង។ ហើយនិងដំបូងបង្អស់ខ្ញុំភ្លេចទៅ មិនដឹងគណៈប្រតិភូអីទេ យើងធ្វើការហ្នឹង មីក្រូគេស្រែកមកថា សូមឲ្យបងប្អូនត្រៀមចាំទទួល ប៉ុន្តែខ្ញុំភ្លេចទៅអង្កាល់ហ្នឹងមិនដឹងពីណា។ ហ្នឹងពិធីធំណាស់ គេមានទង់មានអីលើកក្រវីជយឃោសសម្បើមណាស់កាលនុំង។ ចំណែកឡាវ និងនេប៉ាល់ហ្នឹងបានខ្ញុំដឹង ព្រោះគេប្រកាសតាមមីក្រូ បានខ្ញុំដឹងច្បាស់ថានេប៉ាល់ ថាឡាវហ្នឹង។ គេស្រែកថា គណៈប្រតិភូឡាវអីអ៊ីចឹង បានខ្ញុំដឹង។

**ស៖** ចាស សូមអរគុណអ្នកស្រី។ អ្នកស្រីអាចរៀបរាប់បានទេថា នៅពេលដែលថ្នាក់ដឹកនាំជាន់ខ្ពស់កម្មាភិបាលខ្មែរក្រហម ក៏ដូចជាគណៈប្រតិភូក្រៅប្រទេសដែលគេមកការដ្ឋានហ្នឹង ថាតើអ្នកស្រីបានឃើញថាតើគេមកគេធ្វើអីគេខ្លះ? ថាតើគេមានចូលរួមចំណែកនៅក្នុងការរែកដីជាមួយប្រជាជននៅទីហ្នឹងទេ ឬមួយក៏គេមកធ្វើអ្វីផ្សេង?

**ឆ៖** ចំណែករឿងគណៈប្រតិភូហ្នឹង ឃើញតែគេដើរកាត់ហ្នឹង យើងកំពុងតែរែកដីហ្នឹង។ ឃើញតែគេដើរកាត់ ម្នាក់ៗតាមមើលឡើងផ្អៀងកអស់ហើយ ឃើញខោអាវគេស្អាតៗ ស្លៀកពណ៌រាងអាចម៍សេះ ហើយយួរកាបូបទៀត ស្អាតណាស់ ស្អាតមែនទែន បើត្រគាកធំៗ ធាត់ៗ ធំៗ។ ឃើញគេស្លៀកពាក់ស្អាតបាត។

[០៩:៤៥:២១]

**ស៖** ចាស សូមអរគុណអ្នកស្រី។ ខ្ញុំចង់យោងទៅឯកសារដដែល ដែលអ្នកស្រីបានផ្តល់ជូននៅក្នុងទំព័រ ERN ជាភាសាខ្មែរ 00582097, ERN ជាភាសាបារាំង 00967209, និង ERN ជាភាសាអង់គ្លេស 00940143។ នៅក្នុងព័ត៌មាននោះ អ្នកស្រីបានប្រាប់ផងដែរថា មានការថតកុននៅទំនប់នោះ។ តើអ្នកស្រីបានឃើញសកម្មភាពគេធ្វើរបៀបម៉េចនៅក្នុងការដែលថតកុនហ្នឹង តើអ្នកស្រីអាចរៀបរាប់បានទេ? ហើយតើគេ -- អ្នកស្រីមានបានចូលរួមចំណែកនៅក្នុងការថតកុនហ្នឹងដែរឬទេ? ហើយគេតម្រូវឲ្យយើងធ្វើអីខ្លះ? តើអ្នកស្រីអាចរៀបរាប់លម្អិតជូនសវនាការបានទេអំពីការដែលគេថតកុននៅទំនប់នោះ?

**ឆ៖** ការថតកុន ខ្ញុំបាននៅ ខ្ញុំនៅរែកដី រែកអីនឹងគេហ្នឹង មីក្រូស្រែកខ្លែងៗ គេឲ្យធ្វើសកម្មភាព ព្រោះគេធ្វើឈើអីរើគងៗឡើងលើខ្ពស់ ថតមកក្រោមហ្នឹង។ បើកាយអាចម៍ដីមិនទាន់ទេ គេឲ្យយើងធ្វើចលនារែក តែបង្គីទទេហ្នឹង ធ្វើម៉េចឲ្យដើរឃើញថាកុំឲ្យទំនេរណា។ អ្នកកាយដីទាន់ក៏ទាន់ អ្នកមិនទាន់រែកបង្គីទទេហ្នឹងដើរវិលមុខអស់ហើយ។ បីតំបន់ហ្នឹងឡូកចូលគ្នាទាំងអស់។ ធ្វើសកម្មភាពយ៉ាងណាឲ្យ

គេថាឲ្យវារស់រវើក ឲ្យវាសស្រាក់សស្រាំដូចពាក្យស្លោកជំនាន់នោះៗ ដែលធ្វើម៉េចឲ្យរស់រវើក។ ខ្ញុំចង់ដឹង ហើយខ្ញុំក៏ចង់ឃើញកុនហ្នឹង ព្រោះថតថ្ងៃនុ៎ង នេះណាស់ ប្រឹងណាស់ម្នាក់ៗ។ មេកង មេក្រុមហ្នឹង គឺឈរបញ្ជាតែម្តង ធ្វើម៉េចមិនឲ្យអាក់បន្តិច មិនឲ្យអាក់តែម្តង ធ្វើម៉េចឲ្យដើរប្រឹងគ្រប់គ្នា ខាងគេខាងយើង តំបន់គេ តំបន់យើងហ្នឹង ស្រែក ឮតែមាត់ស្រែកបញ្ជាខាងក្រោមហ្នឹង។ ធ្វើម៉េចឲ្យលឿន ធ្វើម៉េចឲ្យសកម្មឡើង កុំឲ្យមានអ្នកឈរ កុំឲ្យមានអ្នកអង្គុយ ចេះតែកាយទៅ ជួនកាលកាយចបទទេក៏មាន រែកបង្គីទទេក៏មាន។

[០៩:៤៨:០២]

**ស៖** ចាស សូមអរគុណអ្នកស្រី។ ទាក់ទងជាមួយនឹងឪពុកអ្នកស្រី ដែលកាលពីម្សិលមិញអ្នកស្រីបានជម្រាបជូនសវនាការថា ឪពុករបស់អ្នកស្រី ហើយនិងប្អូនអ្នកស្រីពីរនាក់ទៀតត្រូវបានគេចាត់ឲ្យទៅធ្វើការដោយបង្ខំនៅការដ្ឋានទំនប់ ១មករាដែរ។ ខ្ញុំចង់យោងទៅឯកសារដែលអ្នកស្រីបានផ្តល់ជូនតុលាការ នៅក្នុងឯកសារដដែល ERN ជាភាសាខ្មែរ 00582097, ERN ជាភាសាបារាំង 00967209, ERN ជាភាសាអង់គ្លេស 00940142។ នៅក្នុងនោះអ្នកស្រីបានបញ្ជាក់ថា "ឪពុករបស់អ្នកស្រីត្រូវបានគេយកទៅសម្លាប់នៅវត្តបារាយណ៍ជាន់ដែក"។ អ៊ីចឹងតើអ្នកស្រីដឹងអ្វីខ្លះពីវត្តបារាយណ៍ជាន់ដែកហ្នឹង? តើអ្នកស្រីអាចជម្រាបជូនតុលាការបានទេ ថាតើទីកន្លែងនោះគឺជាកន្លែងអ្វីដែរ?

**ឆ៖** កាលនោះ គ្រាន់តែឮគេថាទេ មិនដែលបានទៅជិត មិនដែលបានទៅឃើញទេ ទាល់តែដាច់ហើយទេបានទៅឃើញកន្លែងនោះ។ កាលជំនាន់នោះ គ្រាន់តែឮថា គេសម្លាប់មនុស្សគឺនៅវត្តបារាយណ៍ជាន់ដែកហ្នឹងឯង។

**ស៖** សូមអរគុណអ្នកស្រី។ នៅក្នុងព័ត៌មាននោះ កន្លែងដដែលហ្នឹងអ្នកស្រីបានបញ្ជាក់ថាប្អូនអ្នកស្រីដឹងរឿងនេះដោយសារប្អូនរបស់អ្នកស្រីទាំងពីរហ្នឹងបានប្រាប់អ្នកស្រីថា "លោកប៉ាហ្នឹងត្រូវបានគេយកទៅសម្លាប់នៅវត្តបារាយណ៍ជាន់ដែកហើយ"។ ខ្ញុំចង់សួរថា តើប្អូនទាំងពីរនោះគាត់ឃើញហេតុ-ការណ៍ដែលគេយកឪពុក -- យកលោកឪពុកហ្នឹងទៅដោយផ្ទាល់ភ្នែក ឬក៏គាត់បានដឹង ឬក៏គាត់បានឮតាមគេ? ហើយបើគាត់បានដឹង បានឮ តើគាត់បានដឹង បានឮតាមរបៀបណា? អាចជម្រាបជូនបានទេ?

[០៩:៥០:១២]

**ឆ៖** ថ្ងៃនោះក៏ជាថ្ងៃចៃដន្យដែរ។ ខ្ញុំទៅធ្វើការពេលព្រឹក ខ្ញុំមករដូវ ខ្ញុំចុកពោះ ខ្ញុំធ្វើការមិនកើត ខ្ញុំសុំគេមកសម្រាកនៅកន្លែង។ ខ្ញុំចុកពោះ ចុកឡើងស្លេកស្លាំងអស់ហើយ ទៅប្រធានកងហ្នឹង ឲ្យគេជូនខ្ញុំ

មកសម្រាកនៅរោង។ ល្ងាចនោះហើយ ល្ងាចថ្ងៃ៥ ខែ៤ នោះហើយ ខ្ញុំនៅចាំប្រាកដ ដែលគេហៅប៉ាទៅហ្នឹង។ ប្អូនខ្ញុំឃើញនឹងភ្នែក ប្រាប់ថា ហៅយកទៅជួយលីឈើ ទៅជួយសែងឈើគេ យោធាមកហៅ។ ប្អូនខ្ញុំឃើញ ប្អូនខ្ញុំដឹង ខ្ញុំជីកនៅប្លង់ជាប់ហ្នឹង តែខ្ញុំថ្ងៃនោះ ខ្ញុំមករដូវហ្នឹង ល្ងាចខ្ញុំសម្រាក គឺយប់ហ្នឹងឯងប្រហែលជាម៉ោងប្រាំពីរយប់ហ្នឹង។ រួចទាល់តែភ្លឺឡើង បានប្អូនខ្ញុំមកប្រាប់ថា "បងគេហៅប៉ាទៅបាត់ហើយ មួយយប់ហើយ អត់ឃើញប៉ាយើងមកវិញទេ"។ ខ្ញុំប្រាប់ប្អូន "ខំធ្វើការងារទៅ" សូម្បីតែយំទឹកភ្នែកមួយដំណក់ពេលនុ៎ងក៏អត់មានដែរ យំមិនចេញទេ។ មិនដែលបែកបាក់គ្រួសារ ឥឡូវចាប់ផ្ដើមបែកហើយ បែកឪពុកជាស្រឡាញ់ កូនៗមិនដែលបានអីតបស្នងសងគុណលោក ហើយតាំងពីនៅក្មេង បាត់រហូត។ នៅមុខគេ មុខឯង មិនដែលហ៊ានយំទេ លោកអើយ សូម្បីតែអ្នកធ្វើការនៅជាមួយក៏ដោយ "បង បងឯង កុំពិបាកចិត្ត បងឯងខំធ្វើការដើម្បីរស់"។ ឪពុកមួយទាំងមូល។

[០៩:៥២:៤២]

**ស៖** សូមអរគុណអ្នកស្រី។ ខ្ញុំមានសំណួរមួយទៀត ទាក់ទងទៅនឹងប្អូនរបស់អ្នកស្រីឈ្មោះ ហ៊ុន សុខកុមារ។ នៅក្នុងឯកសារដដែលហ្នឹង អ្នកស្រីបានបញ្ជាក់ថា នៅពេលដែលប្អូនម្នាក់នោះ គាត់បានឮដំណឹងថា ឪពុកត្រូវបានគេយកទៅសម្លាប់ គាត់តក់ស្លុតខ្លាំងពេក ហើយគាត់ក៏ធ្លាក់ខ្លួនឈឺ។ អ៊ីចឹង ខ្ញុំចង់ដឹងថា កូននោះ -- ប្អូនម្នាក់ឈ្មោះ ហ៊ុន សុខកុមារ នោះ ថាតើគាត់ពេលហ្នឹង គាត់មានអាយុប៉ុន្មានដែរ?

**ឆ៖** កាលនុ៎ង អាយុប្រហែល១៣ឆ្នាំ – ១២-១៣ហ្នឹង។ មានអ្នកភូមិហ្នឹង គេទៅមកៗ គេប្រាប់ថា "ហ៊ឺ! ប៉ាគេយកទៅបាត់ហើយ" ហើយប្អូនខ្ញុំនៅឃ្វាលគោឯភូមិ។ គ្រាន់តែឮថាគេចាប់ប៉ា វាដួលសន្លប់នៅកណ្ដាលផ្លូវ សន្លប់តាំងពីម៉ោងមួយថ្ងៃ រហូតដល់ម៉ោងប្រាំល្ងាច។ នៅដេកនៅលើដីហ្នឹងឯងម្នាក់ឯង ដឹងខ្លួនក៏ម្នាក់ឯង។ ខ្ញុំបានដឹងដោយសារវាប្រាប់។ ខែមេសា គេហៅប៉ាទៅខែឧសភា ប្អូនប្រុសខ្ញុំហ្នឹងឈឺស្លាប់ នៅខែឧសភាហ្នឹងឯង។ វាថា "បងអើយ! ខ្ញុំគ្រាន់តែដឹងថាប៉ាស្លាប់ គេយកប៉ាទៅហ្នឹងខ្ញុំបាត់ព្រលឹងអស់រលីង។ ខ្ញុំបាត់ព្រលឹងហើយ ខ្ញុំអត់មានព្រលឹងនៅក្នុងខ្លួនទេ ខ្ញុំដួល។ ខ្ញុំដួលតាំងពីម៉ោងមួយ ខ្ញុំដឹងថាពេលបាយហើយមួយស្របក់ហ្នឹង តែងតែចេញទៅមើលគោហ្នឹង គឺម៉ោងមួយ"។

[០៩:៥៤:៣២]

ពេលឈឺកាលហ្នឹងឯង នៅទំនប់១មករាហ្នឹង គេឲ្យខ្ញុំមកផ្ទះ មកយកអីវ៉ាន់ចុងភៅអីទេ ខ្ញុំចូលទៅថា "អូនឯងកើតអី?" ថា៖ "ខ្ញុំនឹងប៉ាណាស់ បងអើយ ខ្ញុំនឹងប៉ាណាស់។ ប៉ាខ្ញុំទៅបាត់ហើយ។ មុខជា

ស្លាប់ហើយ មិនរស់ទេ។ ខ្ញុំអត់មានព្រលឹងនៅក្នុងខ្លួនទេ បងអើយ ខ្ញុំគ្មានព្រលឹងសោះហើយ។ ខ្ញុំនឹងប៉ាខ្លាំងណាស់។" ប្អូនខ្ញុំចាប់ផ្ដើមឈឺរហូត យកទៅដាក់នៅពេទ្យពណ្ណរាយ នៅកំពង់ថ្មហ្នឹងឯង។ ពេលទៅពេទ្យហ្នឹងឯងខ្ញុំអត់ដឹងទេ ម៉ាក់ខ្ញុំទេ គាត់ផ្ដាំៗតាមគេថាឲ្យខ្ញុំហ្នឹងទៅមើលប្អូនមួយភ្លែតផង សម្រាកពីការងារដើរផងរត់ផង ទៅជួបប្អូនប្រហែលជាមិនបានដប់នាទីផង ខ្លាចមកវិញធ្វើការមិនទាន់។ ទៅដល់កន្លែងនោះខ្ញុំមើលម្ដាយខ្ញុំមិនស្គាល់ទេ នៅតែស្បែកហើយនិងឆ្អឹង អ្នកឈឺដូចអ្នកជាៗដូចអ្នកឈឺ។ រួចហើយខ្ញុំត្រឡប់មកផ្ទះវិញមកបានមួយថ្ងៃពីរថ្ងៃ គេផ្ដាំមក -- ម៉ាក់ខ្ញុំផ្ដាំមកថាប្អូនស្លាប់បាត់ហើយកប់នៅកន្លែងនុ៎ងបាត់ហើយ។ ធ្វើម៉េចបើអ៊ីចឹងទៅហើយ ចង់ធ្វើបុណ្យក៏មិនបាន ចង់ឧទ្ទិសអីក៏មិនបាន ចង់ទៅមើលប្អូនជាលើកចុងក្រោយក៏មិនបាន។ បែកបាក់ម្ដងមួយៗ អស់រលីង។

[០៩:៥៦:២១]

**ស៖** សូមអរគុណអ្នកស្រី។ ខ្ញុំមានសំណួរពីរសំណួរចុងក្រោយទៀត ទី១ គឺទាក់ទងជាមួយហ្នឹងប្អូនស្រីរបស់អ្នកស្រីពីរនាក់ដែលត្រូវបានគេចាត់តាំងឲ្យធ្វើការនៅ ទំនប់១មករា នោះដែរ ឈ្មោះហ៊ិន សុជីវ៉ាត និង ហ៊ិន កុលធីតា។ តើអ្នកស្រីអាចជម្រាបតុលាការបានទេថា ក្រោយមក តើមានរឿងអ្វីកើតឡើងចំពោះពួកគាត់? ថាតើពួកគាត់មានជីវិតរស់នៅសព្វថ្ងៃ ឬក៏មានរឿងអ្វីកើតឡើងចំពោះពួកគាត់?

**ឆ៖** កាលនោះ ប្អូនខ្ញុំមានរឿងមួយ គេចោទ ព្រោះគ្នាអ្នកថ្មីឯណាទៅប៉ានលួចសំពត់គេយកមកដាក់ក្នុងសាក់កាដូខ្លួនឯងនោះ។ មានម្នាក់នៅជិតហ្នឹងច្រណែន មិនដឹងទំនាស់គ្នារឿងអ្វីទេ ខ្ញុំក៏អត់ដឹងៗពេលផ្ទុះរឿងឡើងមានគេទៅប្ដឹងប្រធានកងហ្នឹងថា ប្អូនខ្ញុំលួចសំពត់គេ។ រួចមនុស្សឯណាទៅភ្លើលួចគេយកមកដាក់ក្នុងសាក់កាដូខ្លួនឯងនេះ។ បើលួចបានហើយគេយកទៅលាក់ឯណាឲ្យឆ្ងាយហើយ គេមិនដែលល្ងង់លួចរបស់គេ ជាប់គ្នាហ្នឹងយកមកដាក់កាតាបខ្លួនឯងទេ។ ប្អូនខ្ញុំរួចខ្លួនដោយសារមានអ្នកក្បែរខាងហ្នឹងជួយគាំទ្រ ដឹងថាប្អូនខ្ញុំហ្នឹងមិនចេះលួចអីគេទេ មុខជាម្នាក់ហ្នឹងហើយយកមកដាក់ហ្នឹង គេនាំគ្នាព្រួតគ្នាស្ដីឲ្យ គេនាំគ្នាជួយតតាំងប្អូនខ្ញុំ បានប្អូនខ្ញុំនៅមានជីវិតតទៅទៀត។ បើតាមតែអ្នកខូចហ្នឹងឯងគឺគេយកទៅបាត់ហើយ គេមិនទុកទេប្អូនស្រីហ្នឹងនោះ។ ព្រោះកន្លងមក គេធ្លាប់ដឹងៗថាគ្នាអ្នកថ្មីផងរួញខ្លួន មិនប៉ានធ្វើអីទេ រួចរឿងអីទៅលួចសំពត់គេយកមកដាក់កាតាបខ្លួនឯងហ្នឹង គ្នាមិនប៉ានទេ។ បានម្នាក់នោះគេដឹងរឿងហ្នឹង គេប្រាប់ថាមុខតែវាហ្នឹងហើយអ្នកខូចនោះ គឺអ្នកមូលដ្ឋានហ្នឹងឯងយកមកដាក់ឲ្យនោះ។ បម្រុងឲ្យកើតរឿង តែទៅមិនរួច មានអ្នកល្អច្រើនគេជួយកាន់ជើងប្អូនខ្ញុំ។ គេជឿជាក់

ថាមុខជាមិនហ៊ានទេ បើមានអ្នកលួចយកមកដាក់វិញគេជឿ។ មានកុំតែមានអ្នកឃើញ អ្នកជួយហ្នឹង ប្អូនខ្ញុំប្រហែលជាមិនបានរស់ទេ គេយកទៅទៀតហើយ។

[០៩:៥៨:៤៦]

**លោកស្រី ម៉ុច សុវណ្ណារី៖**

សូមអរគុណអ្នកស្រី។ សូមអរគុណលោកប្រធានខ្ញុំអស់សំណួរហើយ សូមបន្តវេទិកានេះ សូមស្នើសុំលោកប្រធានអនុញ្ញាតឲ្យអ្នកស្រី ម៉ារី ហ្គី្លរ៉ូដ៍ សួរសំណួរបន្ត។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណអង្គជំនុំជម្រះអនុញ្ញាត។ សូមអញ្ជើញ!

**លោកស្រី ម៉ារី ហ្គី្លរ៉ូដ៍៖**

សូមអរគុណលោកប្រធាន។

**សួរដោយលោកស្រី ម៉ារី ហ្គី្លរ៉ូដ៍៖**

**ស៖** ជម្រាបសួរលោកស្រីដើមបណ្ដឹងរដ្ឋប្បវេណី! ខ្ញុំមានសំណួរបន្តតែមួយទេ<> ទាក់ទងទៅនឹងមន្ទីរពេទ្យដែលអ្នកស្រីទើបតែបាននិយាយ ហើយដែលលោកស្រីបានឃើញម្ដាយរបស់លោកស្រីនៅទីនោះ។ អ៊ីចឹង តើលោកស្រីអាចពិពណ៌នាអំពីមន្ទីរពេទ្យកំពង់ថ្មហ្នឹងបានទេ? បើតាមការចងចាំរបស់លោកស្រីហ្នឹង មន្ទីរពេទ្យហ្នឹងយ៉ាងណាដែរ? មានលក្ខណៈដូចម្ដេចដែរ?

**លោកស្រី ហ៊ុន សិត្ថានី៖**

**ឆ៖** ចាស មន្ទីរពេទ្យហ្នឹងឯងគឺជាសាលារៀន១ ដូចជារាងទម្រេតទម្រោតទៅហើយ។ ខាងក្រោមហ្នឹងដី គ្មានស៊ីម៉ង់ត៍គ្មានអីទេ។ អ្នកជំងឺ គេហៅពេទ្យពណ្ណរាយណ៍ហ្នឹងឯង គឺជំងឺពីខាងបារាយណ៍ហ្នឹង គឺគេបញ្ជូនទៅនុ៎ង។ កន្លែងនុ៎ងដូចគេហៅពេទ្យស្រុកអ៊ីចឹងហើយយ៉ាង ពេទ្យពណ្ណរាយហ្នឹង ព្រោះពីខាងណាៗមកគេបញ្ជូនទៅកន្លែងនុ៎ងទាំងអស់។ ចូលទៅកន្លែងនោះ គឺអ្នកឈឺនិងជាហ្នឹងដូចតែគ្នាហ្នឹង ឃើញតែក្បាលត្រមែងៗ ខ្លួនហ្នឹងគ្មានសាច់គ្មានឈាមទេ។ ចេះតែកូនយកម្ដាយ នាំគ្នាយកទៅមើលទៅ។ ចំណែកថ្នាំសង្កូវអីមិនដឹងយ៉ាងម៉េចទេ ព្រោះខ្ញុំមិនបានឃើញ ខ្ញុំបានទៅអើតប្អូនហ្នឹងគឺខ្ញុំទៅមួយភ្លែតហ្នឹងឯង គ្រាន់តែបានទៅអើតប្អូនហ្នឹង មិនដល់១០នាទីផង ខ្ញុំចេញមកវិញហ្នឹង។

[១០:០១:០២]

**ស៖** សូមអរគុណ។ ពេលដែលលោកស្រីនិយាយថាមន្ទីរពេទ្យហ្នឹងមិនមែនធ្វើពី<ស៊ីម៉ងត៍>

ហ្នឹង <តើ>លោកស្រីអាចបញ្ជាក់បានទេថាមន្ទីរពេទ្យហ្នឹងធ្វើអំពីអ្វីដែរ?

**ឆ៖** គឺធ្វើអំពីឈើប្រក់ក្បឿងហ្នឹង សាលារៀនចាស់ពីដើម។ ដូចជារាងចង់ទទ្រេតទទ្រោត វាមិនត្រង់ល្អផង។ មួយបន្ទប់ហ្នឹងគេងប៉ុន្មាននាក់ឯណោះ ដាក់គ្រែពីរបីអ៊ីចឹងទៅ អ្នកទៅទាន់មិនទាន់ទៅគេងនឹងដីខ្លះអីខ្លះទៅ។ ចំណែកថ្នាំសង្កូវអី ខ្ញុំមិនដឹង ព្រោះខ្ញុំបានទៅរយៈពេលខ្លី ខ្ញុំមិនដឹងថាគេមានថ្នាំអីៗចាក់ខ្លះអីអត់ អត់ដឹង។

**លោកស្រី ម៉ារី ហ្គីរ៉ូដ៍៖**

សូមអរគុណលោកស្រីដើមបណ្ដឹងរដ្ឋប្បវេណី។

លោកប្រធាន ខ្ញុំអស់សំណួរហើយលោកប្រធាន សូមអរគុណ។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ ហើយជាបន្តអង្គជំនុំជម្រះផ្ដល់វេទិកាជូនតំណាងសហព្រះរាជអាជ្ញាដើម្បីមានឱកាសតាំងសំណួរដេញដោលចំពោះដើមបណ្ដឹងរដ្ឋប្បវេណីរូបនេះ។

**កញ្ញា សុង ឆវ័ន្ត៖**

ចាស សូមអរគុណលោកប្រធាន។ សូមគោរពលោកប្រធាន លោក លោកស្រីចៅក្រម និងអង្គសវនាការទាំងមូល។

**ការតាំងសំណួរដោយសហព្រះរាជអាជ្ញា**

**សួរដោយកញ្ញា សុង ឆវ័ន្ត៖**

**ស៖** សូមជម្រាបសួរលោកស្រី សិត្ថានី។ ខ្ញុំមានសំណួរខ្លីទេ ដើម្បីសួរបញ្ជាក់ ហើយនិងបន្ទាប់មកនឹងផ្ដល់វេទិកាជូនសហការីអន្តរជាតិរបស់ខ្ញុំ។ ចង់សួរលោកស្រីថា នៅក្នុងអំឡុងពេលដែលលោកស្រីធ្វើការនៅទំនប់១មករាហ្នឹង លោកស្រីមានដែលឃើញមានស្ត្រីមានផ្ទៃពោះគាត់បានទៅធ្វើការដែរឬទេនៅពេលនោះ?

**លោកស្រី ហ៊ុន សិត្ថានី៖**

**ឆ៖** នៅខាងខ្ញុំ គឺគ្មានទេ។ នៅតំបន់គេម៉េចមិនដឹង ប៉ុន្តែខាងខ្ញុំអត់មាន។

**ស៖** ចុះមានការរៀបចំចាត់ចែងយ៉ាងណាដែរ ចំពោះស្ត្រីមានផ្ទៃពោះនៅកន្លែងលោកស្រីហ្នឹង?

[១០:០៣:៤២]

**ឆ៖** គឺគ្មានទេ គឺគ្មាន! រស់តាមសម្មាអាជីវោ កើតរួចក៏រួច កើតមិនរួចក៏ស្លាប់។ គ្មានអីអាងទេ

គ្មានសោះ! លោកឪពុកខ្ញុំគាត់តែងតែភ័យ ព្រោះខ្ញុំកាលនោះខ្ញុំមានគ្រួសារហើយ។ លោកឪពុកខ្ញុំផ្ដាំថា "កុំឱ្យមានកូនមានចៅអីកូនណ៎ា កុំឱ្យប៉ាពិបាកចិត្ត"។ មិនថាអ្នកថ្មី អ្នកចាស់ទេ គឺមានពោះពុងគឺផ្សងព្រេង កើតផុតពីខ្លួនមានសេចក្ដីសុខក៏សុខ កើតមិនរួចគឺស្លាប់។ គ្មានទេ គ្មានអីអាងទេ អាងអី បើអត់មានអីសោះ ទទេអ៊ីចឹង គ្មានអីអាងទេ អាយុជីវិតខ្លីហើយ។ សំណាងល្អហើយដែលបានកូនកើតផុតមកស្រីគេស្រីខ្ញុំ បើអត់មានវាល្អជាងមាន។

**ស៖** ចាស សូមអរគុណលោកស្រី។ មុននេះលោកស្រីបានបញ្ជាក់ថា នៅទំនប់១មករាហ្នឹងមានការប្រមូលប្រជាជនបីតំបន់ឱ្យមកធ្វើការជាមួយគ្នា។ តើលោកស្រីដឹងទេថា តើមានប្រជាជនប្រហែលជាប៉ុន្មានដែលធ្វើការនៅទំនប់១មករានោះ? ខ្ញុំដឹងថាលោកស្រីអត់បានរាប់ទេ ប៉ុន្តែអាចប្រហែលបានទេ រាប់រយ រាប់ពាន់ ឬក៏ដល់រាប់ម៉ឺននាក់ដែរ?

**ឆ៖** ច្រើនណាស់ ថ្នាក់បីតំបន់ចូលគ្នាហើយច្រើនណាស់ មនុស្ស។ បើតាមស្មានប្រហែលជារាប់ម៉ឺននាក់។ ចុះតំបន់៤១ តំបន់៤២ តំបន់៤៣ ពេលទប់ស្ទឹងហ្នឹងគឺច្រឡូកចូលគ្នា អ្នកដាប់ថ្ម នៅទៅអ្នកតាមសម្អាតតាមប្រឡាយហ្នឹងគឺនៅទៅ ហើយអ្នកដែលសម្រុកស្ទឹងហ្នឹងគឺ ទៅចូលគ្នាច្រឡូកប៉ូកប៉ាកគ្នាទ្រុំង ធ្វើម៉េចរែកដីឱ្យតែលឿនយកមកចាក់។

[១០:០៦:១៧]

**ស៖** ពាក់ព័ន្ធទៅនឹងទំហំការងារដែលលោកស្រីត្រូវតែធ្វើរាល់ថ្ងៃហ្នឹង តើអ្នកណាជាអ្នកចាត់ចែង ឬក៏កំណត់ជាទំហំការងារដែលត្រូវធ្វើហ្នឹង?

**ឆ៖** គឺមានប្រធានកង ប្រធានក្រុម គេចាត់ចែង គេមិនឱ្យយើងទំនេរទេ គឺគេមានការងាររហូត។ ទៅត្រង់ណេះ ត្រង់ណោះ ធ្វើម៉េចឱ្យតែការងារសម្រុកឱ្យបានលឿន ឱ្យយើងប្រឹងធ្វើម៉េចអស់ពីកម្លាំងកាយចិត្ត។

**ស៖** ចាស សូមអរគុណ។ ចុះនៅក្នុងក្រុម នៅក្នុងកងហ្នឹងមានមនុស្សប៉ុន្មាននាក់ដែរក្នុងមួយកង ឬមួយក្រុមហ្នឹង?

**ឆ៖** ខ្ញុំដឹងច្បាស់ខាងស្រីៗភូមិខ្ញុំហ្នឹងប្រហែលជា ៥០នាក់ៗ ប្រុសៗហ្នឹងប្រហែល ៣០-៤០អ៊ីចឹងទៅ តាមតិចតាមច្រើន ហើយនិងចល័តទី២ហ្នឹង ប្រហែលជា១០នាក់ជាង ព្រោះកម្លាំងហ្នឹងដកទៅដកមក។ ជួនកាលកម្លាំងតាមភូមិគេថែមមក ភូមិគេត្រូវការ គេដក៤-១០នាក់ត្រឡប់ទៅវិញទៅវិញទៅមកអ៊ីចឹងទៅ បានរកកំណត់មិនបាន។

**ស៖** ចាស សូមអរគុណ។ មុននេះបន្តិចខាងសហមេធាវីបានសួរលោកស្រីពាក់ព័ន្ធទៅនឹងកម្មាភិបាលដែលគាត់ធ្វើការគ្រប់គ្រងនៅកន្លែងហ្នឹងថា ប្រសិនបើស្ថានភាពរស់នៅរបស់ប្រជាពលរដ្ឋមានការខ្វះខាត ការងារធ្ងន់អីចឹង ថាតើគាត់មានចាត់វិធានការ ឬក៏មានការបង្ការណាមួយទេ។ លោកស្រីបានឆ្លើយថា "ពួកគាត់មិនដឹងខ្យល់អីទេ"។ អ៊ីចឹងខ្ញុំចង់ឲ្យលោកស្រីជួយបញ្ជាក់ ថាតើ "ពាក្យមិនដឹងខ្យល់"ហ្នឹងមានន័យថា ពួកគាត់ដែលជាកម្មាភិបាលហ្នឹងពិតជាមិនដឹងពីការខ្វះខាតរបស់ប្រជាជននៅពេលដែលគាត់រស់នៅជាមួយប្រជាជនរាល់ថ្ងៃហ្នឹង ឬក៏គាត់មិនខ្វល់ដោយសារគាត់មិនមានលទ្ធភាពធ្វើ ឬក៏គាត់ពិតជាបានដឹងអំពីស្ថានភាពទាំងអស់នេះមែន ថាប្រជាជនមានការខ្វះខាត?

[១០:០៨:៤៨]

**ឆ៖** តាមធម្មតា ដូចមេកងស្រី ដឹងថាស្រីមានរដូវមានអីចឹង។ ចុះមនុស្សប្រុសៗមិនដឹងខ្យល់អីមែន មិនដឹងពីទុក្ខវេទនាកូនក្រុម កូនចៅហ្នឹងយ៉ាងម៉េចអី គឺមិនដឹងធ្វើម៉េច យកតែរួចខ្លួនរៀងៗខ្លួន មិនយល់ មិនដឹង មិនឮអីទេ ទាល់តែថាឈឺហ្នឹងទៅមិនរួចតែម្តង គ្រាន់ថាទៅមិនរួចបញ្ជូនទៅភូមិ គ្រាន់តែប៉ុណ្ណឹង។ បើថាឲ្យទៅមើល ទៅអើត ទៅឈ្ងោក ទៅសួរ ទៅនាំ ក៏គ្មានដែរ។

**ស៖** អ៊ីចឹងមានន័យថា តើខ្ញុំនិយាយត្រឹមត្រូវទេ កម្មាភិបាលដែលជាកម្មាភិបាលខ្មែរក្រហមនោះគាត់បានដឹងពីស្ថានភាពរបស់ប្រជាពលរដ្ឋ ប៉ុន្តែគាត់ធ្វើជាមិនដឹង មិនឮ?

**ឆ៖** គឺគេធ្វើមិនដឹងមិនឮទេ មិនដឹងអីតែម្តងទៅ។

**កញ្ញា សុង ឆវ័ន្ត៖**

ចាស សូមអរគុណលោកប្រធាន។ ខ្ញុំសូមផ្តល់វេទិកាបន្តទៅសហព្រះរាជអាជ្ញាអន្តរជាតិ។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ ឥឡូវនេះដល់ពេលសម្រាកហើយ អង្គជំនុំជម្រះប្រកាសសម្រាកចាប់ពីពេលនេះតទៅរហូតដល់ម៉ោងដប់កន្លះ សូមអញ្ជើញចូលវិញដើម្បីបន្តកិច្ចដំណើរការសវនាការ។

មន្ត្រីរដ្ឋបាលតុលាការសម្របសម្រួលផ្តល់កន្លែងសម្រាកនៅបន្ទប់រង់ចាំសម្រាប់ដើមបណ្តឹងរដ្ឋប្បវេណីរូបនេះនៅក្នុងអំឡុងពេលឈប់សម្រាក និងឲ្យអញ្ជើញគាត់រួមទាំងបុគ្គលិកអង្គការ ធី.ភី.អូ មកកាន់កន្លែងផ្តល់សក្ខីកម្មនៅក្នុងបន្ទប់សវនាការនេះនៅវេលាម៉ោងដប់កន្លះ។

សម្រាកចុះ!

**ក្រឡាបញ្ជី៖**

សូមអញ្ជើញក្រោកឈរ!

*(សវនាការសម្រាកពីម៉ោង ១០:១០ នាទី ដល់ម៉ោង ១០:៣៣ នាទី)*

[១០:៣៣:៥៨]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ។ ហើយជាបន្តទៅនេះ ផ្តល់វេទិកាជូនទៅតំណាងសហព្រះរាជអាជ្ញាអន្តរជាតិ ដើម្បីមានឱកាសតាំងសំណួរដេញដោលចំពោះដើមបណ្តឹងរដ្ឋប្បវេណីរូបនេះ។ ហើយសូមជម្រាបថា តំណាងសហព្រះរាជអាជ្ញាអន្តរជាតិ មានពេលសាមសិបនាទីក្នុងការតាំងសំណួរដេញដោលដើមបណ្តឹងរដ្ឋប្បវេណីរូបនេះ។

**លោក ឌេល លីសាក់៖**

សូមអរគុណប្រធាន។

**សួរដោយលោក ឌេល លីសាក់៖**

**ស៖** ជម្រាបសួរលោកស្រីដើមបណ្តឹងរដ្ឋប្បវេណី។ ខ្ញុំចង់សួរសំណួរមួយចំនួនត្រឡប់ទៅក្រោយបន្តិច ពាក់ព័ន្ធនឹងការងារលោកស្រីនៅទំនប់១មករា។ តើលោកស្រី គេមានកំណត់ផែនការអីដើម្បីឱ្យលោកស្រីជីកដីក្នុងមួយថ្ងៃៗហ្នឹង ត្រូវជីកទំហំប៉ុន្មាន<ម៉ែត្រគូប>ទេ? តើ<លោកស្រីនៅចាំទេថា>គេមានកំណត់កូតា គឺកំណត់ចំនួនប៉ុន្មានម៉ែត្រគូបអីក្នុងមួយថ្ងៃ<សម្រាប់កម្មករនៅក្នុងកងរបស់លោកស្រីដែរ>ទេ?

[១០:៣៥:២២]

**លោកស្រី ហ៊ុន សិត្ថានី៖**

**ឆ៖** ក្នុងការងារហ្នឹងគឺគេមានកំណត់ខ្លះ ព្រោះគេដាក់ស្រីពីរនាក់ ប្រុសម្នាក់។ ស្រីៗអ្នករែក ប្រុសៗអ្នកកាប់។ បីនាក់ហ្នឹង ដូចជាមួយម៉ែត្រ១,៥ ឬក៏២ម៉ែត្រគូបអ៊ីចឹង ក្នុងមួយថ្ងៃហ្នឹង។ គឺធ្វើយ៉ាងណាឱ្យយើង ឱ្យសម្រេចផែនការដែលគេដាក់។ ក៏ប៉ុន្តែមិនអាចទៅរួចទេ ព្រោះដីកន្លែងនោះរឹង សុទ្ធតែថ្ម ប្រឹងយ៉ាងណាក៏ទៅមិនរួចដែរ ប្រឹងអស់ពីចិត្ត ពីថ្លើមយ៉ាងណាក៏ទៅមិនរួចដែរ។ ខាងលើថ្មបាយក្រៀមហ្នឹង គឺកាប់ទៅចេញភ្លើង ដាក់ទៅដឹងតែចេញភ្លើងហើយ។ អ៊ីចឹង មេក្រុម មេកងហ្នឹង ដាក់ផែនការទៅភូមិ ឱ្យរកដែកត្បែងយកមកបុក យកចបតាសេះហ្នឹងយកមកកាប់។ ចបកាប់ គ្មានលទ្ធភាពធ្វើអី

កើតទេ។ ថ្មបាយក្រៀមខាងលើហ្នឹង កម្រាស់ប្រហែល១ម៉ែត្រ។ ផុតថ្មបាយក្រៀម ទៅដល់ថ្មផុយ ថ្មហ្នឹងរៀងផុយៗ ថ្មនុំង១ម៉ែត្រទៅទៀត ដល់ហើយដល់ថ្មដាហើយ មិនអាចធ្វើកើតទៀតទេ គឺគេចោះ គេដុតផ្លូន គេហៅផ្លូន មិនដឹងគេធ្វើយ៉ាងម៉េច ផ្លូនហ្នឹង ខ្ញុំដឹងថា គេចោះថ្មហើយ គេដាក់ដុតទៅ ផ្ទុះបែកថ្មហ្នឹង។ គេដាក់ផ្លូនហ្នឹង គេមិនដែលប្រាប់ថា “ហ៎! ថយចេញ” គេដាក់ផ្លូនទេ គេចង់ដាក់ថ្មើណា ដាក់ទៅ។ យើងដឹងខ្លួនរត់ឲ្យហើយ។ រត់ចេញពីកន្លែងហ្នឹងឲ្យហើយ ព្រោះគេដាក់ហ្នឹង គេមិនស្រែកថា “ហ៎! បងប្អូនអើយ គេដាក់ផ្លូនអី” គឺគេអត់ប្រាប់ទេ។ គេនឹកឃើញគេដាក់ទៅ យើងដឹងខ្លួនមក នាំគ្នារត់រៀងៗខ្លួនទៅ។ ខ្លះទៅ ក៏ផ្លោងត្រូវ បែកក្បាលទៅ។ បើផ្ទះគាត់មួយនៅក្បែរទំនប់១មករា នៅរហូតសព្វថ្ងៃហ្នឹង ដុំថ្មធំធ្លាក់ត្រូវដំបូលផ្ទះគាត់ហ្នឹង បាក់ឈើហ្នឹង ខ្ញុំសួរកូនគាត់ទៅ ថាប៉ាអត់ផ្លាស់ទេ គាត់ទុកៗមើល នៅដល់សព្វថ្ងៃហ្នឹង។ ខ្ញុំទៅជួបកូនគាត់។ សុទ្ធតែថ្មទៅបាតខាងក្រោមហ្នឹង គឺថ្មដាតែម្តង។

**ស៖** សូមលោកស្រីជម្រាបអង្គជំនុំជម្រះមើលថា <តើគេធ្វើយ៉ាងម៉េចដើម្បីតាមដាន និងកំណត់ដឹងថា លោកស្រីអាច>សម្រេច ឬ<មិនសម្រេចបរិមាណដែលគេកំណត់ឲ្យ? តើនរណាគេជាអ្នក>ត្រួតពិនិត្យ <ហើយគេធ្វើយ៉ាងម៉េចទើបដឹង>ថាលោកស្រីនេះ<>បានគ្រប់ចំនួនម៉ែត្រគូបដែលគេ<កំណត់ឲ្យ>? <>

[១០:៣៩:០៥]

**ឆ៖** គឺមេក្រុមក្នុងភូមិយើង មេក្រុមយើងហ្នឹង ដែលនៅជាមួយយើងហ្នឹង មេក្រុមហ្នឹង គឺគេអ្នកដើរពិនិត្យ ដាក់ផែនការឲ្យយើងហ្នឹង។ ព្រោះមេក្រុមហ្នឹងគេតែងតែហៅទៅប្រជុំ ឲ្យប្រជាជនហ្នឹងសម្រុកការងារហ្នឹង គឺថ្នាក់លើហ្នឹងគេតែងតែហៅទៅប្រជុំហើយ ប្រជុំថ្នាក់សង្កាត់ទៅ ថ្នាក់ស្រុកអ៊ីចឹងទៅ ឲ្យសម្រុកការងារហ្នឹង។ អ៊ីចឹងគេបានផែនការមក គេយកមករឹតយើងហ្នឹងទៀត។ ប្រឹងនាំគ្នាប្រឹងធ្វើម៉េចឲ្យបានហើយ ឲ្យបានលឿន ឲ្យបានឆាប់។ អ៊ីចឹង យើងត្រូវតែប្រឹងៗ ការងារណាស់ សម្លាប់មនុស្សចេះតែបន្តៗ។

**ស៖** លោកស្រីទើបតែនិយាយទីកន្លែងទី២ នៅជិតផ្លូវជាតិ ដែលលោកស្រីត្រូវជីកដីនៅទីនេះគឺ<មាន>ថ្ម <ផ្ទៃដី>រឹងពិបាកជីកណាស់។ ខ្ញុំចង់ដឹង<ឲ្យបានច្បាស់ថា>ទីតាំងនេះនៅកន្លែងណាដែរ? កាលពីម្សិលមិញ លោកស្រីថាពីការដ្ឋាននៅជិតផ្លូវជាតិហ្នឹង គឺនៅកំពង់ថ្ម។ <តើលោកស្រីអាចប្រាប់បានទេថា> លោកស្រីនៅខាងត្បូងស្ទឹងជីនិត ឬក៏លោកស្រីធ្វើការនៅខាងជើងស្ទឹងជីនិត នៅពេលដែលលោកស្រីថាធ្វើការនៅក្បែរផ្លូវជាតិនោះ?

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

**ឆ៖** ខ្ញុំមិនដឹងថាខាងជើងឬខាងត្បូងទេ ខ្ញុំដឹងថាបើមកពីកំពង់ថ្ម គឺនៅខាងឆ្វេងដៃៗ ប្រហែលជា១៥០ម៉ែត្រពីថ្នល់ជាតិ។ កន្លែងហ្នឹងមានដើមត្នោតៗហ្នឹងនៅដល់សព្វថ្ងៃហ្នឹង ខែចូលឆ្នាំ ខែភ្ជុំ ខ្ញុំទៅទីនោះមិនសូវខានទេ ខ្ញុំទៅមើលកន្លែងនោះ។ ខ្ញុំស្រណោះណាស់។

**ស៖** បើខ្ញុំយល់មិនច្រឡំទេ គឺលោកស្រី<បន្ត>ស្នាក់នៅ<កន្លែងដេកដដែល គឺនៅ>ក្បែរ<វត្ត>ត្រពាំងជ្រៃ ទោះបីជាលោកស្រីធ្វើនៅការដ្ឋានទី២ នៅជិតផ្លូវជាតិនោះក៏ដោយ។ លោកស្រីអាចជម្រាបជូនអង្គជំនុំជម្រះថាទី -- ការដ្ឋានការងារទី២ហ្នឹង មានចម្ងាយប៉ុន្មានគីឡូម៉ែត្រ<ធៀបនឹង>កន្លែងលោកស្រីទៅសម្រាន្តនោះ? ហើយលោកស្រីត្រូវ<ដើររយៈពេល>ម៉ោងប៉ុន្មានដើម្បីធ្វើដំណើរទៅធ្វើការនៅទីនោះ?

**ឆ៖** តាមខ្ញុំស្មាន ប្រហែលជា ថា៣គីឡូចុះ ដើរពីវត្តត្រពាំងជ្រៃហ្នឹងមក។

[១០:៤២:៥៧]

**ស៖** លោកស្រីក៏បាននិយាយផងដែរថា ពេលលោកស្រីធ្វើការនៅការដ្ឋានទី២ លោកស្រីត្រូវក្រោកពីសម្រាន្តនៅម៉ោងបីព្រឹក ទើបមានពេលគ្រប់គ្រាន់ដើម្បី<ដើរទៅដល់ទីនោះ>។ នៅពេលដែលលោកស្រីក្រោកពីដេកនៅម៉ោងបីព្រឹក ហើយត្រូវដើរចម្ងាយ៣គីឡូអ៊ីចឹងគេមានផ្តល់អាហារអីឲ្យដែរទេ<មុនពេលលោកស្រីចាប់ផ្តើមធ្វើការ>ហ្នឹង?

**ឆ៖** អើយ! ពុទ្ធោអើយពុទ្ធោ! ឲ្យតែពេលបាយមានគ្រប់គ្រាន់មានអីស្រស់ស្រូបព្រលឹមឡើងគឺគ្មានទេ ពោះទទេៗសុទ្ធ ឃ្លានណាស់ ប៉ុន្តែមិនដឹងធ្វើយ៉ាងម៉េច។ មានអី មានរបបអី គ្មានទេ។ បើចុងភៅគេដួសបាយក្តាំងដាក់ហាលហ្នឹងទៅ លបៗទៅលួចមួយដុំដាក់ហោប៉ៅអាវមក។ មានមិត្តភក្តិអ៊ីចឹងកាច់ចែកគ្នាទៅ ប៉ុនៗមេដៃហ្នឹង បៀមៗក្នុងមាត់ហ្នឹងទៅ។ ហ្នឹងហើយស្រស់ស្រូបពេលព្រឹកបានដោយលួចគេហ្នឹង បើថាឲ្យមានរបបគឺគ្មានទេ គ្មានសោះហើយ។ ឲ្យតែពេលបាយ មានបាយឲ្យហូបឆ្អែត មានម្ហូបហ្នឹងទៅបានហើយ របបព្រឹកគ្មានដែលស្គាល់ជាតិទេ តាំងពីដាច់៧៥ រហូតនោះ។

**ស៖** បើខ្ញុំយល់មិនច្រឡំទេ គឺគេឲ្យលោកស្រី<ត្រូវ>ក្រោកពីសម្រាន្តនៅម៉ោងបីព្រឹក ដើម្បីដើរចម្ងាយ៣គីឡូម៉ែត្រទៅការដ្ឋានការងារ រួចហើយបន្តធ្វើការរហូតដល់ម៉ោងដប់មួយ<ថ្ងៃត្រង់> ទើបគេឲ្យ<សម្រាក>ហូបបាយថ្ងៃត្រង់។ <តើខ្ញុំយល់>អ៊ីចឹង<ត្រឹមត្រូវដែរទេ>?

**ឆ៖** ចាស នេះជារឿងពិត មិនកុហកទេ គឺគ្មានអីញុំាទេពេលព្រឹកនោះ។ ដូចខ្ញុំជម្រាបអ៊ីចឹងបើបានឃើញចុងភៅហាលបាយក្តាំង អរជាងបានអីទៀត មាសប៉ុនដួងទុំក៏មិនស្មើដែរ។ លបៗទៅលួច

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

យកបន្តិចយកមកដាក់ហោប៉ៅអាវទៅ។ បានបៀមទៅ ថ្ងៃណាមានក៏មាន ថ្ងៃណាអត់ក៏អត់ ប៉ុន្តែភាគច្រើនអត់ហើយ មានហ្នឹងម្តងម្យាមទេ។ មិនដែលបានសល់បាយកកអីទុកលាក់ទុកអីកើត បើគេចែកមួយល្មមៗហ្នឹង។ បើបានសល់បាយកកម្តងៗហ្នឹង ជាងព្រះឥន្ទ្រឲ្យអីទៅទៀតលោកអើយ! ពូតមកដាក់ហោប៉ៅអាវ ធុំក្លិនផ្អូមម៉េចក៏ចេះតែលេបទៅ ឲ្យតែបានចូលពោះ។

**ស៖** លោកស្រីក៏បាននិយាយផងដែរថា កន្លែងដែលលោកស្រី<ដេក>ហ្នឹងគឺនៅជិត<វត្ត>ត្រពាំងជ្រៃ។ តើ<លោកស្រីអាចប្រាប់បានទេថា តើ>វត្តមួយនេះ<គេ>ប្រើប្រាស់ធ្វើជាកន្លែងអីដែរ<ក្នុងសម័យខ្មែរក្រហម>?

[១០:៤៧:១១]

**ឆ៖** កន្លែងវត្តហ្នឹង គឺគេលែងគោរពបូជាអីហើយ ដាក់ចោលនៅនុ៎ង។ គេឲ្យខាងឃុំបារាយណ៍ហ្នឹង គឺសម្រាកនៅនុ៎ងទាំងអស់ មួយឃុំបារាយណ៍ហ្នឹង គឺចល័តហ្នឹងទៅសម្រាកនៅកន្លែងនុ៎ង។ គេដាក់មុំជុំគ្នានៅកន្លែងនុ៎ង។ ទោះបីជារើកន្លែងធ្វើការទៅពីរបីកន្លែងទៀត ក៏គេឲ្យនៅតែគេងហ្នឹងដែរ គេមិនឲ្យយើងដូរទៅជិតកន្លែងទេ គឺគេដាក់មុំហ្នឹងរហូត ពីដើមទីហ្នឹងរហូតដល់ចប់ការដ្ឋាន។ គឺនៅនឹងវត្តត្រពាំងជ្រៃហ្នឹង។

**ស៖** នៅពេលដែលលោកស្រីធ្វើការនៅទំនប់ ១មករា ៗ តើនៅទីនោះមានព្រះសង្ឃនៅវត្តនោះទេ? តើគេអនុញ្ញាតឲ្យ<ប្រជាជន>គោរព<ប្រណិប័តន៍>ព្រះពុទ្ធសាសនា<នៅទីនោះ ដែរ ឬ>ទេ?

**ឆ៖** មិនមានសោះៗ តាំងពីខ្ញុំដាច់៧៥ទៅ រហូតទៅដល់ខ្ញុំទៅនៅបារាយណ៍ហ្នឹង ខ្ញុំស្គាល់មិត្តភក្តិប្រុសម្នាក់កាលពីតូចៗរៀនជាមួយគ្នា ឪពុកខ្ញុំធ្លាប់បង្រៀននៅបារាយណ៍ហ្នឹង។ ម្នាក់ហ្នឹងគេឈ្មោះ ណូ គេបួសជាសង្ឃ គឺនៅតែមួយអង្គឯងទេ សង្ឃហ្នឹងគឺសង្ឃមានកាំភ្លើង នៅជាសង្ឃតែមានកាំភ្លើងនៅនឹងខ្លួនទៀត ហើយគេកំណត់កាលឲ្យសឹក។ ខ្ញុំជួបអង្គាល់នុ៎ងគេនៅជាលោក ខ្ញុំឃើញគេស្លៀកស្បង់ឈ្មោះ ណូ នៅបារាយណ៍ហ្នឹង។ ណូ ហ្នឹងឯងជាកូនគ្រូពេទ្យ ឈ្មោះពេទ្យ សាវ៉ាត។ គេរៀនជំនាន់ខ្ញុំហ្នឹង តាំងខ្ញុំនៅតូចៗដូចគ្នាហ្នឹង តែខ្ញុំស្គាល់គេច្បាស់ ព្រោះពេទ្យ សាវ៉ាត និងឪពុកខ្ញុំហ្នឹងគាត់ស្គាល់គ្នាស្និទ្ធស្នាល យើងខស្សាហ៍ជួបមុខគ្នា ហើយរៀនជាមួយគ្នាទៀត បានខ្ញុំស្គាល់ហ្នឹង។ ព្រោះលោក ណូ ហ្នឹងសឹកក្រោយគេបង្អស់ ឆ្នាំ -- ដើមឆ្នាំ៧៦ហ្នឹងសឹក។ ដឹងថា មានកាំភ្លើងហ្នឹង ព្រោះខ្ញុំមានមិត្តភក្តិនៅហ្នឹងគេអ្នកស្រុកចាស់ គេប្រាប់។ គេថា លោក ណូ ហ្នឹងបួសមែនតែមានកាំភ្លើងនៅហ្នឹងខ្លួន គេប្រាប់ថាអ៊ីចឹង។ ខ្ញុំមិនដែលបានឃើញទេ គ្រាន់តែមិត្តភក្តិប្រាប់ ថាគេជិតឲ្យសឹកហើយ។

**ស៖** លោកស្រីដើមបណ្ដឹងរដ្ឋប្បវេណី តើលោកស្រីមានជម្រើសខ្លួនឯងថា ត្រូវតែទៅធ្វើការនៅទំនប់១មករា ឬក៏មិនត្រូវទៅធ្វើការនៅទីនោះបានទេ?

[១០:៥០:៥៧]

**ឆ៖** គឺមិនអាចមានជម្រើសទេ។ ពាក្យថា "ចាត់តាំង" មួយម៉ាត់ហ្នឹងគឺខ្លាំងក្លាហើយ។ គេអ្នកស្រុកចាស់ គេហ៊ានតវ៉ា ចំណែកខ្ញុំអ្នកស្រុកថ្មីហ្នឹង អ្នកថ្មីហ្នឹងគឺគ្មាន គឺគ្មានតែម្ដង។ តែតម្រូវឲ្យទៅ គឺទៅដោយមិនប្រកែកបាន ដែលយើងគ្មានសិទ្ធិនោះណា គ្មានសិទ្ធិអីទេ គ្មានសោះសូន្យតែម្ដង។ ពិបាកចិត្តហ្នឹងបានត្រឹមតែយំហ្នឹង បានត្រឹមតែគ្រាំគ្រាក្នុងខ្លួន។ តឹងទ្រូងប៉ុនណា ដែលតវ៉ាមិនបាន និយាយមិនកើត អស់លោកដឹងហើយពិបាកប៉ុនណា ក្នុងទ្រូង ក្នុងខ្លួនហ្នឹងវាប៉ុនណាទៅ។

**ស៖** ខ្ញុំសូមសួរលោកស្រីមួយចំនួនអំពីឪពុករបស់លោកស្រី។ លោកស្រីថាបានដឹងពីការចាប់ខ្លួនឪពុករបស់លោកស្រីតាមរយៈពីបងប្អូនលោកស្រី គេចាប់ខ្លួនហើយគេយកទៅសម្លាប់ចោល។ <ខ្ញុំសូមសួរលោកស្រី> នៅក្នុងពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីរបស់លោកស្រី គឺឪពុកលោកស្រីគេយកទៅសម្លាប់ចោលនៅវត្តបារាយណ៍ជាន់ដែក។ <តើបងប្អូន>លោកស្រី<មានប្រាប់លោកស្រីដែរទេថា តើ>ធ្វើម៉េច<ពួកគេ>ដឹងថា ឪពុកលោកស្រីត្រូវគេយកទៅសម្លាប់នៅឯវត្តបារាយណ៍ជាន់ដែក<ហ្នឹង>?

**ឆ៖** ធម្មតា កន្លែងគុក កន្លែងសម្លាប់មនុស្ស គឺតែងតែប្រជាជនដឹង។ ខ្ញុំដឹង ដឹងតាមរយៈគេប្រាប់បារាយណ៍ជាន់ដែកហ្នឹងជាគុកធំ។ គេចាប់ពីកន្លែងណាៗទៅ មិនមែនចាំបាច់តែនៅ ១មករាទេ អ្នកទោសធ្ងន់ៗ គឺគេយកទៅសម្លាប់នៅទីនោះ។ បានដឹងថាគេយកទៅសម្លាប់ទីនោះ ព្រោះគេមានកន្លែងគេហ្នឹងស្រាប់ហើយ។ ប្អូនខ្ញុំមកប្រាប់ហ្នឹងថា "បងបាត់ប៉ាហើយ គេមុខជាយកទៅសម្លាប់នៅ បារាយណ៍ជាន់ដែក ហ្នឹងឯងគេគ្មានយកទៅណាទេ។ ប៉ាយើងបាត់មួយយប់ហើយ មិនឃើញគាត់ត្រឡប់មកវិញទេបង"។ ពេលនោះ យំអត់ចេញទេ សូម្បីតែទឹកភ្នែកមួយដំណក់ក៏អត់មានស្រក់កើតដែរ។ លួងប្អូន "អូនឯងទៅកន្លែងវិញ ខំធ្វើការណាអូនណ៎ា ធ្វើម៉េចសុំម៉ារស់ អូនឯងទ្រាំទៅ"។ ពេលនោះ ធ្វើម៉េចក៏យំមិនចេញ យំអត់ចេញសោះ។ ខ្ញុំស្រែកយំបាន នៅពេលដែលមានភ្លៀងធ្លាក់ធំទេ ដែលខ្ញុំស្រែកយំ គឺខ្ញុំយំឲ្យអស់ពីក្នុងខ្លួន។ ខ្ញុំយំមួយទំហឹងហើយ ព្រោះខ្ញុំគ្មានពេល គ្មានសិទ្ធិយំទេ ទាល់តែភ្លៀងធំ ផ្គរលាន់ក្អុងៗបានខ្ញុំស្រែកហើយ ពេលណាក៏ខ្ញុំស្រែកយំដែរ ឲ្យតែភ្លៀង។ ខ្ញុំនឹកឃើញរឿងទាំងអស់។ នៅមុខគេខ្ញុំគ្មានសិទ្ធិទេ កុំឲ្យគេថា ខ្ញុំនឹងសតិអារម្មណ៍ គិតអី។ អ៊ីចឹង ខ្ញុំត្រូវតែទ្រាំក្នុងខ្លួន ទ្រាំហ្នឹងពិបាកណាស់

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

ទ្រាំហ្នឹងពិបាកមែនទែន សឹងរហែកដើមទ្រូងងាប់ភ្លាមៗហើយ។ ចុកអស់ហើយក្នុងខ្លួន នេះគឺការអត់ធ្មត់។ ដល់ពេលភ្លៀងខ្លាំងហ្នឹង យើងបានស្រែក បានយំ នឹកឃើញប៉ា នឹកឃើញម៉ាក់ នឹកឃើញប្អូនដែលបែកបាក់គ្នា។ ហ្នឹងបានយើងមានសិទ្ធិយំៗ កុំឲ្យគេឮ។

[១០:៥៦:០០]

**ស៖** លោកស្រីដើមបណ្ដឹងរដ្ឋប្បវេណី លោកស្រីដែលបានដឹងទេថា មូលហេតុអ្វីបានជាគេចាប់ឪពុកលោកស្រីយកទៅសម្លាប់ចោល?

**ឆ៖** ពេលនោះ គេជាមាត់ទិព្វហើយ គេចង់សម្លាប់អ្នកណាស្រេចតែចិត្តគេ។ ខ្ញុំមើលទៅឪពុកខ្ញុំហាក់ដូចជាគ្មានកំហុសអីទេ ព្រោះឃើញគាត់ទៅរែកដីរាល់តែថ្ងៃ មិនដែលខានថ្ងៃណាទេ។ មិនឃើញគាត់សម្រាកទេ ព្រោះប្ដូងនៅជិតគ្នា។ មិនដឹងជាកំហុសរឿងអី ខ្ញុំរកមូលហេតុមិនឃើញទេ។ ឪពុកខ្ញុំប្រឹងណាស់ ព្រោះគាត់ជាគ្រូបង្រៀន គាត់ដឹងថាគាត់មានខ្លួន គាត់ប្រឹងធ្វើការ គេរុញទៅណាក៏គាត់ទៅនុំង គាត់មិនដែលប្រកែកនឹងគេទេ។ ចុះហេតុអីយកគាត់ទៅសម្លាប់មិនប្រាប់ពីមូលហេតុ គាត់មិនទាំងដឹងខ្លួនផង។ គេហៅទៅ ថាហៅទៅលីឈើ គេហៅទៅឲ្យជួយលីឈើ ទៅបាត់រហូតៗ។ ចាំមើល១ថ្ងៃ ២ថ្ងៃមិនឃើញ ៣ថ្ងៃ ៤ថ្ងៃក៏មិនឃើញ បាត់រហូត។ អ្នកដែលគេដឹង គេប្រាប់ហើយថា គេចាប់ទៅហើយ គឺមិនរួចខ្លួនទេ គេយកទៅបារាយណ៍ជាន់ដែកហ្នឹងឯង ទើបតែដាច់មកទេបានខ្ញុំឃើញរណ្ដៅនៅកន្លែងនុំងច្រើនណាស់។ រណ្ដៅជាប់ៗគ្នាហ្នឹង សុទ្ធតែឃើញតែក្បាល ឃើញតែឆ្អឹង។ បានខ្ញុំជឿជាក់ថាឪពុកខ្ញុំប្រាកដជាស្លាប់នៅទីនោះហើយ គ្មានយកទៅណាទេ។

**ស៖** តើលោកស្រីអាចជម្រាបជូនអង្គជំនុំជម្រះបានទេថា ឪពុកលោកស្រីកាលពីរបបមុនៗ គឺរបបលន់ នល់ គាត់<ជាគ្រូ>បង្រៀននៅឯណាដែរ?

**ឆ៖** គាត់នៅធ្វើការក្នុងវិទ្យាល័យព្រះសីហនុកំពង់ចាម គាត់កាន់ខាងរោងជាង។ គាត់ធ្វើការរហូតៗទាល់តែដាច់៧៥ហ្នឹងឯង។

[១០:៥៩:២០]

**ស៖** តើលោកស្រីដឹងថា ឪពុកលោកស្រីនេះជាអ្នកដែល<>គាំទ្រដល់ចលនាខ្មែរក្រហម ឬក៏ជាមនុស្សម្នាក់ដែលប្រឆាំងនឹងចលនាខ្មែរក្រហម?

**ឆ៖** មិនទេ គាត់មិនគាំទ្រសោះឡើយ។ គាត់មិនចូលចិត្តទេរបបកុម្មុយនីស្តនោះ។ ចង់អ្នកណាមកឃោសនា បង្គាប់បញ្ជាគាត់យ៉ាងម៉េចក៏ដោយ គាត់ស្រឡាញ់ប្រពន្ធ ស្រឡាញ់កូនគាត់ណាស់ គាត់

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

មិនចេញទៅណាឆ្ងាយទេ ដាច់ខាតគឺគាត់មិនចេញ។ គាត់មិនគាំទ្រទេ។ គាត់ដឹងថា ខាង លន់ នល់ ហ្នឹង ប្រាកដជាចាញ់ខ្មែរក្រហមហើយ ព្រោះខ្មែរក្រហមមកហើយ។ មុន១៧មេសា មួយថ្ងៃហ្នឹង គាត់ជាមួយ លោក អ៊ុំ ជួន នាយកវិទ្យាល័យព្រះសីហនុហ្នឹងឯង គាត់ប្រុងមកសម្លាប់កូនចៅចោលអស់ ហើយគាត់ សម្លាប់ខ្លួនឯង។ គាត់ខ្លាចខ្មែរក្រហមធ្វើបាបគាត់។ តែម្ដាយខ្ញុំអង្វរ ថាកុំឲ្យធ្វើអ៊ីចឹង កុំឲ្យសម្លាប់កូន ប្រពន្ធ ទុកទៅ ក្រែងលោកូនយើងមានរស់ខ្លះ។ បើបងសម្លាប់កូន សម្លាប់ប្រពន្ធ សម្លាប់ខ្លួនឯង បាន ប្រយោជន៍អី ទុកទៅ កុំធ្វើអ៊ីចឹង។ ម្ដាយខ្ញុំ សំពះអង្វរ យំ ថាកុំឲ្យគាត់ធ្វើអ៊ីចឹង។ គាត់និយាយគ្នា ប្រហែលជាពីរម៉ោងជាង ខ្ញុំលបនៅចាំស្ដាប់គាត់នៅមាត់ទ្វារ ខ្ញុំភ័យណាស់ ភ័យខ្លាចប៉ាសម្លាប់កូនៗ ហ្នឹងណ៎ា ខ្ញុំថាឲ្យតែប៉ាហៅឲ្យចូលបន្ទប់អី អត់ទេ ខ្ញុំនាំបងប្អូនខ្ញុំរត់ហើយ។ គាត់សន្យាគ្នាមកសម្លាប់ ប្រពន្ធកូន គាត់ខ្លាចកុម្មុយនីស្ដណាស់។ ចុងក្រោយគាត់មកស្លាប់នឹងខ្មែរក្រហមសម្លាប់។ មិនគួរនឹក ឃើញណ៎ា។

[១១:០១:៣៣]

**ស៖** សូមអរគុណលោកស្រីដែលបានចែករំលែកព័ត៌មាននេះ។ នៅពេលដែលលោកស្រីធ្វើការ នៅទំនប់១មករា តើមានពេលណាមួយនោះ មានកម្មាភិបាលខ្មែរក្រហមនៅស្រុកបារាយណ៍ ឬក៏នៅការ ដ្ឋានការងារតែម្ដង ត្រូវបានគេដកចេញ ឬក៏បាត់ខ្លួន ហើយត្រូវបានដាក់ជំនួសដោយកម្មាភិបាលមកពី ភូមិភាគនិរតីទេ? លោកស្រីមានចាំចំណុចនេះទេ?

**ឆ៖** កាលនោះគឺខ្ញុំអត់ដឹងទេ។ គ្មានពេលណាទៅចាំស្ដាប់រឿងរ៉ាវអីទេ គិតតែពីការងារ ធ្វើម៉េច ឲ្យខ្លួនហ្នឹងឯងបានទៅដល់កន្លែង បានសម្រាកយកកម្លាំងធ្វើការស្អែកទៀត។ អ៊ីចឹង រឿងរ៉ាវអីផ្សេងៗគឺ មិនដឹង មិនឮទាំងអស់។ បើអ្នកមូលដ្ឋានប្រហែលជាគេដឹង។ ចំណែកយើងអ្នកថ្មី មិនដឹងទេ។

**លោក ឌេល លីសាក់៖**

លោកប្រធាន ខ្ញុំសូមការអនុញ្ញាតបង្ហាញឯកសារមួយជូនទៅសាក្សី និងបញ្ចាំងនៅលើអេក្រង់ គឺរូបថត<មួយសន្លឹក មាននៅក្នុងពាក្យសុំតាំងខ្លួនជា>ដើមបណ្ដឹងរដ្ឋប្បវេណី គឺឯកសារ E3/4790 ត្រង់ ERN ជាភាសាខ្មែរ<00582093>។ បាទ បើលោកប្រធានអនុញ្ញាត គឺខ្ញុំសូមផ្ដល់ឯកសារជា ក្រដាស<ថតចម្លង ហើយ>ជូនទៅសាក្សីមើល និងបញ្ចាំងនៅលើអេក្រង់កុំព្យូទ័រផង។

**ប្រធានអង្គជំនុំ៖**

បាទ អង្គជំនុំជម្រះអនុញ្ញាត!

ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។

**សួរដោយលោក ឌេល លីសាក់៖**

**ស៖** លោកស្រីដើមបណ្តឹងរដ្ឋប្បវេណី សូមលោកស្រីមើលរូបថតនៅលើអេក្រង់កុំព្យូទ័រនេះ។ ខ្ញុំចង់ឲ្យលោកស្រីរៀបរាប់ជាទូទៅសិនថា តើរូបអ្នកនៅក្នុងរូបថតទាំងអស់នេះជាអ្នកណា? លោកស្រីចាប់ផ្តើមពីខាងឆ្វេងមកមុនមក ពីកុមារីម្នាក់ដែល<កំពុងឈរ>។

**លោកស្រី ហ៊ុន សិត្ថានី៖**

**ឆ៖** ចាស រូបកាន់បាច់ផ្កាហ្នឹង គឺរូបនាងខ្ញុំផ្ទាល់។ ហើយអង្គុយក្មេងប្រុសហ្នឹង គឺប្អូនប្រុសបន្ទាប់ខ្ញុំឈ្មោះ ហ៊ុន សុជីវ៉ាត ហ្នឹង។ ហើយប្អូនស្រីដែលអង្គុយដែរហ្នឹងគឺ ហ៊ុន កុលធីតា ហើយក្មេងអង្គុយខាងលើហ្នឹង ហើយក្មេងអង្គុយខាងលើហ្នឹងគឺ ប្អូនប្រុសខ្ញុំ សុខកុមារ ដែលស្លាប់ក្នុងជំនាន់ ប៉ុល ពត ហ្នឹង។ ហើយជាប់ប្អូនខ្ញុំហ្នឹង គឺម្តាយខ្ញុំ និងឪពុកខ្ញុំ។ កាលណោះ គាត់ទើបមានកូនបួននាក់ទេ ក្រោយមកគាត់មានកូន ប្រាំនាក់ទៀត ទាំងអស់ប្រាំបួននាក់ ទាំងខ្ញុំ។

**ស៖** ទារកមួយនេះ នៅអង្គុយលើតុដែល -- តើឈ្មោះ <ហ៊ុន> សុខកុមារ ដែលលោកស្រីនិយាយថាស្លាប់នៅឯមន្ទីរពេទ្យក្រោយពេលគេយកឪពុកលោកស្រីបាត់ទៅហ្នឹងមែនទេ?

**ឆ៖** ចាស គឺរូបហ្នឹងហើយ សុខកុមារ ហ្នឹងហើយ។

**ស៖** ពាក់ព័ន្ធទៅនឹងម្តាយលោកស្រីវិញម្តង លោកស្រីបញ្ជាក់ក្នុងពាក្យសុំរបស់លោកស្រីថា នៅថ្ងៃទី៧ ខែកក្កដា ១៩៧៧ លោកស្រីបានទទួលព័ត៌មានថាម្តាយរបស់លោកស្រី ហើយនិងបងប្អូនប្រុសស្រីប្រាំនាក់ ត្រូវបានខ្មែរក្រហមសម្លាប់ចោល។ អ្នកទាំងអស់នោះត្រូវបានគេ ទម្លាក់ចូលក្នុងអណ្តូង <នៅចម្ការ>អណ្តូងនោះ។ <សំណួរដំបូងខ្ញុំគឺ> តើ<នៅពេលដែល>ពួកគាត់ទាំងអស់ហ្នឹង <ត្រូវគេនាំចេញ តើពួកគាត់រស់នៅ និងធ្វើការនៅឯណាដែរ? ឬក៏ពួកគាត់នៅធ្វើការ>នៅឯទំនប់១មករា ដូចលោកស្រីដែរ ឬក៏អត់ទេ?

[១១:០៧:០២]

**ឆ៖** ម្តាយខ្ញុំនិងប្អូនៗ គឺនៅហ្នឹងភូមិទេៗ។ កាលណោះគេយកប៉ាខ្ញុំទៅសម្លាប់បាត់ហើយ គឺនៅតែគាត់ទេ ហើយនិងប្អូនតូចៗហ្នឹង។ ថ្ងៃនោះ ថ្ងៃដែលគេហៅគាត់ប្រជុំ គាត់បានឲ្យប្អូនប្រុសខ្ញុំម្នាក់ទៅតាមខ្ញុំ ទៅប្រាប់ថា ម៉ាក់ឲ្យហៅទៅ -- ព្រោះខ្ញុំនៅជាប់ភូមិគាត់ហ្នឹង បារាយណ៍តូចហ្នឹង បារាយណ៍ភូមិធំបានភូមិខ្ញុំ រំលងមួយភូមិ។ ទៅតាមថ្នល់ "បងៗម៉ាក់ឲ្យហៅ" គេប្រជុំរួចហើយគាត់មកផ្ទះហ្នឹងឃើញខ្ញុំទៅ ប្រាប់ខ្ញុំថា "កូនទៅរៀបអីវ៉ាន់មកទៅជាមួយម៉ាក់"។ ខ្ញុំនឹកឃើញក្នុងខ្លួនថា គេអត់មានហៅ

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

ខ្ញុំប្រជុំទេ "ហើយគេឲ្យម៉ាក់ឯងទៅណា?" "គេថាឲ្យទៅនៅដីថ្មី" ស្រណោះណាស់ គាត់ប្រមូលតាំងពីគ្រាប់ត្រសក់ គ្រាប់ត្រប់ គ្រាប់ល្ពៅ ឮថាគេឲ្យទៅនៅដីថ្មី ខំប្រមូលគ្រាប់ពូជយកទៅដាក់ដាំ។ ខ្ញុំនឹកឃើញរឿងជម្លៀសឡើងខ្ញុំឆ្អែតណាស់។ ខ្ញុំថា៖ "ម៉ាក់ បើគេហៅម៉ាក់ប្រជុំ ម៉ាក់ទៅមុន រួចចាំម៉ាក់សរសេរសំបុត្រផ្ញើមកខ្ញុំវិញថាម៉ាក់នៅកន្លែងណា ខ្ញុំទៅលេង។ ខ្ញុំគេអត់ហៅប្រជុំទេ ម៉ាក់ទៅមុន"។ ខ្ញុំរត់ទៅផ្ទះប្រមូលអំបិល ប្រមូលប្រេងកាតដែលខ្ញុំលាក់ទុកហ្នឹង យកមកឲ្យគាត់ ហើយប្រាប់គាត់ថា "ម៉ាក់ទៅមុន" គាត់ថា "ម៉ាក់បែកប៉ា បែកប្អូន បែកខ្ញុំទៀត ម៉ាក់អីក៏ពិបាកម្ល៉េះ ម៉ាក់ចង់ឲ្យកូនទៅជាមួយ កូនធំជាងគេ"។ ខ្ញុំសុំគាត់ "ម៉ាក់សុំអង្វរ ម៉ាក់ទៅចុះ ហើយម៉ាក់សរសេរសំបុត្រមកឲ្យកូន" គ្មានដឹងថាទៅស្លាប់ទេ។ ដល់ពេលម៉ោងប្រហែលជាដប់អីហ្នឹង រទេះគេចេញទៅ នៅក្នុងភូមិខ្ញុំហ្នឹងក៏មានដឹកទៅដែរ យកចេញទៅហ្នឹង។ ខ្ញុំនៅហ្នឹងភូមិខ្ញុំធ្វើអង្ករ។ ពូមួយឈ្មោះ ពូយ៉ែម១ហ្នឹងគាត់ដឹក -- គិតទៅដឹកទៅមួយយប់។

[១១:១០:០០]

ខ្ញុំចាំច្បាស់ថា ថ្ងៃ៧ ខែ៧ ឆ្នាំ៧៧ ខ្ញុំចាំច្បាស់ណាស់។ យកទៅហ្នឹង ទៅបាត់មួយយប់ ទាំងអ្នកដឹកទៅទាំងអីហ្នឹង។ ពូនៅភូមិខ្ញុំដែលគាត់ដឹកអ្នកជម្លៀសទៅដែរហ្នឹង ខ្ញុំចម្លែកគាត់ គាត់ជាមនុស្សស្លូត គាត់ធ្លាប់ធ្វើប្រធានភូមិ។ ត្រឡប់មកវិញល្អីកញ្ចើដែលនៅក្រោមកន្លែងសហករណ៍ហ្នឹងឯង គាត់ដឹកគោដើរជាន់ល្អីជាន់កញ្ចើ។ ខ្ញុំចាប់អារម្មណ៍ភ្លាម ខ្ញុំថា "ហឺយ! ពូ មិនបានអីក៏ប្រាប់ថាយកល្អី យកកញ្ចើចេញទៅ" ម៉េចបានគាត់ដឹកគោទៅជាន់នៅលើល្អីកញ្ចើទាំងអស់ហ្នឹងអីចឹង អីក៏ចម្លែកម្ល៉េះ នឹកក្នុងខ្លួន១ឯង។ ស្រាប់តែល្ងាច មិត្តភក្តិខ្ញុំម្នាក់ឈ្មោះ សារឿន គេ១អ្នកថ្មី តែម៉ែឪគេអ្នកចាស់នៅនោះ។ គេយំមកឱបខ្ញុំ គេថា "នីអើយ! ម៉ាក់នីដែលទៅនឹងគេយកទៅសម្លាប់នៅចម្ការអណ្តូងអស់ហើយ"។ ខ្ញុំមិនជឿទេ ខ្ញុំមិនជឿថាយកមនុស្សទៅសម្លាប់ចោល ខ្ញុំមិនជឿទាល់តែសោះ ព្រោះមនុស្សច្រើនណាស់។ ខ្ញុំថា "សម្លាប់ម៉េចទេ បើទៅពីរបីនាក់ បួនប្រាំនាក់ អាហ្នឹងខ្ញុំ បើទៅរាប់សិបរទេះអីចឹងខ្ញុំមិនជឿទេ" ខ្ញុំមិនជឿមែន។ ទាល់តែកន្លងមកបានប្រហែលជា៥ថ្ងៃ ខ្ញុំឃើញខោអាវប្អូនខ្ញុំ អាវប៉ាក់ដែលម៉ាក់កាត់ឲ្យធ្វើជាអាវទ្រនាប់ គាត់ឲ្យមកខ្ញុំមួយ ឲ្យទៅប្អូនស្រីខ្ញុំមួយ ខ្ញុំឃើញគេហាលអាវ អាវទ្រនាប់ហ្នឹងបានខ្ញុំដឹងប្រាកដ។ ខ្ញុំថាខោអាវហ្នឹងជាខោអាវប្អូនរបស់ខ្ញុំហើយ បានខ្ញុំជឿ១ថា ស្លាប់ហើយ ស្លាប់ទាំងអស់គ្នាហើយ។

**ស៖** លោកស្រីដើមបណ្តឹងរដ្ឋប្បវេណី ខ្ញុំសូមឲ្យលោកស្រីបញ្ជាក់តែចំណុចមួយទៀតទេ។ ប្អូន

ប្រុសប្អូនស្រីលោកស្រីដែលអង្គុយនៅលើកៅអី ក្នុងរូបថតដែលលោកស្រីកំពុងពិនិត្យមើលនេះ មានប្អូនប្រុសមានឈ្មោះ សុជីវ៉ាត និងកុលធីតា។ តើទាំងពីរនាក់នេះធ្វើការជាមួយនឹងឪពុកលោកស្រីនៅទំនប់១មករា ឬក៏អត់? តើប្អូនប្រុសប្អូនស្រីទាំងពីរនាក់នេះ គឺស្លាប់នៅក្នុងរបបខ្មែរក្រហមដែរឬក៏អត់?

[១១:១៣:១២]

**ឆ៖** ចាស ពីរនាក់ហ្នឹងគឺទៅជាមួយម៉ាក់ខ្ញុំទាំងអស់ គឺគេយកទៅថ្ងៃ៧ ខែ៧ ឆ្នាំ៧៧ហ្នឹង។ ត្រឡប់មកពីការដ្ឋានវិញ គេដឹករទេះទៅហ្នឹង គេឲ្យយកអីវ៉ែអីវ៉ាន់ គេរៀបចំហ្នឹងគឺស្អាតណាស់។ ថាឲ្យទៅដីថ្មី យើងចង់បានអីយកទៅ អីវ៉ាន់ហ្នឹងគេឲ្យដាក់យកទៅទាំងអស់។ ប្រាប់ឲ្យរកពូជអីៗយកទៅទុកដាំទៀត។ ហើយខ្ញុំបានដឹងពី ពូយ៉ែម ហ្នឹង គាត់ថា និយាយប្រាប់អ្នកស្រុកហ្នឹង អ្នកស្រុកមកប្រាប់ខ្ញុំថា គេយកទៅសម្លាប់ហ្នឹង គេសុទ្ធដាក់មីក្រូ គេមិនឲ្យឮសំឡេងស្រែក គេចាក់មីក្រូ។ សម្លាប់នៅខាងចម្ការអណ្តូង បររទេះវង់ទៅខាងចម្ការអណ្តូងវិញ។

**ស៖** លោកស្រីដើមបណ្តឹងរដ្ឋប្បវេណី សូមអរគុណច្រើនដែលឆ្លើយទៅនឹងសំណួររបស់ខ្ញុំ<នូវរឿងរ៉ាវដ៏>លំបាក<នេះ>។

**លោក ឌេល លីសាក់៖**

លោកប្រធាន ខ្ញុំអស់សំណួរហើយ។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ ហើយជាបន្តទៅនេះអង្គជំនុំជម្រះផ្តល់វេទិកាជូនទៅក្រុមមេធាវីការពារក្តី ដែលដំបូងនេះប្រគល់វេទិកាទៅក្រុមមេធាវីការពារក្តីលោក នួន ជា ដើម្បីមានឱកាសតាំងសំណួរដេញដោលចំពោះដើមបណ្តឹងរដ្ឋប្បវេណីរូបនេះ។

[១១:១៥:០៦]

**លោក វ៉ិចទ័រ កូប៉េ៖**

សូមអរគុណលោកប្រធាន។ អរុណសួស្តី លោក លោកស្រី ចៅក្រមសហការីទាំងអស់។

**ការតាំងសំណួរដោយសហមេធាវីការពារក្តី**

**សួរដោយលោក វ៉ិចទ័រ កូប៉េ៖**

**ស៖** ជម្រាបសួរលោកស្រីដើមបណ្តឹងរដ្ឋប្បវេណី។ ខ្ញុំមានសំណួរមួយចំនួនសួរទៅលោកស្រីទាក់ទងទៅនឹងការងាររបស់លោកស្រីនៅទំនប់១មករា។ ខ្ញុំសូមចាប់ផ្តើមសួរពាក់ព័ន្ធទៅនឹង<ការ

រៀបចំក្នុងក្រុម និងកង>របស់លោកស្រី។ លោកស្រីបានឆ្លើយពីខាងដើមថាប្រហែលជាមាននារី ៥០ នាក់នៅកងរបស់លោកស្រី ហើយកងនេះបែងចែកទៅជា<ក្រុមៗ>។ តើ<លោកស្រីមានចាំទេ> ថា <តើក្នុង>កងរបស់លោកស្រីដែលមាននារីៗដល់ទៅ ៥០នាក់ហ្នឹង គេបែងចែកទៅជាប៉ុន្មានក្រុម?

**លោកស្រី ហ៊ុន សិត្ថានី៖**

**ឆ៖** នៅក្នុងកងហ្នឹង គេគ្មានបែងចែកទេ ពេលការងារ គឺធ្វើទាំងអស់គ្នា។ គេអត់មានបែងចែកជាក្រុមជាអីទេ ពេលទៅធ្វើទំនប់១មករា ហ្នឹងនោះ។ គ្រាន់តែគេវាស់ដី យើងធ្វើទាំងអស់គ្នា។

**ស៖** ខ្ញុំប្រហែលជាស្ដាប់មិនបានច្បាស់ទេ។ លោកស្រីក៏បាននិយាយប្រើពាក្យថា "ក្រុម" <និង> "កង"<>។ អ៊ីចឹង សូម<លោកស្រីជួយ>ពន្យល់<បន្តិច>មើល៍<ថា>ក្រុម<ធៀបនឹងកង វាខុសគ្នាយ៉ាងម៉េចដែរ>?

**ឆ៖** ខាងខ្ញុំហ្នឹង មិនមែនខាង ដូចកងចល័តទេ មានកង មានក្រុមអីហ្នឹងនោះ។ ខ្ញុំនៅផ្នែកមីងៗ ផ្នែកមីង ទៅចូលច្រឡូកជាមួយនឹងកងចល័តហ្នឹង ជាមួយនឹងចល័តទី២ហ្នឹង។ អ៊ីចឹងគេអត់មានបែងចែក បែកជាក្រុម ជាអីទៀតទេ គឺក្នុងភូមិហ្នឹងឯងធ្វើការក្នុងភូមិហ្នឹង ក្រុមគេវាស់ដីឲ្យហ្នឹង គឺធ្វើទាំងអស់គ្នា។ ពេលគេចែកហ្នឹង គឺចែកពេលដែលគេវាស់ដីម៉ែត្រគូបៗ ហ្នឹងបានគេចែក។ គេដាក់មនុស្សប្រុសម្នាក់និងស្រីពីរនាក់ ឲ្យកាប់រែកដីហ្នឹង។ បើថាឲ្យបែងចែកជាក្រុម ជាអីហ្នឹងគ្មានទេ។ ជាកងចល័តទេ ដែលគេនិយាយថា ក្រុម កង អីហ្នឹងនោះ។ ចំណែកនៅតាមភូមិនេះ គ្មានទេ។

[១១:១៨:៣០]

**ស៖** បាទ ខ្ញុំយល់ហើយ។ ចំនួនប្រជាជនសរុបមកពីភូមិរបស់លោកស្រីហ្នឹង គឺបើខ្ញុំមិនច្រឡំទេ បើខ្ញុំប្លុកប៉ាន់មើលទៅឃើញក្នុង ១០០នាក់ហ្នឹង គឺមានស្ត្រី ៥០នាក់ បុរសប្រហែលជា ៣០ <ឬ> ៤០ នាក់ ហើយ<កម្មករមកពី>កងចល័ត<ទី២ហ្នឹងមាន>១០<នាក់>។ អ៊ីចឹង អ្នកដែលមកពីភូមិរបស់លោកស្រីមានចំនួនមនុស្ស សរុបទាំងអស់ ប្រហែលជា១០០នាក់ ត្រឹមត្រូវទេ?

**ឆ៖** ប្រហែលជា ៨០ ទេមិនដល់ ១០០ទេ។ ប្រហែលខ្ទង់ប៉ុណ្ណឹង ៨០នាក់អីហ្នឹង។

**ស៖** តើលោកស្រីអាចប៉ាន់ប្រមាណបានទេ ថាមានប្រជាជនក្នុងចំណោមមនុស្សទាំង ៨០នាក់ មកពីភូមិលោកស្រីនោះ ប៉ុន្មាននាក់ជាប្រជាជនថ្មី <និងមាន>ប៉ុន្មាននាក់ជាប្រជាជនមូលដ្ឋាន ដែលរស់នៅក្នុងភូមិនោះតាំងពីមុនមក?

**ឆ៖** អ្នកដែលទៅធ្វើការនៅ ១មករា ហ្នឹង អ្នកថ្មីប្រហែលជា ២០នាក់ លើសបន្តិចបន្តួច។

**ស៖** ដូច្នេះ គឺថាប្រជាជនមូលដ្ឋានមានចំនួនប្រហែលជា ៦០នាក់។ តើត្រឹមត្រូវដែរឬទេ?

**ឆ៖** ចាស ប្រហែលប៉ុណ្ណឹង។

**ស៖** លោកស្រីនៅចាំបានទេ ដីនៅជាប់ភូមិរបស់លោកស្រីហ្នឹង គេឲ្យគេធ្វើការហ្នឹង តើមានប្រជាជនមកពីភូមិដទៃទៀតមកធ្វើទីហ្នឹងទេ? <ដូច្នេះ តើ>ដីមួយ<ប្លង់នោះ>នៅខាងលិច ឬក៏នៅខាងកើតភូមិលោកស្រីហ្នឹង តើមានអ្នកភូមិក្បែរៗហ្នឹងមកធ្វើការនៅទីហ្នឹងដែរទេ?

**ឆ៖** លោកសួរខ្ញុំហ្នឹង នៅនឹងភូមិ ឬនៅទំនប់១មករា? នៅឯភូមិ?

**ស៖** សូមទោសលោកស្រី ខ្ញុំ<ដូចមិនច្បាស់ទេ។> ខ្ញុំសួរ<>លោកស្រីផ្តោតតែលើ<ការដ្ឋាន> ទំនប់១មករា<ប៉ុណ្ណោះ>។ សំណួររបស់ខ្ញុំគឺថា <ដីមួយប្លង់ដែលត្រូវធ្វើការហ្នឹង តើមានមនុស្សមកពីភូមិ>ដទៃ<មកធ្វើការលើដីហ្នឹង, អ៊ីចឹងមែនទេ>?

[១១:២១:៣៨]

**ឆ៖** ចាស គឺមាន។ ក្នុងមួយសង្កាត់ហ្នឹង វាមានភូមិអីៗជាប់ៗគ្នាអ៊ីចឹង។ វាមានថ្នល់ថ្មី វាមានភូមិបារាយណ៍តូច បារាយណ៍ធំ ភូមិពោធិ៍ពីរ ចតុលោក គឺគេដាក់ជាប់ៗគ្នាអ៊ីចឹង។ អាហ្នឹងគេហៅសង្កាត់បារាយណ៍។ បន្តទៅទៀតទៅ ខាងស្ទឹងត្រង់ទៅ ខាងស្រុកអីទៅទៀតទៅ ខ្ញុំមិនចាំ។ គឺជីកហូរហែអ៊ីចឹង។ រហូតដល់ទប់ស្ទឹងហ្នឹងបាន បីតំបន់ហ្នឹងចូលគ្នាតែម្តង។ គេសម្រុកទប់ស្ទឹងហ្នឹង បីតំបន់បញ្ចូលគ្នា។

**ស៖** តើត្រឹមត្រូវដែរទេ បើខ្ញុំនិយាយថា <>នៅការដ្ឋានទំនប់១មករា<ហ្នឹង ពីភូមិ>មួយ<ទៅ>ភូមិ<>មួយ<>ជាប់ៗគ្នា <ដែល>ភូមិនីមួយៗត្រូវតែជីកដីដែលគេបានកំណត់ទៅឲ្យក្នុងភូមិ<របស់ខ្លួន ដើម្បីសាងសងទំនប់នោះ>។ តើត្រឹមត្រូវដែរទេ?

**ឆ៖** ចាសគឺអ៊ីចឹងមែន គេចែកតាមភូមិហ្នឹង កង់ៗចែកគ្នា។ ជាប់ៗគ្នាហ្នឹង ក្នុងសង្កាត់បារាយណ៍ហ្នឹងគឺជីកជាប់គ្នា។

**ស៖** តើត្រឹមត្រូវដែរទេ ដែលថាភូមិនីមួយៗ ឬក៏ក្រុមអ្នកធ្វើការមួយក្រុមៗមកពីភូមិនីមួយៗមានកន្លែងដេកនៅក្បែរការដ្ឋានការងារហ្នឹងដែរទេ?

**ឆ៖** មានខាងស្រុកគេមាន។ បើចំណែកពួកខ្ញុំ គឺស្នាក់នៅវត្តត្រពាំងជ្រៃហ្នឹងរហូតតាំងពីដំបូងរហូតដល់ចប់ការដ្ឋាន គឺនៅតែមួយកន្លែង គ្មានផ្លាស់ប្តូរទេ។ ដើរពីកន្លែងគេងហ្នឹងរហូតទៅដល់កន្លែងធ្វើការ គឺរាល់ថ្ងៃ។ ចំណែកខាងគេគឺមាននៅជិត ចំណែកខ្ញុំគឺនៅមួយកន្លែងហ្នឹងឯង ដូរពីរបីកន្លែងហ្នឹង

គឺនៅតែមួយកន្លែងហ្នឹង គេមិនឲ្យដូរកន្លែងទៅទៀតទេ។

[១១:៣៩:៤០]

**ស៖** តើក្រុមដែលមកពីភូមិរបស់លោកស្រី គឺជាក្រុមដែលមិនបានដេកនៅក្បែរការដ្ឋានលើកទំនប់ទេ ឬក៏មានក្រុមដទៃទៀតមកពីភូមិផ្សេងទៀត <ក៏>ដេក<នៅវត្តហ្នឹង>ដូចក្រុមលោកស្រីដែរ?

**ឆ៖** មានដែរ ខាងស្រុកស្ទឹងត្រង់ តែគេនៅ -- ដើរមកប្រហែលជាជាង១គីឡូហ្នឹង ខាងស្ទឹងត្រង់។ ខ្ញុំដើរពីត្រពាំងជ្រៃមកហ្នឹង។ ខាងស្ទឹងត្រង់ហ្នឹង គឺគេឲ្យនៅម្ដុំដែរ។

**ស៖** <អ្នកដែល>មកពីភូមិរបស់លោកស្រី ដែលគ្រប់គ្រងទៅលើពលករប្រហែលជា៨០នាក់មកពីភូមិលោកស្រីហ្នឹង តើអ្នកទាំងអស់នោះ ទទួលខុសត្រូវក្នុងការ<ស្នាក់នៅពេលយប់របស់លោកស្រីនៅក្នុងវត្តនោះ តើពួកគេទទួលខុសត្រូវ>ផ្តល់កន្ទេល ឬក៏អង្រឹង ឬក៏អ្វីៗយ៉ាងដូច្នេះ<> ឬក៏អត់ទេ?

**ឆ៖** រឿងហ្នឹង ជារឿងកំសត់ខ្លាំងណាស់។ កូនឈើប៉ុនៗមេជើងយកទៅក្រង គ្មានគិតគូររឿងកន្ទេល រឿងអីក្រាលទេ គឺគេងផ្ទាល់នឹងដើមឈើដែលគេក្រងឲ្យយើងគេហ្នឹង។ ឈឺខ្លួនប៉ុនណា លោកសាកទៅដឹងហើយ។ ហេតុតែអស់កម្លាំង ប្រះក្អកគឺឈឺងហើយៗ អាឈឺខ្លួននៅពេលដែលដឹងខ្លួនទេបានដឹងថាឈឺខ្លួន តែពេលលក់ហ្នឹងគ្មានដឹងឈឺខ្លួនទេ។ ដំបូលហ្នឹង គេប្រកស្លឹកត្នោតឲ្យ។ តែបើមានភ្លៀង មុខតែក្រោកអង្គុយទាំងយប់ហ្នឹងឯង នាំគ្នាអង្គុយទាំងអស់តែគ្នាហ្នឹង ព្រោះប្រកហ្នឹងវាមិនមាំទេ វាគ្រាន់តែបានបាំងក្ដៅទេ បើថាភ្លៀងគ្មានទេ។ ទឹកភ្នែកហូរ ហើយទឹកភ្លៀងមកពីលើ ខ្លួនឯងហូរទឹកភ្នែកទៀត។ កំពុងតែគេងលក់នេះ មានកម្លាំងអីទៅរែកដីទៀតទេ លោកគិតទៅ វាពិបាកប៉ុនណា។ ដើមឈើ គ្រាន់តែលួសៗយកក្រង ក្រងៗគ្រាន់តែកុំឲ្យតែវាផុងជើង។ គេងទៅ មានអីក្រាល បានអីក្រាលមានអីក្រាល។ បើខោអាវមានតែមួយចង្កេះ ផ្លេះនឹងខ្លួនហ្នឹង។ សារុងមួយហ្នឹងប៉ះរាប់រយបំណះ ទុកគ្រាន់ផ្លាស់ ផ្លាស់ងូតទឹក ពិបាកប៉ុនណា។ លោកអាសូរទេ ដែលគ្មានខោអាវស្លៀកនេះ នៅអង្គុយហាលភ្លៀងនេះ វាពិបាកប៉ុនណាទៅ។ ស្អែកឡើងគេឲ្យរែកដីទៀត។

[១១:២៨:៣២]

**ស៖** ការដែលរៀបរាប់ពេលសម្រាន្ត<របស់លោកស្រី>នេះ តើលោកនិយាយអំពីការសម្រាកនៅក្នុងបរិវេណវត្តនុំុង ឬក៏លោកស្រីកំពុងតែនិយាយទីកន្លែងផ្សេង<ទេ>?

**ឆ៖** គឺនៅក្នុងវត្តហ្នឹងឯង គេធ្វើរោងវែងៗ គេងបន្តគ្នាអ៊ីចឹងទៅ។ គេងលើដើមឈើហ្នឹងឯង។

**ស៖** បាទ ខ្ញុំនៅតែបន្តសួរទៅលើក្រុមរបស់លោកស្រី។ <ពេលណាមួយនៅពេល>ព្រឹកមិញ

លោកស្រីនិយាយថាលោកស្រីឈឺពោះហើយលោកស្រីសុំ<បុគ្គលម្នាក់នៅក្នុងក្រុមហ្នឹង គឺមេម្នាក់> ដើម្បីឈប់សម្រាកនៅថ្ងៃមួយនុ៎ង។ តើអ្នកណាគេដែលលោកស្រីសុំច្បាប់ស្នាក់នៅក្នុងវត្ត មិនទៅធ្វើការ ដោយសារតែលោកស្រីឈឺពោះ?

**ឆ៖** ចាស ឈឺពោះហ្នឹងគឺមករដូវ។ ចុកពោះ ដែលយើងរែកដីរាល់ថ្ងៃ។ មនុស្សស្រី មានរដូវណា ឈាមធ្លាក់មកហ្នឹងធ្វើទុក្ខខ្លួន ចុកពោះ ស្លេកស្លាំងញ័រៗដៃ ញ័រជើងអត់កើតទេ ដែលសុំគេមក គេឲ្យសម្រាកហ្នឹងនោះ។ ឡើងស្លេកស្លាំងខ្លួនអស់ហើយ ញ័រធ្វើការអត់កើត។ ហ្នឹងទៅសុំគេសម្រាកបានមួយល្ងាចនុ៎ង។ ល្ងាចដែលគេចាប់ឪពុកខ្ញុំហ្នឹង គឺល្ងាចនោះឯងដែលខ្ញុំចុកពោះហ្នឹងនោះ។ យើងរែកដីដល់ពេលមករដូវហ្នឹង វាដូចអត់ៗធ្លាក់មកនោះ វាទៅជាចុកពោះត្រឡប់ត្រឡិនអ៊ីចឹងទៅ។ នេះលោកមនុស្សប្រុស បើលោកមនុស្សស្រីវិញមិនដឹងជាអាណោចអាធ័មក្នុងចិត្តប៉ុនណាទេនេះ មនុស្សស្រីដូចគ្នាតែមនុស្សប្រុសហ្នឹងបានត្រឹមមួយសួរទេ មិនដឹងយ៉ាងម៉េចទេ។

**ស៖** សំណួររបស់ខ្ញុំសួរថា លោកស្រីចាំទេពេលនុ៎ង លោកស្រីសុំច្បាប់ពីអ្នកណា? ហើយអ្នកណាដែលឲ្យច្បាប់លោកស្រីសម្រាកនៅថ្ងៃនុ៎ង លោកស្រីចាំទេ?

**ឆ៖** គឺចាំ មេកងខ្ញុំហ្នឹងឈ្មោះ អានៗ តែឥឡូវគេស្លាប់បាត់ហើយ គេធ្លាប់មករដូវចុកពោះដូចតែខ្ញុំអ៊ីចឹង បានគេអនុគ្រោះខ្ញុំហ្នឹងនោះ។ ធ្លាប់រកខ្ញុំកោសចង្កេះ កោសអីឲ្យគេ គេថាខ្ញុំមករដូវ ខ្ញុំចុកពោះកន្លងមកមួយអាទិត្យហ្នឹងខ្ញុំចុកពោះវិញហ្នឹង បានគេអនុគ្រោះឲ្យខ្ញុំទៅមួយល្ងាចហ្នឹងនោះ។ គេដឹងខ្លួនគេថាគេឈឺប៉ុនណា គេពិបាកប៉ុនណាបានគេឲ្យខ្ញុំសម្រាកពេលល្ងាចហ្នឹងនោះ។

[១១:៣២:១៧]

**ស៖** តើ អាន ជាមេកង ស្ត្រី៥០នាក់នៅ<កងរបស់>លោកស្រីហ្នឹង ឬក៏អត់ទេ? <ដូច្នេះទាល់តែស្ត្រីទាំងអស់នោះសុំការអនុញ្ញាតពី> អាន <សិន ទើបបានសម្រាក បើសិនពួកគេស្ថិតនៅក្នុងស្ថានភាពដូចលោកស្រីដែរ>?

**ឆ៖** អាន ហ្នឹងជាមេកងរបស់ខ្ញុំ – មេកងរបស់ខ្ញុំផ្ទាល់ហ្នឹង ។

**ស៖** តើ អាន គ្រប់គ្រងទៅលើស្ត្រីទាំង៤៩នាក់នៅក្នុង<កង>របស់លោកស្រីហ្នឹង ឬក៏អត់ទេ?

**ឆ៖** ចាស គឺគេគ្រប់គ្រង គេម្នាក់ហ្នឹង ស្រី។

**លោក វ៉ិចទ័រ កូប៉េ៖**

លោកប្រធាន ខ្ញុំក្រឡេកមើលទៅនាឡិកា ឃើញដល់ម៉ោងឈប់សម្រាកហើយ តើយ៉ាងម៉េចដែរ

លោកប្រធាន?

**ប្រធានអង្គជំនុំ៖**

បាទ អរគុណលោកមេធាវី។ ឥឡូវនេះដល់ពេលសម្រាកថ្ងៃត្រង់ហើយ អង្គជំនុំជម្រះប្រកាសសម្រាកចាប់ពីពេលនេះតទៅរហូតដល់ម៉ោងមួយកន្លះនៅរសៀលនេះ សូមអញ្ជើញចូលវិញ ដើម្បីបន្តកិច្ចដំណើរការសវនាការ។

មន្ត្រីរដ្ឋបាលតុលាការសម្របសម្រួលផ្តល់កន្លែងសម្រាកនៅបន្ទប់រង់ចាំសម្រាប់ដើមបណ្តឹងរដ្ឋ-ប្បវេណីរូបនេះនៅក្នុងអំឡុងពេលឈប់សម្រាក និងឲ្យអញ្ជើញគាត់ រួមទាំងបុគ្គលិកអង្គការ ធី.ភី.អូ មកកាន់កន្លែងផ្តល់សក្ខីកម្ម ក្នុងបន្ទប់សវនាការនេះ នៅវេលាម៉ោងមួយកន្លះនៅរសៀលនេះ។

ហើយបង្គាប់ឲ្យអនុរក្សមន្ទីរឃុំឃាំងនាំខ្លួនលោក ខៀវ សំផន ទៅកាន់បន្ទប់រង់ចាំខាងក្រោមសាលសវនាការនេះ ហើយនិងបង្គាប់ឲ្យនាំខ្លួនគាត់មកចូលរួមសវនាការ នៅក្នុងបន្ទប់សវនាការនេះវិញនៅរសៀលនេះ ឲ្យបានមុនម៉ោងមួយកន្លះ។

សម្រាកចុះ!

**ក្រឡាបញ្ជី៖**

សូមអញ្ជើញក្រោកឈរ!

*(សវនាការសម្រាកពីម៉ោង១១:៣៤ នាទី ដល់ម៉ោង១៣:៣២ នាទី)*

[១៣:៣២:១៧]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ ហើយនិងផ្តល់វេទិកាជូនទៅក្រុមមេធាវី ការពារក្តីលោក ខៀវ សំផន ដើម្បីមានឱកាសបន្តការតាំងសំណួរដេញដោលចំពោះដើមបណ្តឹងរដ្ឋ-ប្បវេណី -- នួន ជា ក្រុមមេធាវីការពារក្តីលោក នួន ជា!

**លោក វ៉ិចទ័រ កូប៉េ៖**

សូមអរគុណលោកប្រធាន។ ជម្រាបសួរលោក លោកស្រី ចៅក្រម សហការីទាំងអស់។

**សួរដោយលោក វ៉ិចទ័រ កូប៉េ៖**

**ស៖** ជម្រាបសួរសាជាថ្មី លោកស្រីដើមបណ្តឹងរដ្ឋប្បវេណី។ ខ្ញុំមានសំណួរមួយចំនួនទៀតត្រូវ

សួរលោកស្រី។ ហើយនៅមុនពេលឈប់សម្រាកពិសាបាយថ្ងៃត្រង់ ខ្ញុំបានសួរអំពីកន្លែងសម្រាន្តនៅក្នុងបរិវេណវត្តត្រពាំងជ្រៃ <ហើយថា ស្ត្រីនៅក្នុងកងរបស់លោកស្រីក៏បានស្នាក់នៅទីនោះដែរ កាលនោះ។ អ៊ីចឹង> តើប្រុសៗ<>៣០នាក់<ក៏ស្នាក់នៅទីនោះដែរ ឬ? និយាយម្យ៉ាងទៀត ថាតើអ្នកដែល>មកពីភូមិរបស់លោកស្រី<ទាំងអស់ មកដេកនៅក្នុងបរិវេណ>វត្តត្រពាំងជ្រៃដែរ ឬក៏អត់ទេ?

**លោកស្រី ហ៊ុន សិត្ថានី៖**

**ឆ៖** គឺគេធ្វើរោងដោយខ្លួនហ្នឹង ចម្ងាយប្រហែលពីគ្នា៣០ម៉ែត្រ រោងស្រីផ្សេង រោងប្រុសផ្សេង។ ខាងស្រីៗគេងនៅខាងស្ដាំដៃវត្ត -- វិហារ។ ហើយខាងប្រុសៗនៅពីខាងមុខៗវិហារវត្ត។

**ស៖** ហើយក្រោយពេលសម្រាន្តនៅពេលយប់ តើប្រជាជនទាំង៨០នាក់ ទាំងប្រុស ទាំងស្រី មានចាកចេញពីវត្តត្រពាំងជ្រៃដែរឬក៏អត់? មានចាកចេញពីវត្តត្រពាំងជ្រៃរួចហើយ ធ្វើដំណើរទៅកន្លែងធ្វើការ គឺនៅទំនប់ ១មករា។ តើអ៊ីចឹងមែនទេ?

**ឆ៖** សូមលោកសួរម្ដងទៀត ខ្ញុំស្ដាប់សំណួរអត់បាន។

[១៣:៣៥:០៥]

**ស៖** តើប្រជាជនទាំងប្រុសទាំងស្រីមកពីភូមិរបស់លោកស្រីហ្នឹង ក្រោយពី<ក្រោកពី> សម្រាន្តនៅវត្តហ្នឹងហើយ តើ<លោកស្រី និង>ប្រជាជនទាំង៨០នាក់ហ្នឹង<>ដើរ<ជាមួយគ្នាពីវត្តហ្នឹង>ទៅធ្វើការនៅឯការដ្ឋាន<ទំនប់ឬ>?

**ឆ៖** គឺម៉ោងបួនហ្នឹង គឺកញ្ចែដាស់យើងឲ្យស្លៀកពាក់រៀបចំខ្លួន។ កញ្ចែហ្នឹងប្រហែល១៥នាទី ២០នាទី កញ្ចែមួយទៀតគឺត្រូវតែចេញដំណើរ ទាំងស្រីទាំងប្រុសហ្នឹង គឺចេញដំណើរ ដើរទៅ។ ហើយក្នុងការធ្វើដំណើរហ្នឹង គឺថាម្នាក់ៗងោកងុយ ដើរតោងគ្នា ជួនដួលទៅ អីទៅ។ មេកង មេក្រុម គេស្ដីឲ្យថាម៉េចបានដួល។ ចុះបើងោកដួល នាំគ្នាក្រោកទៅ ទៅទៀតទៅ។ អ្នកថាឲ្យចេះតែថាទៅ យើងទៅតែចេះទៅទៀត តោងទៅមុខទៀតទៅ។ ជួនកាលទៅដួលឯមុខហ្នឹងទៀតទៅ ក៏មានដែរ។ ខ្លួនខ្ញុំផ្ទាល់ហ្នឹងក៏ធ្លាប់ដួលដែរ ធ្វើម៉េចបើដើរធ្មេច តោងគេទៅ ដឹងតែទៅមុខ ចេះតែតោងៗទៅនឹងគេទៅ។ ទាំងស្រីទាំងប្រុសហ្នឹង ជួនដួលគេ ជួនដួលយើង។ ដើរទៅជាន់កែងគ្នា។ ម្នាក់ៗសុទ្ធតែសង្វាតធ្មេច។ ងងុយម៉ោងបួនហ្នឹង កំពុងតែលក់ស្រួល ហើយដល់ម៉ោងការងារត្រូវតែចេះដំណើរ។ មិនចេញ គឺមិនបាន។ ត្រូវតែទៅ។

**ស៖** ពីមុននេះ<បន្តិច កាល>ពីព្រឹកមិញនេះ លោកស្រីនិយាយថា លោកស្រីស្មានចម្ងាយពីវត្ត

ត្រពាំងជ្រៃទៅការដ្ឋាន<ទំនប់ហ្នឹង>គឺមានចម្ងាយប្រហែលជា៣គីឡូម៉ែត្រ។ <តើ>លោកស្រីអាចជម្រាបអង្គជំនុំជម្រះបានទេ ហេតុអីបានលោកស្រីអាចសន្និដ្ឋានថា វាមានចម្ងាយ៣គីឡូម៉ែត្រ ពីវត្តទៅការដ្ឋាន?

[១៣:៣៧:៤៤]

**ផ៖** ខ្ញុំអាចប៉ាន់ស្មានបាន ព្រោះខ្ញុំធ្លាប់រៀនធ្លាប់សូត្រ ខ្ញុំដឹងចម្ងាយស្មាន ខុសបន្តិចបន្តួច លើសបន្តិចបន្តួច ខ្វះបន្តិចបន្តួច។ ខ្ញុំប៉ាន់ស្មានទៅប្រហែលជាប៉ុណ្ណឹង។

**ស៖** ហើយក្រោយពីប្រជាជនទាំង៨០នាក់មកដល់ការដ្ឋានការងារ តើនៅពេលហ្នឹង លោកស្រីចាប់ផ្ដើមធ្វើការងារភ្លាមៗ ដូចពលករដទៃទៀត មកពីភូមិដទៃៗទៀតដែរឬទេ?

**ផ៖** ប្រាកដហើយ បើទៅដល់កន្លែងគឺយើងចាប់ផ្ដើមការងារហើយ។ ដឹងការងាររៀងខ្លួន មានចប មានបង្គី មានដងរែក។ គឺចាប់ផ្ដើមធ្វើការងារហើយ តែទៅដល់កន្លែងហើយ ត្រូវតែចាប់ផ្ដើមហើយ។ គ្មានអ្នកណានៅអែអង់អីបានទេ ដឹងការងាររៀងៗខ្លួន។ អ្នកកាប់ស្រវាចប អ្នករែកស្រវាបង្គីហ្នឹង។ បង្គីហ្នឹង ជួនកាលថ្ងៃណា ដូចថាអស់កម្លាំងពេកហ្នឹង យកទៅរកកន្លែងលាក់ទៅ លីទាំងបង្គីហ្នឹងមកកន្លែងវិញ។ គឺថាវាអស់ដៃអស់ជើងពេកទៅ មិចភ្នែកដាក់គ្នាអ៊ីចឹងទៅ យកបង្គីទៅលាក់កន្លែងណាទៅ លីទៅទៀត។ អើយ! ចុះម៉ោង១០យប់ ដើរត្រឡប់ទៅវិញ។ អ៊ីចឹង នាំគ្នាលាក់ រកកន្លែងណាលាក់ឲ្យវាមានសុវត្ថិភាព ណាខ្លាចគេលួច ប៉ុនទេបើអស់កម្លាំងពេកទៅហើយ។ អ៊ីចឹង នាំគ្នាយកទៅលាក់ត្រង់នេះ លាក់ត្រង់នោះទៅ។ ហើយបើថ្ងៃណាមានកម្លាំងរាងក្លាហានទៅ ក៏លីចប លីបង្គីរៀងខ្លួនយកទៅទុកឯវត្តត្រពាំងជ្រៃហ្នឹងទៅ។ តែថ្ងៃណាអស់កម្លាំងពេក មិចភ្នែកដាក់គ្នារកកន្លែងលាក់ហើយយកទៅមិនរួចទេ អស់ ដើរតែអូសដៃ អូសជើងគ្រប់គ្នា។ ម៉ោងដប់ ទម្រាំដើរទៅដល់វត្តនុំង ទម្រាំតែរកទឹកងូត ដូចខ្ញុំជម្រាបលើកមុនអ៊ីចឹង ថាអស់ទៅលក់ទាំងខោអាវហ្នឹងទៅ ព្រលឹមឡើងមកទៀតទៅ។ បើថ្ងៃណាមានកម្លាំងទៅស្រវេស្រវារកទឹក រកអីងូតអ៊ីចឹងទៅ។ ងូតទឹកហើយហ្នឹង ត្រូវរៀបចំខ្លួន ថាស៊ិកខោអាវសម្រាប់ទៅរែកស្អែកហ្នឹងឲ្យហើយ ដើម្បីកញ្ចែទី១ហ្នឹង យើងសម្ងំបានបន្តិចទៀត។ បើយើងមិនទាន់ស្លៀកពាក់កញ្ចែទី១ ត្រូវតែងើប។ មានទឹកលុបមុខក៏លុបទៅ គ្មានទេក៏គ្រាន់យកដៃកេះៗភ្នែកហ្នឹងទៅ ទៅទៀតទៅ។

[១៣:៤១:០៥]

**ស៖** លោកស្រីខ្ញុំមានសំណួរតិចទេ សូមលោកស្រីឆ្លើយខ្លីបន្តិច។ <ខ្ញុំនឹងអគុណលោកស្រី។>

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

ឥឡូវនេះ ខ្ញុំនៅសួរពាក់ព័ន្ធទៅនឹងពេលព្រឹក នៅពេលលោកស្រីទៅធ្វើការងារ។ នៅពេលប្រជាជនទាំង ៨០នាក់ពីក្រុមលោកស្រីទៅដល់ការដ្ឋាន<ទំនប់ហ្នឹង> តើអ្នកទាំង៨០នាក់ហ្នឹង ក៏ដូចជាក្រុមដទៃទៀត ចាប់ផ្តើមធ្វើការងារតំណាលៗគ្នា ឬក៏អត់ទេ? តើនៅ<ពេលលោកស្រី>ឮសូរជួង <បន្ទាប់មក លោកស្រីចូលរួមកម្លាំងការងារជាមួយប្រជាជនមកពីភូមិផ្សេងៗ, តើត្រឹមត្រូវ>ទេ?

**ឆ៖** រឿងខាងខ្ញុំគឺមិនដែលខកទេ យើងនៅឆ្ងាយអ៊ីចឹង ប្រធានកងហ្នឹងឯងត្រូវប្រយ័ត្ន ព្រោះយើងនៅឆ្ងាយជាងគេ អ្នកដែលគេនៅជិត ជួនកាលយើងកាប់ដីមួយស្របក់ហើយគេទើបទៅដល់ក៏មានដែរ។ យើងឆ្ងាយ យើងធ្វើម៉េចឱ្យទៅដល់កន្លែងហ្នឹង ព្រោះមេក្រុមហ្នឹងគាត់ប្រយ័ត្នកុំឱ្យយើងទៅដល់ក្រោយគេ ព្រោះយើងឆ្ងាយ យើងទៅមុនគេ។

**ស៖** ប៉ុន្តែបើខ្ញុំនិយាយយ៉ាងដូច្នេះ វាត្រឹមត្រូវដែរទេថា នៅពេលលោក<ស្រី>ចាប់ផ្តើមធ្វើការងារនៅការដ្ឋាន<ទំនប់ហ្នឹង> គឺចាប់ផ្តើមនៅពេល<ដំណាលគ្នានឹង>ប្រជាជនមកពីភូមិដទៃៗទៀតដែរ<ទេ>? តើត្រឹមត្រូវដែរទេបើនិយាយអ៊ីចឹង?

**ឆ៖** ដូចខ្ញុំជម្រាបអ៊ីចឹងថា ជួនកាលយើងទៅដល់មុនបន្តិច តែជាទូទៅយើងនៅឆ្ងាយនេះគឺច្រើនតែទៅដល់មុនគេមិនដែលក្រោយគេទេ។ អ្នកដែលគេតាំងទីនៅជិតហ្នឹង គេអាច -- យើងកាប់បានរែកបានពីរបីជើងអ៊ីចឹងទៅ បានគេទើបទៅដល់ ភូមិគេហ្នឹង។

[១៣:៤៣:២៦]

**ស៖** លោកស្រី<ដើមបណ្តឹងរដ្ឋប្បវេណី> មុនពេលលោកស្រីឆ្លើយជូនតុលាការ មានសាក្សីបីនាក់<រួចទៅហើយ ដែលបាន>ឆ្លើយជូនតុលាការអំពីម៉ោងការងារ ក៏ដូចជាលក្ខខណ្ឌការងារនៅការដ្ឋាន<ទំនប់ហ្នឹង។ល។> សាក្សីម្នាក់ក្នុងចំណោមទាំងបីនាក់ហ្នឹងបានផ្តល់សក្ខីកម្មថា "ម្នាក់ៗធ្វើ -- ចាប់ផ្តើមធ្វើការនៅការដ្ឋាននៅពេលតែមួយ គឺប្រហែលជានៅម៉ោងប្រាំពីរព្រឹក"។ តើសាក្សីម្នាក់នេះឆ្លើយថាយ៉ាងដូច្នេះត្រឹមត្រូវដែរទេ?

**ឆ៖** អត់ទេ ព្រោះខាងខ្ញុំឆ្ងាយដូចខ្ញុំជម្រាបអ៊ីចឹង ពួកខ្ញុំគឺតែងតែមកដល់មុនគេ គ្មានដល់ម៉ោងប្រាំពីរឯណា មិនដែលមានទេ ម៉ោងប្រាំពីរច្បាស់ការងារភ្លឺទែងទៅហើយ ពួកខ្ញុំចាប់ផ្តើមតាំងពីល្ងះៗនោះ។

**ស៖** ប្រហែលជាខ្ញុំយល់ច្រឡំហើយ <ប៉ុន្តែកាល>ពីព្រឹកមិញ <ខ្ញុំយល់ថា កន្លែងធ្វើការ>ក្រុមរបស់លោកស្រី<គឺនៅ>ជាប់ទៅនឹងក្រុម<ដែលមកពីភូមិផ្សេង>ទៀត គឺមានន័យលោកស្រីជីក<>ដី

ហ្នឹង គឺថា<>នៅជាប់ៗជាមួយក្រុម<ដែលមកពីភូមិផ្សេង>ទៀតដែរ។ ខ្ញុំយល់អ៊ីចឹងត្រឹមត្រូវទេ?

**ឆ៖** គឺជាប់ៗគ្នាហ្នឹង គឺឃុំបារាយណ៍។ ឃុំបារាយណ៍ហ្នឹង គេដាក់តាមភូមិមក បន្តបន្ទាប់គ្នាមក ចតុលោកមក ពោធិ៍ពីរមក បារាយណ៍តូច បារាយណ៍ធំ ភូមិថ្មី មានខាងជីអោក មានខាងចតុលោក មានខាងស្អឹទេ ខ្ញុំភ្លេចភូមិខ្លះហើយ។ ហ្នឹងខាងសង្កាត់បារាយណ៍ គឺងើបមកទាំងអស់គ្នាហ្នឹង។ ខ្ញុំ--

[១៣:៤៥:១០]

**សៈ** លោកស្រីសូមទោសដែលខ្ញុំកាត់ផ្តាច់លោកស្រី។<ខ្ញុំគិតថា វាមានប្រយោជន៍ជាង បើ>ខ្ញុំសូមអានសម្រង់នៃសក្ខីកម្មរបស់សាក្សីរូបនេះ ហើយខ្ញុំសួរទៅលោកស្រី <បើសិនជាវាត្រឹមត្រូវ>។ លោកស្រីគ្រាន់តែឆ្លើយថា ត្រូវ ឬក៏មិនត្រូវ គឺឯកសារ E3/403 គឺចម្លើយរបស់ ប៊ិច សុខា។ ERN អង់គ្លេស 00403006, ERN ភាសាខ្មែរ 00389524 និងបារាំង 00422240។ <លោកស្រីសាក្សី គេសួរសាក្សីរូបនោះ>ដូចតទៅ ខ្ញុំសូមអាន៖ "តើគេកំណត់ម៉ោងការងារដូចម្តេច ហើយគេៗបែងចែកការងារយ៉ាងដូចម្តេចដែរ?" ហើយសាក្សីរូបនេះ ឆ្លើយដូចតទៅ៖ "ពីម៉ោងប្រាំពីរព្រឹក ដល់ម៉ោងដប់មួយព្រឹក ហ្នឹងពេលព្រឹក ហើយពេលរសៀល ពីម៉ោងពីរ ទៅដល់ម៉ោងប្រាំ ក្នុងពេលធ្វើការងារ គឺគេអនុញ្ញាតឲ្យឈប់សម្រាក១៥នាទី។ ពេលយប់ ចាប់ផ្តើមធ្វើការងារនៅម៉ោងប្រាំមួយ សាមសិបនាទីល្ងាច ទៅដល់ម៉ោងដប់ល្ងាច។ ការងារ<នៅទំនប់ត្រូវ>ចែកទៅតាមតំបន់ ស្រុក <និងបុគ្គល>ម្នាក់ៗ។ <មនុស្សម្នាក់>ជីកឲ្យបាន ២ម៉ែត្រគូប <ក្នុងមួយថ្ងៃ ហើយ>រែកដី<ធ្វើទំនប់>។ បើអ្នកណាចប់មុនម៉ោង គេអាចសម្រាកមុនបាន"។ តើចម្លើយរបស់សាក្សីរូបនេះត្រឹមត្រូវទេ? តើចម្លើយនេះ វាដូចគ្នានឹងក្រុមមនុស្សទាំង៨០នាក់ ពីក្រុមរបស់លោកស្រីដែរទេ?

**ឆ៖** ខ្ញុំចង់ដឹងថា គេនេះនៅស្រុកឯណា សង្កាត់ណា បានជាមិនដូចខាងខ្ញុំ។ ពួកខ្ញុំដឹងតែ តែដល់ម៉ោងប្រាំ ធ្វើម៉ោងប្រាំ ដល់ទៅម៉ោងដប់មួយសម្រាកហូបបាយ ម៉ោងមួយចាប់ផ្តើមដល់ម៉ោងប្រាំមួយ -- អ៊ូ! ដល់ម៉ោងប្រាំ។ ម៉ោងប្រាំមួយ ចាប់ផ្តើមទៅទៀត ដល់ម៉ោងដប់យប់។

**សៈ** ប៉ុន្តែយ៉ាងហោចណាស់ថា វាត្រឹមត្រូវទេ ដែលថាគេមានពេលសម្រាកបីម៉ោង ពីម៉ោងដប់មួយ រហូតទៅដល់ម៉ោងពីរ គិតទៅវាបីម៉ោង ដើម្បីសម្រាកពេលបាយថ្ងៃត្រង់។ ត្រឹមត្រូវទេ?

**ឆ៖** ខាងខ្ញុំ តែម៉ោងមួយគឺចុះហើយ អត់មានដល់ម៉ោងពីរទេ។

[១៣:៤៩:១០]

**សៈ** ដូច្នេះ នៅកន្លែងដែលលោកស្រីធ្វើការ គឺលោកស្រីមានពេលសម្រាកបាយថ្ងៃត្រង់ហ្នឹង ពីរ

ម៉ោង។ ត្រឹមត្រូវទេ?

**ឆ៖** ចាស។

**ស៖** ហើយថាតើត្រឹមត្រូវទេ នៅពេលព្រឹក ប្រជាជនទាំង៨០នាក់ គឺ<ត្រូវគេ>អនុញ្ញាតឱ្យ យកទៅជាមួយ ដូចជាបាយ សម្ល បន្លែ ត្រី សាច់ជាដើម<ដែរ ឬទេ? តើ>គេអនុញ្ញាតឱ្យយកម្ហូបចំណី ទាំងអស់នេះ<នៅពេលព្រឹក> ពីវត្តទៅការដ្ឋានការងារ <មែន>ទេ?

**ឆ៖** រឿងបាយ រឿងម្ហូប គឺមានចុងភៅគេដោះស្រាយ យើងដឹងតែការងារទេ។ ចុងភៅហ្នឹង តែម៉ោងដប់ គឺសម្លបាយហ្នឹងឆ្អិន គេសែងមក គេចាត់កម្លាំង ឱ្យនៅសែងបាយ សែងសម្ល យកមកឱ្យ អ្នកពលកម្មហ្នឹង។ ធ្វើម៉េចឱ្យមកដល់កន្លែងហ្នឹង ដល់ពេលសម្រាកហ្នឹងមកមុន កន្លះម៉ោងទៅ ១៥នាទី ២០នាទីអី តាមតែគេតាមមកទាន់មិនទាន់ហ្នឹង។ អត់មានជាឯកជនដាក់តាមខ្លួនអីគ្មានទេ។

**ស៖** ដូច្នេះ បាយថ្ងៃត្រង់ដែលលោកស្រីហូបនៅអំឡុងម៉ោងដប់មួយ គឺជាចំណីអាហារ<ពី ពេលព្រឹក>ដែលលោកយកពីវត្តទៅកន្លែងការដ្ឋានការងារ<> តើត្រឹមត្រូវទេ?

**ឆ៖** ចាស ពិតហើយ ទៅហូបនៅកន្លែងការងារហ្នឹង។ ថ្ងៃខ្លះក៏បានឆ្អែតទៅ ថ្ងៃខ្លះក៏រាងស្ទើរ បន្តិចទៅ។

**ស៖** តើ អាន – ដែលលោកស្រីនិយាយឈ្មោះគាត់កាលពីព្រឹកមិញ– <>ជាអ្នកទទួលខុសត្រូវ ចំពោះមនុស្ស ទាំង៨០នាក់ <ដែលមកពីភូមិរបស់លោកស្រី នៅក្នុងកង>របស់លោកស្រី គឺគាត់ជាអ្នក ទទួលខុសត្រូវថា ត្រូវតែមានចំណីអាហារហូបគ្រប់គ្រាន់។ អីចឹងឬក៏អត់ទេ?

**ឆ៖** ខាងម្ហូបអាហារ គឺដោះស្រាយតាមភូមិៗ គឺអ្នកភូមិហ្នឹងផ្គត់ផ្គង់មកឱ្យ។ កាលណាយើង ជិតអត់អីចឹងទៅ ឱ្យដំណឹងទៅគេៗបររទេះដឹកអង្ករ ដឹកម្ហូបអាហារហ្នឹងមកឱ្យ ១០ថ្ងៃ សម្រាកម្តង។ ជួនកាលគេកាប់គោឱ្យហូបអីចឹងទៅ ជួនកាលកាប់សាច់ជ្រូកអីចឹងទៅ។ យូរៗបានហូបសាច់ម្តងវេទនា ម្នាក់ៗរាក ភ្នែករូងអស់ហើយ។ ខ្លះទៅជាមួល ឈឺ រដូករណែល ខានទៅធ្វើការគេស្តីឱ្យទៀត គេថា "ឱ្យហូបឆ្អាញ់ហើយនៅឈឺទៀត បានតែគេមិនឱ្យហូបមែន"។ ធ្វើម៉េចបើយូរៗបានហូបសាច់ម្តង ម្នាក់ៗអរហើយបានសាច់ហូប ប៉ុនថាហូបទៅសុខភាពក្នុងខ្លួននោះ សាច់ញ៉ាំទៅវាក្តៅ ទៅវារាកមួល ទាំងគេទាំងខ្ញុំ ទាំងអស់តែគ្នាហ្នឹង។ ពេទ្យមកចែកថ្នាំមូលៗ ដូចអាចម៍ទន្សាយហ្នឹង ចេះតែលេបទៅ ត្រូវមិនត្រូវគេឱ្យហើយ ចេះតែលេបទៅ។

[១៣:៥៣:៣៥]

**ស៖** ព្រឹកមិញនេះ លោកស្រីឆ្លើយថា លោកស្រីចាប់ផ្ដើមធ្វើការងារដូចអ្នកដទៃទៀតដែរ ប៉ុន្តែ តើ<>គេឲ្យ<លោកស្រី>សម្រាក១៥នាទីដែរទេ<ក្រោយពីធ្វើការបានមួយម៉ោងកន្លះ ឬពីរម៉ោង>?

**ផ៖** គេឲ្យសម្រាកប្រហែលជាម៉ោង ប្រាំបួន១កន្លះអីហ្នឹង គេឲ្យសម្រាកមួយភ្លែត។ សម្រាក ហ្នឹងដឹងទៀតថា កញ្ជែគេច្រេចត្រង់ណា ដាក់គួទអង្គុយត្រង់ហ្នឹងហើយ អត់មានដើរទៅណាទេ ព្រោះ ពេលវាខ្លី។ ខ្លះអង្គុយទៅទល់ខ្នងគ្នាទៅ ធ្មេចបន្តិចទៅ ឲ្យតែថាកញ្ជែច្រេចហ្នឹង គឺដាក់បង្គីចុះហើយ ដាក់ គួទចុះហើយ ធ្វើម៉េចឲ្យបានផ្អែកគ្នា ឬក៏ក្បែរស្អីអ៊ីចឹងទៅ ទម្រេតទៅ។ អ្នកខ្លះគ្រាន់តែភ្លាមហ្នឹងមួយ ស្របក់ហ្នឹង ក៏ស្រមុកបានដែរ។

**ស៖** តើពេលសម្រាក ១៥នាទីនេះ<ដែលលោកស្រីទើបាននិយាយហ្នឹង> តើជាការឈប់ សម្រាកនៅពាក់កណ្ដាល<វគ្គការងារ>ពេលព្រឹក<? និយាយម្យ៉ាងទៀត តើ>ការអនុញ្ញាតឲ្យឈប់ សម្រាក១៥នាទីនេះ គឺគេសម្រាកពេលធ្វើការបានពាក់កណ្ដាលព្រឹកហើយ។ អ៊ីចឹងមែនទេ?

**ផ៖** ចាស មែនហើយ។

**ស៖** លោកស្រីទើបតែឆ្លើយអម្បាញ់មិញនេះ តាមដែលលោកស្រីស្មានទៅចម្ងាយពីវត្តទៅ កន្លែងធ្វើការ គឺមានចម្ងាយប្រហែលជា ៣គីឡូម៉ែត្រ។ តើខ្ញុំអាចនិយាយយ៉ាងដូច្នេះត្រូវទេថា ប្រជាជន ទាំងអស់ហ្នឹងត្រូវដើរ ៤៥នាទី <តែបើដើរយឺត គឺចំណាយរយៈពេលមួយម៉ោង ចេញ>ពីវត្តទៅ ការដ្ឋានការងារហ្នឹង។ តើត្រឹមត្រូវទេ ដើរពី៤៥នាទី ទៅមួយម៉ោង?

**ផ៖** ដើរ -- ពេលដើរនេះ ខ្ញុំមិនអាចស្មាននាទីដឹងទេ។ បើចម្ងាយចេះតែប្រមាណបានហើយ ដល់ដើរ ធ្វើដំណើរហ្នឹងមិនស្មានបានទេ។

**ស៖** បើសិនជាយើងស្ដាប់ចម្លើយរបស់សាក្សីដែលទើបបង្ហាញលោកស្រី ហើយក៏ដូចជា ចម្លើយរបស់សាក្សីពីរនាក់ផ្សេងទៀត ម៉ោងការងារ គឺចាប់ផ្ដើមធ្វើនៅម៉ោង<ប្រាំ>ពីរ។ តើត្រឹមត្រូវទេ បើខ្ញុំនិយាយថា លោកស្រីត្រូវចាកចេញពីវត្តនៅម៉ោងប្រាំមួយ ឬក៏ម៉ោងប្រាំមួយ ដប់ប្រាំនាទី។ បើខ្ញុំថា អ៊ីចឹង តើត្រឹមត្រូវទេ?

[១៣:៥៧:២៣]

**ប្រធានអង្គជំនុំ៖**

សាក្សីកុំទាន់អាល់ឆ្លើយតប! សូមអញ្ជើញ សហព្រះរាជអាជ្ញារងអន្តរជាតិ!

**លោក ឌេល លីសាក់៖**

*ប្រតិចារិកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារិកក្នុងភាសាទាំងបី។ ប្រតិចារិកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារិកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

សូមអរគុណលោកប្រធាន។ បើសិនជាមេធាវីត្រូវប្រើចម្លើយរបស់សាក្សីផ្សេងទៀត គឺត្រូវ<យោង>ទៅលើចម្លើយរបស់សាក្សីម្នាក់។ តាមដែលខ្ញុំចាំ <ហើយយល់នោះ> សាក្សីបីនាក់មុននោះពីរនាក់<>ជាអ្នក<គ្រប់គ្រងការងារ ឬជនដៃដល់ ដែលបានផ្ដល់ម៉ោងចាប់ផ្ដើមនៅយឺតបន្តិច។ ចំណែកឯសាក្សីម្នាក់ទៀត គឺជាកម្មករ>ធ្វើការដូចដើមបណ្ដឹងរដ្ឋប្បវេណី<រូបនេះ បានប៉ាន់ប្រមាណរយៈពេលម៉ោងធ្វើការស្របគ្នានឹងចម្លើយរបស់គាត់>។ ដើម្បីចៀសវាងកុំឲ្យមានការច្របូកច្របល់មេធាវីការពារក្ដីត្រូវតែ<ដកស្រង់ឯកសារយោង ជាជាងគ្រាន់តែដាក់បង្ហាញពីព្រឹត្តិការណ៍ភស្តុតាងទាំងហ្នឹងនោះ>។

**លោក វ៉ិចទ័រ កូប៉េ៖**

ខ្ញុំយល់ឃើញថា <នេះ>ជាការ<បង្កើតការ>ជំទាស់<ដ៏អន់មួយ ដោយ>ហៅសាក្សីពីរ<នាក់ដំបូង>ថាជាចារីនោះ។ <ខ្ញុំគិតថា គ្មានហេតុផលណាសោះ ដែលលោកសហព្រះរាជអាជ្ញាទៅហៅសាក្សីទាំងពីរនាក់នោះថាជា>ដៃដល់បែបនេះ<>។ <ប៉ុន្តែ>តាមខ្ញុំចាំ សាក្សីទី៣ បានបញ្ជាក់ហើយថា<>ម៉ោងការងារ<វាវែងជាង>។ ខ្ញុំគ្រាន់តែយោងទៅលើចម្លើយរបស់សាក្សីម្នាក់ក្នុងបីនាក់នេះ។ <ឥឡូវនេះ> ខ្ញុំ<>ព្យាយាម<ចង់ដឹងថា តើសាក្សីប្រហែលនិយាយខុសអំពី>ម៉ោងការងារ <ហើយថាចង់ដឹងថា តើក្រុមរបស់គាត់ ពួកគាត់បានចេញពីវត្តទៅធ្វើការនៅម៉ោងប្រាំមួយ ឬអត់ទេ។ បើសិនជាគាត់ឆ្លើយថាអត់ទេ ក៏មិនអីដែរ តែគាត់អាចឆ្លើយអ៊ីចឹង។ ដូច្នេះខ្ញុំគិតថា ខ្ញុំត្រូវបានអនុញ្ញាតឲ្យសួរសំណួរនេះ>។

[១៣:៥៩:២៤]

**ចៅក្រម ក្លូឌា ហ្វេនស៍៖**

បើតាមដែលខ្ញុំ<យល់>ពីខាងសហព្រះរាជអាជ្ញា គឺ<បញ្ហាមិនមែនអំពីសំណួរនោះទេ តែអំពីឯកសារយោង>។ <អ្វីដែលយើងបានធ្វើគឺទទួលយកឯកសារយោងចំពោះ>ចម្លើយសាក្សីមុននេះ<លុះត្រាតែភាគីយល់ស្របដែរ។ នេះគឺជាអ្វីដែលបានលើកឡើង។ បើ>មានភាគី<ណាមួយ> ក្រោកឡើង<>ភ្លាមៗ <ហើយប្រាប់ថា នេះមិនមែនជាអ្វីដែលខ្ញុំចាំបាននោះទេ>។ អ៊ីចឹង លោកមេធាវីត្រូវដកស្រង់ឲ្យបានច្បាស់លាស់។ <ខ្ញុំគិតថា ត្រង់នេះហើយជាបញ្ហា។>

**លោក វ៉ិចទ័រ កូប៉េ៖**

<ខ្ញុំគិតថា ខ្ញុំទើបតែដកស្រង់ពីកំណត់ហេតុស្ដាប់ចម្លើយរបស់ឈ្មោះ> សុខា <ដែល>បាន

និយាយថា ម៉ោងការងារគឺប្រាំពីរ ទៅដល់ម៉ោងដប់មួយ ហ្នឹងពេលព្រឹក។ ហើយបន្ទាប់មក<បានគណនា>ថា ត្រូវដើរ <ប្រហែលជា>៤៥<នាទី ហើយច្រើនបំផុតគឺមួយម៉ោង។ ខ្ញុំសួរទៅដើមបណ្ដឹងរូបនេះថា តាមពិតគាត់មិនបានក្រោកនៅម៉ោងបី ហើយចេញទៅធ្វើការនៅម៉ោងបួនទេ។ តាមពិត គាត់ឡើងម៉ោងប្រាំ និងចេញទៅធ្វើការនៅម៉ោងប្រាំមួយ> ។

**ចៅក្រម ក្លូឌា ហ្វេនស៍៖**

បញ្ហា<ចោទ> មិនមែនជា<សំណួរ>បញ្ហាទេ <តែជាឯកសារយោង,>លោកមេធាវី។

**លោក វ៉ិចទ័រ កូប៉េ៖**

គឺយកឯកសារយោង គឺ<E3/403> ERN <អង់គ្លេស> 00403006, ខ្មែរ <00389524> ហើយបារាំង 00422240 គឺឯកសារ<តែមួយដែលខ្ញុំទើបតែផ្ដល់ជូន។>

[១៤:00:៥១]

**លោក ឌេល លីសាក់៖**

ប្រសិនណាបើមេធាវីការពារក្ដីយកចម្លើយរបស់សាក្សីមួយ<នេះ>យកមកសួរ គឺមិនបញ្ហាទេ។ <ខ្ញុំគិតថា >គាត់បានសួរ<ជាច្រើនដងមកហើយ អំពីម៉ោងការងារដែល ប៊ុច សុខា បានផ្ដល់> ហើយ <>ប៊ុច សុខា <ខ្លួនឯងហ្នឹងគឺជាកម្មាភិបាលគ្រប់គ្រងនៅការដ្ឋានហ្នឹង>។ <ប៉ុន្តែ ស្រាប់តែមេធាវីព្យាយាមបង្ហាញថា>មនុស្សទាំងបីនាក់យល់ស្រប<គ្នាលើរឿងតែមួយទៅវិញ។ ខ្ញុំមិនចាំសក្ខីកម្មរបស់លោកស្រី ឡៃហ្សូរ នោះទេ>។ <បើសិនណាលោកមេធាវី ចង់ប្រើប្រាស់សក្ខីកម្មអ្នកទាំងបីនេះ ហើយដាក់បង្ហាញនោះ លោកមេធាវីត្រូវតែដកស្រង់សិន> បើមិនអ៊ីចឹងទេ វាធ្វើឲ្យមានការយល់ច្រឡំ ហើយគាត់ក៏អាចនឹងសួរបែបសំណួរនាំមុខសាក្សីទៀតផង។

**លោក វ៉ិចទ័រ កូប៉េ៖**

<ខ្ញុំអាច>ខាតបង់ពេលវេលារបស់ខ្ញុំ<ហើយ ខ្ញុំសូមអានចម្លើយរបស់លោក ឱ ហូ វិញ។ ខ្ញុំគិតថា គាត់បានបញ្ជាក់អំពីចម្លើយឈ្មោះ សុខា រួចហើយ>។ ឥឡូវ ខ្ញុំសូមរៀបសំណួរឡើងវិញ <ហើយបញ្ចប់ការពិភាក្សាដេញដោលនេះ។>លោកប្រធាន <ប្រសិនលោកអនុញ្ញាត>។

**សួរដោយលោក វ៉ិចទ័រ កូប៉េ៖**

**ស៖** លោកស្រីដើមបណ្ដឹងដើមបណ្ដឹងរដ្ឋប្បវេណី នៅពេលលោកស្រី<បានចាកចេញទៅធ្វើការ>នៅពេលព្រឹក។ <តើ>ពេលហ្នឹងលោកស្រីមាននាឡិកាមើលដែរទេ លោកស្រីពេលហ្នឹង?

**លោកស្រី ហ៊ុន សិត្ថានី៖**

**ឆ៖** មាន។ គេមានអ្នកមូលដ្ឋានហ្នឹង គេមាន។ កាលណា ពួកញ្ចេហ្នឹង ខែមុនដំបូងហ្នឹង គឺគេដាស់ពីម៉ោងបីកន្លះ ម៉ោងបួន។ អត់ទៀងដែរ ជួនកាលគេងខកអ៊ីចឹងទៅ។ មេផ្អុកញ្ចេហ្នឹងគេងខកអីទៅវាចំណាញយើងដែរ កន្លះម៉ោងអ៊ីចឹងទៅ។ អ្នកដែលជម្រាបលោកថា ម៉ោងប្រាំពីរធ្វើការហ្នឹង ប្រហែលជាគេមេក្រុមអ្នកមូលដ្ឋានអីហ្នឹងហើយ គេអាចមានសិទ្ធិទៅក្រោយ។ ចំណែកយើងប្រជាជនធ្វើការយើងត្រូវតែងើបទៅមុនគេ។

**ស៖** លោកតំណាងសហព្រះរាជអាជ្ញាលោកស្ដាប់ឮហើយ។ លោកស្រីដើមបណ្ដឹងរដ្ឋប្បវេណីការងារពេលព្រឹកបញ្ចប់នៅម៉ោងដប់មួយ គឺគេឱ្យឈប់សម្រាកនៅពាក់កណ្ដាល<វគ្គការងារ>ពេលព្រឹក។ តើត្រឹមត្រូវទេ ដែលថាលោកស្រីចាប់ផ្ដើមធ្វើការនៅម៉ោងប្រាំពីរ <ដោយគណនាពេលវេលាក្នុងចិត្តខ្លួនឯងឬ>?

[១៤:០៣:៣៤]

**ឆ៖** សម្រាក១៥នាទីមានមែន។ តែរឿងការងារមិនដែលមានដល់ម៉ោងប្រាំពីរទេ គឺម៉ោងប្រាំមួយហ្នឹងចាប់ផ្ដើមហើយ ខាងខ្ញុំហ្នឹងមិនដែលបានម៉ោងប្រាំពីរទេ។ មិនដែលសោះ គឺម៉ោងប្រាំមួយម៉ោងប្រាំបួន ឬប្រាំបួន ដប់នាទីនេះ គេឱ្យសម្រាក១៥នាទី។ ឡើងមកធ្វើការវិញ ម៉ោងដប់មួយ សម្រាកម៉ោងមួយចុះ ម៉ោងបីជាងបន្តិចហ្នឹង ក៏សម្រាកបន្តិចដែរ ហើយម៉ោងប្រាំហ្នឹងបានសម្រាកហូបបាយ។ ល្ងាចម៉ោងប្រាំ ម៉ោងប្រាំមួយ ចុះធ្វើការវិញ រហូតដល់ម៉ោងដប់បានត្រឡប់ទៅរោងឯត្រពាំងជ្រៃវិញ។

**ស៖** សូមអរគុណលោកស្រី។ ខ្ញុំបានឮនូវអ្វីដែលខ្ញុំ<ចង់>ឮហើយ។ ឥឡូវនេះ ខ្ញុំបន្តនិយាយអំពី<ការរៀបចំ>បាយថ្ងៃត្រង់វិញ។ តើ<លោកស្រីដាក់វេនគ្នារៀបចំអាហារសម្រាប់>បាយថ្ងៃត្រង់ដែរទេ?

**ឆ៖** ខ្ញុំមានពេលម្ដងដែលចុងភៅគាត់មានធុរៈទៅផ្ទះ កូនគាត់ឈឺ នោះត្រូវខ្ញុំអត់ស្រួលខ្លួននុំងពួចុងភៅហ្នឹងគាត់ឱ្យខ្ញុំទៅជួយគេបានម្ដងដែរ។

**ស៖** នៅពេលមួយដែលលោកស្រីមិនស្រួលខ្លួន គឺនៅពេលដែលលោកឈឺពោះ<ខ្លាំង> ហើយលោកស្រីបានស្នើសុំ អាន ឈប់សម្រាកមិនទៅធ្វើការទេ។ តើលោកស្រីសុំគាត់នៅពេលព្រឹកមុនចេញដំណើរទៅកន្លែងធ្វើការ ឬក៏លោកស្រីសុំនៅពេលកំពុងតែធ្វើការ<នៅការដ្ឋាន>?

[១៤:០៦:៣២]

**ឆ៖** ខ្ញុំមករដូវហ្នឹងឯង គឺតាំងពីយប់ម្ល៉េះ តែខ្ញុំនៅតែទៅធ្វើការ។ ដែលយើងរែកដីទៅប្រហែលជាវាធ្ងន់ ឬក៏វាយ៉ាងម៉េច រដូវខ្ញុំអត់ធ្លាក់មកទេ ខ្ញុំចុកពោះ។ ខ្ញុំចុកពោះហ្នឹងគឺញ័រតែម្ដង ញ័រជើង ញ័រដៃ រែកដីអត់កើត។ អ៊ីចឹងបាយក៏ហូបអត់កើតដែរថ្ងៃនុ៎ង។ ហើយក៏ខ្ញុំសូម -- ខ្ញុំមិនទាន់ទាំងបានសុំនេះផង គ្រាន់តែឃើញខ្ញុំអ៊ីចឹង ប្រធានកងហ្នឹងគាត់ថា ឲ្យគេម្នាក់ហ្នឹងជូនខ្ញុំមករោង ប្រហែលជាមើលមកហ្នឹងឃើញខ្ញុំសភាពរាងធ្ងន់ធ្ងរដែរ ព្រោះខ្ញុំមិនដែលឈឺ។ ឈឺអីម្ដងហ្នឹងដូចរាងធ្ងន់ធ្ងរ ថាស្លេកមុខ ស្លេកអីខ្ញុំៗមិនដឹងថាខ្លួនខ្ញុំស្លេកអីទេ។ បើប្រធានកងហ្នឹងប្រាប់ខ្ញុំថា "ម៉េចក៏ស្លេកម៉េចថ្ងៃហ្នឹង?" ខ្ញុំថា ខ្ញុំចុកពោះណាស់បងអើយមករដូវ ប៉ុន្តែឥឡូវនេះវាអត់ឃើញ តាំងពីម៉ោងប្រាំបួនព្រឹកមកនេះ ព្រោះពីយប់ខ្ញុំមានស្រាប់តែតាំងពីម៉ោងប្រាំបួនព្រឹកមកអត់មក ខ្ញុំចុកពោះម្ដងបន្តិចៗ ចុករហូតដល់ញ័ររែកដីមិនកើតនេះ។ គេក៏អនុញ្ញាតឲ្យខ្ញុំមកទៅ រួចខ្ញុំក៏ថាអ៊ីចឹងខ្ញុំសូមសម្រាកមួយល្ងាចអ៊ីចឹង។ គេក៏អនុញ្ញាតឲ្យខ្ញុំមក អាន ហ្នឹងនោះ។

**ស៖** ហើយនៅពេលដែលលោកស្រីសុំច្បាប់ អាន តើ អាន យល់ព្រមភ្លាមៗ<ថា មិនអីទេ ហើយ>ឲ្យលោកស្រីវិលត្រឡប់មករោង ដើម្បីសម្រាក ឬក៏យ៉ាងណា?

**ឆ៖** ដំបូងគេរាងអេះអុញ ដល់ឃើញខ្ញុំរញីរញ័រហ្នឹងទៅហ្នឹង បានគេប្រាប់ថាឲ្យខ្ញុំមានមនុស្សម្នាក់ឲ្យជូនខ្ញុំទៅរោងទៀត។ ដើរឈប់ៗ ព្រោះញ័រជើង ញ័រដៃ។ អ្នកដទៃទេដែលប្រាប់ខ្ញុំថា អីក៏ស្លាំងម្ល៉េះ ខ្ញុំមិនដឹងថាខ្លួនឯងហ្នឹងស្លេកស្លាំងទេ ប៉ុន្តែដឹងថាញ័រ។ ដឹងថាខ្លួនឯងហ្នឹងញ័រៗជើង ញ័រដៃទទ្រាក់ទទ្រើត។

[១៤:០៩:១៧]

**ស៖** លោកស្រីព្រឹកមិញ លោកស្រីបាននិយាយបុរសចំណាស់ម្នាក់នៅក្នុងក្រុមរបស់លោកស្រី គឺបុរសម្នាក់ក្នុងចំណោមប្រជាជនទាំង ៨០នាក់ ដែលលោកស្រីបានឆ្លើយថា គាត់បានស្លាប់ទៅ។ លោកស្រីចាំទេ មានអ្វីកើតឡើងចំពោះបុរសម្នាក់នេះ<?> តើគាត់ធ្លាក់ខ្លួនឈឺ<នៅពេលណាមួយ> ហើយមានសុំច្បាប់<សម្រាកទទួលព្យាបាល>ពេទ្យ <ឬក៏ក្រោយមក ប្រហែលជាគាត់ទៅកន្លែងណាផ្សេងដែរ ឬទេ>? ពាក់ព័ន្ធនឹងបុរសចំណាស់ម្នាក់នេះ តើលោកស្រី<>អាចជម្រាបជូនអង្គជំនុំជម្រះឲ្យលម្អិតបន្តិចបានទេ <តើមានរឿងអីកើតឡើងចំពោះគាត់>?

**ឆ៖** ចាស បាន តែគាត់នុ៎ងមិនមែនបុរសចំណាស់ទេ គ្នានៅលីវទេ អាយុប្រហែលជា២០-២១ ប៉ុណ្ណឹង គ្នានៅលីវ អ្នកមូលដ្ឋានទេ អ្នកច្បាស់លាស់ ធ្វើការងារអត់គិតពីកម្លាំងខ្លួន។ ប្រឹងៗទាល់តែឈឺ

ខក គ្មានបានទៅសម្រាកពេទ្យឯណាទេ ទៅផ្ទះវិញកន្លះខែ គេស្លាប់។ ឪពុកម្ដាយគ្នា មានកូនប្រុសតែពីរម្នាក់ហ្នឹងឈ្មោះ រី ជាកូនទី២ហ្នឹង បានស្លាប់ទៅ ទៅដល់ផ្ទះកន្លះខែ ស្លាប់។

**ស៖** ដូច្នេះ បុរសម្នាក់នេះ អ្នកមូលដ្ឋានម្នាក់នេះ <>គាត់<បាន>ស្នាក់នៅក្នុងភូមិរបស់លោកស្រី<អស់រយៈពេល១៤ថ្ងៃ មុនពេលស្លាប់, អ៊ីចឹងត្រឹមត្រូវទេ>?

**ឆ៖** ស្នាក់នៅភូមិជាមួយខ្ញុំ រំលងផ្ទះប្រហែលប្រាំមួយផ្ទះ។

**ស៖** ប៉ុន្តែមុនពេលគាត់ស្លាប់ទៅ គឺគាត់ដេកឈឺសម្រាក ដេកឈឺហ្នឹង ប្រហែលជា១៤ថ្ងៃ បើតាមស្ដាប់ឮ។ អ៊ីចឹងមែនទេ?

[១៤:១១:៤៦]

**ឆ៖** ចាស ប្រហែលប៉ុណ្ណឹង ចេះតែទ្រោមទៅៗ។ ពេទ្យនោះមានថ្នាំឯណា មានតែថ្នាំដប ដូចខ្ញុំជម្រាបអ៊ីចឹង ហើយនិងថ្នាំអាចម៍ទន្សាយហ្នឹង។ លេបទៅ ចេះតែទៅៗរហូតដល់ថ្ងៃស្លាប់។

**ស៖** តើលោកស្រីដឹងដោយរបៀបណា ដែលថាការស្លាប់របស់គាត់ហ្នឹង<>គឺ<មានអ្វី>ពាក់ព័ន្ធទៅនឹងការងារនៅឯការដ្ឋាន<ទំនប់ដែរ>ទេ?<អ្នកស្រីដឹងដោយរបៀបណា? អ្នកណាជាអ្នកប្រាប់លោកស្រី?>

**ឆ៖** ទេ គ្នាឈឺពីការដ្ឋានមកតើ! ឈឺបន្តិចម្ដងៗ ដែលគ្មានថ្នាំព្យាបាលហ្នឹង បានទៅជាទ្រុឌទ្រោមដល់ថ្នាក់ស្លាប់នេះ។ កាលពីនៅការដ្ឋានហ្នឹង គ្នាដាប់ថ្ម ដាប់អី ធ្វើការធ្ងន់ៗណាស់ លីថ្ម លីអីហ្នឹង។

**ស៖** ខ្ញុំព្យាយាមរៀបចំសំណួរឡើងវិញ។ តើការសន្និដ្ឋានរបស់លោកស្រី -- នេះជាការសន្និដ្ឋានរបស់លោកស្រី ឬក៏អ្នកណាម្នាក់ប្រាប់លោកស្រី? <ខ្ញុំសង្ឃឹមថា> លោកស្រីអាចយល់ហើយ ចំណុចពីរហ្នឹង។ តើមានអ្នកណាម្នាក់ប្រាប់លោកស្រីអំពីមូលហេតុនៃការស្លាប់របស់បុរសម្នាក់នេះដែរ--បុរសក្មេងម្នាក់នេះៗ?

**ឆ៖** គ្មានអ្នកណាប្រាប់ទេ គឺខ្ញុំឃើញ ខ្ញុំដឹងនឹងភ្នែកហ្នឹងណា៎ ព្រោះនៅភូមិ នៅផ្ទះក្បែរគ្នារំលងប្រាំ ប្រាំមួយផ្ទះហ្នឹង ប៉ុន្មានទៅ!

[១៤:១៤:០៨]

**ស៖** តើលោកស្រីបានឃើញ នៅ<សម្រាកទេ? គឺ>ចំថ្ងៃទី១០ ដែល<លោកស្រីត្រឡប់ទៅភូមិវិញ។ តើនេះជាអ្វីដែលលោកស្រីចង់និយាយឬ>?

**ឆ៖** ពេលការដ្ឋានចប់ហ្នឹង ត្រឡប់មកផ្ទះហ្នឹង ខែ៦ហ្នឹង ស្លាប់នៅក្នុងខែ៦ហ្នឹង។

**ស៖** តើលោកស្រីចាំទេ មានរយៈពេល -- វាមានរយៈពេលប៉ុន្មានថ្ងៃដែរ បន្ទាប់ពីចប់ពីធ្វើការងារ ហើយ លោកស្រីបានឃើញបុរសម្នាក់ហ្នឹងដេកនៅក្នុងផ្ទះរបស់គាត់ហ្នឹង មានរយៈពេលប៉ុន្មានថ្ងៃដែរ?

**ឆ៖** ដូចខ្ញុំជម្រាបហើយ មកពីការដ្ឋានហ្នឹងប្រហែលជាកន្លះខែ តាមការស្មានទៅថាប៉ុណ្ណឹងទៅចុះ ព្រោះពេលវា -- ដូចជិតដែរ។

**ស៖** <ខ្ញុំយល់ថា>បុរសក្មេងនោះគឺធ្លាក់ខ្លួនឈឺនៅថ្ងៃចុងក្រោយ គឺធ្លាក់ខ្លួនឈឺនៅៗ<ថ្ងៃចុងក្រោយនៃ>ការងារ<នៅភូមិលោកស្រី>នៅឯ<ការ>ដ្ឋានហ្នឹង។ អ៊ីចឹងមែនទេ?

**ឆ៖** ចាស ឈឺបន្តិចៗ តែមានៈទៅតែធ្វើការទៀត។ ចេះតែគិតថាខ្លួនឯងមិនអីមើលទៅបានជាឃើញទៅៗហ្នឹង ដល់ការដ្ឋានចប់ត្រឡប់មកផ្ទះហ្នឹង ខ្ញុំប្រមាណមើលទៅថាកន្លះខែហ្នឹង គឺស្លាប់។

[១៤:១៦:១៧]

**ស៖** សូមអរគុណលោកស្រី។ ឥឡូវខ្ញុំសូមសួរអំពីកុមារៗមកពីភូមិរបស់លោកស្រីដែលលោកស្រីក៏បានឆ្លើយដែរថាទៅធ្វើការនៅឯការដ្ឋានការងារនោះដែរ។ តើលោកស្រីចាំឈ្មោះក្មេងៗទាំងនេះទេ?

**ឆ៖** ខ្ញុំចាំពីរនាក់បងប្អូននោះ ឈ្មោះ -- អាមួយឈ្មោះគេ ការ៉ុង ប្អូនគេឈ្មោះ ការើន អាមួយទៀតនោះឈ្មោះ អាតុតៗ ហ្នឹងឯងស្គមខ្ពស់ដៃជើងវល្លិ៍ៗ ហើយប៉ុន្មានទៀតភ្លេចឈ្មោះហើយ។

**ស៖** តើកុមារទាំងអស់នេះទៅ<តាមឪពុកម្ដាយ>របស់គេ ដែលធ្វើការនៅឯការដ្ឋាននោះដែរឬក៏យ៉ាងណា?

**ឆ៖** អត់ទេ គ្មានម៉ាក់គេទៅទេ គឺគេចាត់តាំងចល័តទី២ ហ្នឹងឲ្យមកតែម្ដង ម្ដាយនៅភូមិ ឪពុកនៅភូមិ។

**ស៖** តើ<ការងារមួយក្នុងចំណោមការងារផ្សេងរបស់គេគឺត្រូវ> ដើរកើបអាចម៍គោ តើអ៊ីចឹងមែនទេ?

**ឆ៖** ចាស អត់ទេ គឺរែកដីជាមួយមនុស្សចាស់។

**ស៖** តើលោកស្រីអាចដឹងអំពីអាយុរបស់កុមារៗទាំងនោះបាន<ដោយរបៀបណា> នៅពេលនោះ?

**ឆ៖** ក្មេងអស់ហ្នឹងប្រមាណជាបើមិនប្រាំបួន ១០ ត្រឹម១៣ចុះក្រោមហ្នឹង ប៉ុណ្ណឹង មិនស្រួល

១២អីហ្នឹងផងមិនដឹង។

**ស៖** តើអ្នកណាជាអ្នកជ្រើសរើសកុមារ<ពីរបីនាក់>នេះឲ្យទៅធ្វើការនៅទីនោះ? តើ អាន ឬក៏មិនមែនទេ?

**ឆ៖** មិនមែន អាន ទេ គឺប្រធានភូមិ។ ប្រធានភូមិតែម្តង ចាត់តាំងឲ្យមកហ្នឹង។

**ស៖** យើងខ្ញុំបានស្តាប់ឮពីសាក្សីម្នាក់ក្នុងចំណោមសាក្សីបីនាក់កាលពីសប្តាហ៍មុនដែលជាប្រធាន -- គាត់ធ្វើជាប្រធានភូមិដែរថា មានតែអ្នកមានកម្លាំងទេទើបអាចជ្រើសរើសទៅធ្វើការលើកទំនប់ជីកប្រឡាយហ្នឹង។ នៅពេលនោះ <តើ>លោកស្រី<នៅចាំថា>ធ្លាប់<មានការពិភាក្សាណាមួយ អំពីមូលហេតុនាំឲ្យមាន>ការជ្រើសរើសកុមារ<ពីរបីនាក់នេះ ទៅបម្រើ>ការងារនៅការដ្ឋាន<ទំនប់ ដែរឬទេ>?

**ឆ៖** ភូមិគេខ្ញុំមិនដឹង។ ខ្ញុំដឹងតែភូមិខ្ញុំមានក្មេងទៅរែកដីជាមួយ ចល័តទី២។ ចំណែកភូមិគេ ខ្ញុំអត់ដឹង។

[១៤:២០:៣៥]

**ស៖** លោកស្រីនៅចាំឈ្មោះប្រធានភូមិរបស់លោកស្រីទេ?

**ឆ៖** ប្រធានភូមិខ្ញុំ ឈ្មោះ អុល។ តែឥឡូវគាត់ស្លាប់បាត់ហើយ។ អុល ហ្នឹងឯងរាងខ្ពស់ដៃជើងវែងៗ ខ្ពស់ប្រហែលចង់ ១,៨០ម៉ែត្រ ឯណោះ។

**ស៖** តើលោកស្រីដឹងថា មានអ្នកណាម្នាក់ដែលនៅក្នុងចំណោមប្រជាជនទាំង ៨០នាក់ <មក> ពីភូមិលោកស្រីហ្នឹងនៅរស់រានមានជីវិតមកដល់សព្វថ្ងៃនេះទេ?

**ឆ៖** អ្នកថ្មី ឬក៏អ្នកចាស់?

**ស៖** អ្នកណាក៏បានដែរ ឲ្យតែក្នុងចំណោមប្រជាជន ៨០នាក់ មកពីភូមិលោកស្រីហ្នឹង?

**ឆ៖** អ្នកថ្មី គឺមានឈ្មោះ មឿន សាក់ នោះពីរនាក់ប្តីប្រពន្ធ។ ខ្ញុំពីរនាក់ប្តីប្រពន្ធ។ ហើយមានឈ្មោះ បងរី មួយនៅខេត្តកំពង់ធំសព្វថ្ងៃនេះ។ ឈ្មោះអាម៉ម ហើយនិងប្អូនអាម៉ម មួយទៀតនោះ ខ្ញុំភ្លេចឈ្មោះ។ អ្ហូ! នៅឈ្មោះ សារឿន គេបានទៅធ្វើបន្តិចគេត្រឡប់មកភូមិវិញ តែគេស្លាប់ប្រហែលជា មួយអាទិត្យហ្នឹងបាត់ហើយ។ ភូមិខ្ញុំរស់បានតែប្រហែលជា ប្រាំបី ទៅ ប្រាំបួននាក់ទេ អ្នកថ្មី អស់រលីង ៣០ ទៅ ៤០គ្រួសារគឺអស់។ គឺនៅសល់តែ បងរី ហ្នឹងពីរនាក់ប្តីប្រពន្ធគាត់ ម្តាយគាត់មួយ និងប្អូនគាត់បី ហើយនិងកូនគាត់ពីរ។ ហ្នឹងគ្រួសារហ្នឹង ឃើញនៅបានប៉ុណ្ណឹង ហើយនិងពួកខ្ញុំហ្នឹង ប្រាំមួយនាក់

ទៀត។ ខ្ញុំពីរនាក់ប្ដីប្រពន្ធ អាពៅ និង ថុល និងប្ដីប្រពន្ធ ហើយនិង មឿង សាក់ ហ្នឹង តែប៉ុណ្ណឹង។ ក្រៅពីហ្នឹងស្លាប់ រលីងគ្មានសល់។

[១៤:២៣:៣៨]

**ស៖** សូមអរគុណលោកស្រី។ ឥឡូវ ខ្ញុំត្រឡប់ទៅនិយាយអំពីការដ្ឋានការងារវិញ <និង>អំពីអនាម័យវិញម្ដង។ លោកស្រីថា មានរុយ<ច្រើនណាស់>មករោមបាយសម្ល។ លោកស្រី នៅចាំទេ នៅពេលដែលលោកស្រីធ្វើការនៅទីនោះ មានដែលឃើញនរណាម្នាក់មកបាញ់ថ្នាំសម្លាប់សត្វល្អិត <ដើម្បីដេញ>រុយហ្នឹងដែរទេ?

**ឆ៖** សំណួរនេះ ខ្ញុំចង់អស់សំណើចណាស់លោក ព្រោះវាគ្មានស្អីសោះទទេស្អូន្យ ម៉េចពាក្យថាស្អូន្យនោះ។ គឺគ្មានៗស្អីទេ ដូចខ្ញុំជម្រាបព្រឹកមិញអ៊ីចឹង រុយដែលចូលទៅនៅក្នុងចានសម្លហ្នឹងគឺនាំគ្នាយកដៃ ឬក៏យកស្លាបព្រាហ្នឹងឆ្កឹះតែរុយចេញទេ សូម្បីតែដួសឲ្យដោយទឹកសម្លមកជាមួយរុយក៏មិនហ៊ានដួសផង។ វាស្ដាយសម្ល។ ចង្អុលដៃហ្នឹងឆ្កឹះមកសុទ្ធតែរុយក្បាលខៀវ ខ្ញុំមិនកុហកទេ។ ទាំងគេទាំងខ្ញុំ ហូបទៅមកដល់ហើយនោះ ឃ្លានហើយនោះ។ គិតពីអនាម័យអី ឲ្យតែបានហូបហ្នឹង វាពិសេសហើយ មានសម្លទឹកហុត ពិសេសណាស់។ នឹកថាមានកម្លាំងរស់មួយថ្ងៃទៀតហើយ។ រុយប៉ុនណាក៏ដោយ លែងគិតហើយ។ បើរឿងថាទៅបត់ជើងធំវិញ ដូចគេចាក់និតគ្នាអ៊ីចឹង ជ្រៀតជើងមិនចុះទេ។ អ៊ីចឹងហើយបានវាកើតរុយយ៉ាងហ្នឹងនោះ គ្មានរុយតូចទេ សុទ្ធតែក្បាលខៀវ។

**ស៖** លោកស្រីដើមបណ្ដឹងរដ្ឋប្បវេណី សូមលោកស្រីគ្រាន់តែឆ្លើយថា ទេ ឬក៏ ចាស <មកបានហើយណា>។ តើមានអ្នកមកបាញ់ថ្នាំសម្លាប់សត្វល្អិតនៅក្បែរបង្គន់ ក្បែរផ្ទះបាយ ក្បែរកន្លែងលោកស្រីធ្វើការដែរ ឬក៏អត់? បាទ សូមឆ្លើយ "ចាស" ឬក៏ "ទេ" ទៅបានហើយ?

**ឆ៖** ទេ គឺអត់មាន។

[១៤:២៦:៣៤]

**ស៖** លោកស្រីនិយាយអំពី<ការចំអិន>សម្ល ហើយរុយទាំងអស់ហ្នឹងហើរចូលក្នុងសម្ល។ តើសម្លនេះ គេស្លនៅឯកន្លែងផ្ទះបាយហ្នឹង ឬក៏យ៉ាងម៉េច?

**ឆ៖** សម្លហ្នឹង គេស្លកន្លែងដែលយើងគេងហ្នឹង នៅវត្តត្រពាំងជ្រៃហ្នឹង ស្លពីនុ៎ងមក។ គេចាត់កម្លាំងឲ្យសែងមក សែងសម្លហ្នឹងពីរនាក់ សែងបាយហ្នឹងពីរនាក់។ ស្លឯវត្តត្រពាំងព្រៃហ្នឹង កន្លែងសម្រាកហ្នឹង។

**ស៖** ប៉ុន្តែតើចុងភៅនៅឯផ្ទះបាយ គេមានបង្កាត់ភ្លើងអីដើម្បីកម្តៅសម្លហ្នឹងឡើងវិញដែរអីដែរ ឬក៏អត់ទេ?

**ផ៖** គ្មានៗទេ។

**ស៖** ដូច្នេះ នៅផ្ទះបាយ នៅឯកន្លែងការដ្ឋានហ្នឹងតែម្តង គឺថាគេអត់មានបង្កាត់ភ្លើងអី ដាំស្ល ឬក៏កម្តៅឡើងវិញនោះទេ។ អ៊ីចឹងមែនទេ?

**ផ៖** ខ្ញុំជម្រាបថាគ្មានទេ តែគេស្លធ្អិនហើយ ដាក់ចុះមកហើយ សែងទៅហើយ គ្មានទៅកម្តៅអីទៀតទេ។ ធ្វើការអស់កម្លាំង អរឱ្យតែគេសែងបាយទៅដល់ ដល់ម៉ោងហ្នឹង ន្ទាលនឹងហូប។

**ស៖** ឥឡូវ ខ្ញុំមានសំណួរមួយផ្សេងទៀត លោកស្រីឆ្លើយកាលពីព្រឹកមិញនេះថា ប្រសិនបើជាអ្នកណាម្នាក់ គឺប្រជាជនមូលដ្ឋានអាចប្រកែកមិនទៅធ្វើការនៅឯការដ្ឋានបាន។ លោកស្រីអាចលើកជាឧទាហរណ៍ណាមួយបានទេ។ ឧទាហរណ៍ដែលថា អ្នកមូលដ្ឋានអាចបដិសេធមិនទៅធ្វើការនៅឯការដ្ឋានការងារបែបនោះបាន?

**ផ៖** មាន ព្រោះនៅនឹងមុខខ្ញុំ។ ខ្ញុំដើរទៅដល់ហ្នឹង ឮគាត់សួរថា “ខុមៗ ទៅការដ្ឋាន១មករាទេ? គេថា អឺ! ខ្ញុំមិនទៅទេ កន្លែងហ្នឹងចាញ់” ខ្ញុំឮប្រកែកអ៊ីចឹង។ ប្រធានភូមិហ្នឹងងាកមករកខ្ញុំ “មិត្តនី, មិត្តរឿន ទៅការដ្ឋានទេ? ខ្ញុំថា ខ្ញុំទៅ” យើងឯណាប៉ានទៅប្រកែកថាទេនោះ។

[១៤:៣០:០០]

**ស៖** អ្នកដែលឆ្លើយថា “អត់ទេ ខ្ញុំអត់ចង់ទៅទីនោះទេ ព្រោះនៅទីនោះ កើតមាននៅជំងឺគ្រុនចាញ់”។ អ៊ីចឹងគាត់<ហ្នឹងនៅក្នុងភូមិឬ>?

**ផ៖** អត់ទេ ថ្ងៃក្រោយក៏គេបញ្ជូនម្នាក់ហ្នឹងទៅដែរ។

**ស៖** ដូច្នេះ អ្នកមូលដ្ឋានម្នាក់នេះ ក៏ត្រូវគេបញ្ជូនឱ្យទៅធ្វើការជាមួយអ្នកមូលដ្ឋានផ្សេងទៀតនៅឯការដ្ឋានការងារនុ៎ង។ អ៊ីចឹងមែនទេ?

**ផ៖** មែន។

**ស៖** តើវាជាការត្រឹមត្រូវដែរទេថា ប្រជាជនទាំង៨០នាក់ មកពីភូមិរបស់លោកស្រីហ្នឹង នៅពេលទៅដល់កន្លែងធ្វើការហ្នឹង គឺថាធ្វើការងារដូចៗតែគ្នាទេ។ អ៊ីចឹងឬក៏អត់?

**ផ៖** ចាស ធ្វើការដូចៗតែគ្នាហ្នឹង។

**ស៖** ដូច្នេះ នៅការដ្ឋានការងារ គឺមិនមានការប្រព្រឹត្តខុសៗគ្នា មកលើប្រជាជនថ្មី និងប្រជាជន

មូលដ្ឋានទេ។ អ៊ីចឹងឬក៏អត់?

**ឆ៖** គ្រាន់តែថា អ្នកចាស់គេប៉ានតមាត់ គេប៉ានប្រកែកប្រណាំងបាន ព្រោះគ្នាគេ។ យើងអ្នកថ្មី អត់ទេ តែគេចង្អុលឆ្វេង ឆ្វេង ចង្អុលស្ដាំ ស្ដាំ។ សុខចិត្តគ្រាំក្នុងខ្លួនទៅ គេថាម៉េចថាទៅ កុំឱ្យតែគេយកទៅសម្លាប់ហ្នឹង ប្រសើរហើយ។

**ស៖** ប៉ុន្តែពាក់ព័ន្ធនឹងការងារ បរិមាណការងារ គឺប្រជាជនទាំង៨០នាក់មកពីភូមិរបស់លោកស្រី ត្រូវបានគេប្រើឱ្យធ្វើការងារដូចៗគ្នា។ ត្រឹមត្រូវទេ?

**ឆ៖** រឿងការងារគឺដូចៗគ្នា គ្មានអ្នកណាគេចវេះទេ យើងអ្នកថ្មីហ្នឹង រឹតតែមិនប៉ានគេចវេះហើយ។ គេអ្នកចាស់គ្រាន់ថាទៅឈរត្រង់នេះ ត្រង់នោះអីបានបន្តិចបន្តួច គេអនុគ្រោះគ្នាគេ។ រឿងការងារ ធ្វើដូចតែគ្នាហ្នឹង គ្រាន់តែគេមានសិទ្ធិលើយើងបន្តិច។

**ស៖** ខ្ញុំយល់បញ្ហានេះហើយ ប៉ុន្តែពាក់ព័ន្ធទៅនឹងបរិមាណការងារ ប្រភេទការងារ ចំនួនម៉ោងការងារ គឺប្រជាជនទាំងអស់នៅក្នុងក្រុមរបស់លោកស្រី<ទាំង៨០នាក់>ហ្នឹង ធ្វើដូចៗគ្នា មានពេលម៉ោងដូចៗគ្នា។ ត្រឹមត្រូវទេ?

**ឆ៖** ចាស ត្រឹមត្រូវ។

[១៤:៣៣:៣២]

**ស៖** ប្រហែលជាខ្ញុំស្ដាប់សក្ខីកម្មលោកស្រីពីខាងដើមមិនច្បាស់ក៏ថាបាន <ប៉ុន្តែ ខ្ញុំពិតជាបានឮលោកស្រីនិយាយថា មានការបែងចែកប្រជាជនថ្មី និងប្រជាជនចាស់ក្នុងចំណោម>មនុស្សទាំង៨០នាក់ហ្នឹង< គឺប្រហែលពាក់កណ្ដាលៗ។ តើខ្ញុំយល់នេះត្រឹមត្រូវដែរទេ> លោកស្រី?

**ឆ៖** មិនបែងចែកទេ គឺយើងធ្វើការទាំងអស់គ្នា ព្រោះគេវាស់ដីឱ្យហ្នឹង ដូចថាភូមិយើងគេប្រគល់ឱ្យប៉ុន្មាន ១០០ម៉ែត្រ ឬក៏៥០ម៉ែត្រអ៊ីចឹង យើងចុះធ្វើទាំងអស់គ្នាទៅ។ បែងចែកហ្នឹង មានតែខាងក្រុមកងចល័តអីទេ។ បើថារឿងតាមភូមិនេះ គឺមិនដែលបែងចែកទេ។ ទាល់តែចែកហ្នឹង ចែកដូចថា គេវាស់ដីឱ្យ ម្នាក់១ម៉ែត្រគូប, ពីរនាក់ ២ម៉ែត្រគូប ឬក៏បីនាក់ ២ម៉ែត្រគូបអ៊ីចឹងទៅ គេឱ្យប្រុសម្នាក់ និងស្រីពីរនាក់អ៊ីចឹងទៅ។

**ស៖** សូមអធ្យាស្រ័យ ប្រហែលជាសំណួរខ្ញុំវាមិនច្បាស់ទេមើលទៅ។ <ខ្ញុំចង់សួរថា> បើខ្ញុំយល់មិនច្រឡំទេ មនុស្សទាំង៨០នាក់នេះ គឺគេមានមនុស្សប្រជាជនចាស់ ប្រជាជនថ្មី ចម្រុះគ្នា គឺថាពាក់កណ្ដាលម្នាក់។ អ៊ីចឹងមែនទេ?

*ប្រតិចារិកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឱ្យមានភាពស្របគ្នារវាងប្រតិចារិកក្នុងភាសាទាំងបី។ ប្រតិចារិកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារិកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

**ឆ៖** ខាងខ្ញុំស្រី ខាងស្រីៗហ្នឹង ខាងអ្នកថ្មីហ្នឹងតិចទេ។ ខាងប្រុសៗប្រហែលជាស្មើគ្នាយ៉ាង។

**ស៖** សូមអរគុណលោកស្រី។

[១៤:៣៥:៣៨]

**លោក វ៉ិចទ័រ កូប៉េ៖**

លោកប្រធាន ខ្ញុំជិតអស់សំណួរហើយ នៅសល់ប្រហែលជាពីរបីសំណួរទៀត។ តើគួរឈប់សម្រាកសិន ឬក៏យ៉ាងម៉េចលោកប្រធាន?

**ប្រធានអង្គជំនុំ៖**

អញ្ជើញតទៅទៀតទៅ មិនទាន់ដល់ម៉ោងសម្រាកឯណា។

**សួរដោយលោក វ៉ិចទ័រ កូប៉េ៖**

**ស៖** លោកស្រីដើមបណ្ដឹងរដ្ឋប្បវេណី លោកស្រីដែលស្ដាប់ឮតាមមីក្រូដែលគេចាក់នៅការដ្ឋានគឺទំនប់១មករា គេហៅថា "សមរភូមិក្ដៅ"។ លោកស្រីដែលឮគេនិយាយតាមមីក្រូអីចឹងទេ?

**លោកស្រី ហ៊ុន សិត្ថានី៖**

**ឆ៖** ដែល ព្រោះមីក្រូចាក់រាល់ថ្ងៃ មានតាំងពីចម្រៀង មានតាំងពីរឿង រឿងបដិវត្តន៍ហ្នឹង។ គេគ្មាននិយាយពីអីក្រៅពីរឿងសម្រុកការងារទេ។

**ស៖** <>តើអ្នកដែលនិយាយមីក្រូហ្នឹងបានពន្យល់ទៅដល់កម្មករ ហើយ<ពន្យល់>ប្រាប់ថា<កម្មករថា> ហេតុអ្វីបានគេហៅទំនប់១មករា –ការដ្ឋាន១មករា– ថាជាសមរភូមិក្ដៅដែរទេ?

[១៤:៣៧:៣៩]

**ឆ៖** ទីនោះប្រាកដជាសមរភូមិក្ដៅ ព្រោះពេលសម្រុកការងារបិទស្ទឹងបិទអីហ្នឹង គឺថាមនុស្សគឺយកទៅបណ្ដើរៗ សម្លាប់បណ្ដើរៗទៀត។ ការងារសម្រុក មនុស្សក៏សម្រុកសម្លាប់ដែរ។ បានជាគេហៅ "សមរភូមិក្ដៅ"ហ្នឹងនោះ។

**ស៖** តើលោកស្រីខ្លួនឯងផ្ទាល់ ដែលធ្លាប់បានទៅធ្វើការនៅទំនប់៦មករាដែរទេ?

**ឆ៖** អត់ទេ។

**ស៖** តើលោកស្រីដឹង ឬក៏នៅចាំថា មុនពេលលោកស្រី និងអ្នក<មកពី>ភូមិចាប់ផ្ដើមទៅធ្វើការនៅទំនប់ហ្នឹង គឺវាមានភាពរាំងស្ងួតនៅក្នុងប្រទេសកម្ពុជា ហើយ<ដោយសារតែមានគ្រោះរាំងស្ងួតនេះហើយ ទើបមានការខ្វះខាតស្បៀង។>តើលោកស្រីធ្លាប់ដែលឮថាមានភាពរាំងស្ងួតហួតហែងដែរទេ

---

*ប្រតិចារិកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារិកក្នុងភាសាទាំងបី។ ប្រតិចារិកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារិកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

នៅក្នុងប្រទេសកម្ពុជាហ្នឹងមុននោះ?

**ឆ៖** ដូចជាអត់មានទេ។ ជំនាន់ ប៉ុល ពត ហ្នឹងគឺសម្បូរទឹកធ្វើស្រូវបានល្អណាស់ មិនដែលមានភាពរាំងស្ងួតទេ។ តែចុងខែ៦ ចូលខែ៧ហ្នឹងចាប់ផ្ដើមហើយធ្វើស្រែ ដូចមិនដែលបានរាំងស្ងួតទេ។ បើស្រុកគេមិនដឹង បើខាងបារាយណ៍ខ្ញុំហ្នឹង ឃុំបារាយណ៍ហ្នឹងគ្មានទេ គ្មានរាំងស្ងួតទេ។

[១៤:៣៩:៣៥]

**ស៖** មុនពេលលោកស្រីចាប់ផ្ដើមធ្វើការនៅការ<ដ្ឋាន>ទំនប់<ហ្នឹង> នៅកន្លែងលើកទំនប់ហ្នឹង តើលោកស្រីមានដែលឮថាមានការខ្វះចំណីអាហារដោយសារតែសង្គ្រាម អ៊ីចឹង ដោយសារតែសង្គ្រាម<នៅមុន ពេលរំដោះខែមេសា ឆ្នាំ១៩៧៥>អ៊ីចឹង ឬក៏អត់ទេ?

**ឆ៖** សូមសំណួរម្ដងទៀត។

**ស៖** តើលោកស្រីធ្លាប់ឮដែរឬទេ មុនពេលលោកស្រីចាប់ផ្ដើមធ្វើការនៅឯទំនប់ហ្នឹង ថាមានការ<ខ្វះខាត>ស្បៀងអាហារ<ក្នុងតំបន់លោកស្រី> ដោយសារតែសង្គ្រាមរហូតមកដល់<ខែមេសា> ១៩៧៥។ ធ្លាប់ដែលឮការខ្វះស្បៀងអាហារហ្នឹងទេ?

**ឆ៖** ខ្វះស្បៀងអាហារក្នុងរបបប៉ុល ពត ហ្នឹង? ខ្ញុំធ្លាប់ឮ ព្រោះប្រជាជនគេថា យោធាគេពលីជីវិតរំដោះយកអ្នកថ្មី អ្នកសមរភូមិក្រោយហ្នឹង គេធ្វើស្បៀងយកទៅផ្គត់ផ្គង់អ្នកសមរភូមិមុខ។ អ៊ីចឹងហើយបានគេមិនចូលចិត្តអ្នក៧៥ នោះ មកឲ្យគេខ្វះស្បៀងអាហារហូប វាលើសរបបមនុស្ស។ យើងមកច្រើនហ្នឹងបានគេហូបមិនគ្រប់គ្រាន់ គេខឹងទាំងយើងទៀត។ តាមការពិតទៅអ្នក៧៥ គ្មានចង់ចេញមកធ្វើអីទេ គេនៅផ្ទះគេមានក្ដីសុខណាស់។ យើងរំដោះគេមកធ្វើអី រួចថាគេមកជាន់ក។

**ស៖** តើមានការខ្វះស្បៀងអាហារដែរទេ នៅក្នុងភូមិរបស់លោកស្រី?

**ឆ៖** នៅក្នុងភូមិខ្ញុំ គឺខ្វះស្បៀង ឲ្យតែរដូវវស្សា មិនដែលបានញ៉ាំអីឆ្អែតទេ គឺបបរលាយត្រកួនដើមត្រកួនហ្នឹង គេហាន់ ហើយគេយកទៅលាយបបរ ហើយគេវាល់វែកចែកគ្នាទៀត។ ជួនកាលបបរសុទ្ធតែទឹក។ ពីខែ៨ ខែ៩ ខែ១០ ខែ១១ ស្រីៗនៅភូមិខ្ញុំគ្មានរដូវទេ ញ៉ាំអត់គ្រប់គ្រាន់ ម្នាក់ៗស្គម ចែកបបរៗរាវ ទាល់តែស្រូវដល់បានៗបាយហូប។ មុននឹងបានបាយហូបគេឲ្យបបរខាប់សិន ព្រោះអត់ទាន់ស្រូវបរិបូណ៍គេត្រូវឲ្យបបរសិន គ្រាន់ថាខាប់ជាមុនបន្តិច។ ក្មេងក្លាយទៅជាមនុស្សចាស់អស់ហើយ អ្នកថ្មីរឹតតែទ្រុឌទ្រោមទៀតហើយ។ អ្នកមូលដ្ឋានគេមានដី គេមានដំណាំអ៊ីចឹងទៅ អាចគាស់ដំឡូងគាត់អីហូប ចំណែកអ្នកថ្មីទទេ ត្រូវភូមិហ្នឹងទឹកលិចផងនោះ ភូមិពោធិ៍ពីរហ្នឹងទឹកលិច ឲ្យខែវស្សាស្រុក

បារាយណ៍ហ្នឹងទឹកលិចរហូត គ្មានបានដាំអីបានញ៉ាំទេ។

[១៤:៤៣:២៥]

**ស៖** សំណួរចុងក្រោយរបស់ខ្ញុំលោកស្រី។ តើគេមានប្រាប់អ្នក<ស្រី ក៏ដូចជាកម្មករ>ធ្វើការនៅទំនប់ ១មករា ហ្នឹងថាគោលបំណងនៃការលើកទំនប់នេះ គឺដើម្បីធានាថាមានទឹកគ្រប់គ្រាន់ដើម្បីស្រោចស្រពវាលស្រែ ដូច្នេះគឺថាវានឹងមិនខ្វះស្បៀងនោះទេ ពីព្រោះថាស្ថានភាពធាតុអាកាសហ្នឹង បើពឹងតែទៅលើមេឃហ្នឹងគឺថាមិនៗបានទេ អ៊ីចឹងត្រូវជីកទំនប់នេះ ដើម្បីកុំឲ្យខ្វះស្បៀង។ <តើនោះជាគោលបំណង ដែលមនុស្សគ្រប់គ្នាធ្វើការជាមួយគ្នានៅការដ្ឋានទំនប់នោះ មែនទេ>?

**ឆ៖** ខ្វះស្បៀងមកពីអី? ច្រូតស្រូវបានហើយគេយកទៅដាក់រួម មិនដឹងគេដឹកចេញទៅណាទេ។ ពេលហូបព្រលឹមឡើងហ្នឹង គឺចុងភៅទៅបើករបបពីសង្កាត់យកមកវិញ ទៅបើករបបស្រូវហ្នឹងយកមកកិនធ្វើជាអង្ករឲ្យអ្នកស្រុកហូបទៅ វាល់វែកចែកគ្នា។ ស្រូវធ្វើបានណាស់ វាលបារាយណ៍ជ្រាបស្រាប់ហើយស្រូវប៉ុនណា ហេតុអ្វីបានជាប្រជាជនអត់? ឃើញតែឡានចូលដឹក។ ដឹកចេញទៅបាត់ៗ រួចគេទុកនឹងសង្កាត់ហ្នឹង។ ខ្ញុំមិនដឹងជាគេដាក់ជង្រុកហ្នឹងអីប៉ុនណាទេ ខ្ញុំមិនដែលហ៊ានទៅដឹងកន្លែងគេហ្នឹងអីទេ ទៅឃើញកន្លែងគេអីទេ។ ប៉ុន្តែគ្រាន់តែថាព្រលឹមឡើងគេប្រកូកប្រកាសគ្នា "ហ៎! អ្នកណាត្រូវទៅបើកស្រូវនៅកន្លែងសង្កាត់" ខាងចុងភៅហ្នឹងគេហៅឡើងរទេះទៅៗ មកវិញឃើញដាក់បាវមកៗ ស្អែកទៅទៀតទៅ។ ឃើញធ្វើតែអ៊ីចឹងរហូត។

[១៤:៤៥:២០]

**ប្រធានអង្គជំនុំ៖**

អត់ទាន់ឆ្លើយតបនឹងសំណួរមេធាវីសួរផង។ ចាំស្តាប់សំណួរឲ្យបាន ហើយឆ្លើយតបនឹងសំណួរឲ្យចំសំណួរដែលមេធាវីសួរ។

មេធាវីអាចតាំងសំណួរចុងក្រោយអម្បាញ់មិញសាជាថ្មីម្តងទៀតដើម្បីឲ្យគាត់ឆ្លើយតប ព្រោះគាត់អម្បាញ់មិញឆ្លើយមិនចំសំណួរដែលលោកមេធាវីសួរទេ។

**លោក វ៉ិចទ័រ កូប៉េ៖**

ខ្ញុំសូមចប់ត្រឹមនេះ ហើយលោកប្រធាន អរគុណច្រើន។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ ឥឡូវនេះ ដល់ពេលសម្រាកហើយ អង្គជំនុំជម្រះប្រកាសសម្រាកចាប់ពីពេល

នេះ តទៅរហូតដល់ម៉ោងបី សូមអញ្ជើញចូលវិញដើម្បីបន្តកិច្ចដំណើរការសវនាការ។

មន្ត្រីរដ្ឋបាលតុលាការសម្របសម្រួលផ្តល់កន្លែងសម្រាកនៅបន្ទប់រង់ចាំសម្រាប់សាក្សី និងអ្នកជំនាញដល់សាក្សីរូបនេះ នៅក្នុងអំឡុងពេលឈប់សម្រាក និងឲ្យអញ្ជើញគាត់ រួមទាំងបុគ្គលិកអង្គការធី.ភី.អូ មកកាន់កន្លែងផ្តល់សក្ខីកម្មនៅក្នុងបន្ទប់សវនាការនេះនៅវេលាម៉ោងបី។

សម្រាកចុះ!

**ក្រឡាបញ្ជី៖**

សូមអញ្ជើញក្រោកឈរ!

*(សវនាការសម្រាកពីម៉ោង ១៤:៤៦ នាទី ដល់ម៉ោង ១៥:០២ នាទី)*

[១៥:០២:៣៣]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ។ ហើយតទៅនេះ អង្គជំនុំជម្រះផ្តល់វេទិកាជូនទៅក្រុមមេធាវីការពារក្តីលោក ខៀវ សំផន ដើម្បីមានឱកាសតាំងសំណួរដេញដោលចំពោះដើមបណ្តឹងរដ្ឋប្បវេណីរូបនេះ។

**កញ្ញា អង់តា ហ្គីសសេ៖**

សូមអរគុណលោកប្រធាន។

**សួរដោយកញ្ញា អង់តា ហ្គីសសេ៖**

**ស៖** ជម្រាបសួរលោកស្រី ហ៊ុន សិត្ថានី! ខ្ញុំឈ្មោះ អង់តា ហ្គីសសេ ខ្ញុំជាសហមេធាវីអន្តរជាតិការពារក្តីលោក ខៀវ សំផន។ ខ្ញុំសួរសំណួរខ្លីៗ ដើម្បីសុំបំភ្លឺចំពោះសក្ខីកម្មរបស់លោកស្រីដែលបានឆ្លើយនៅចំពោះមុខតុលាការនេះ។ សំណួរទី១របស់ខ្ញុំ គឺពាក់ព័ន្ធទៅនឹងរយៈពេលដែលលោកស្រីធ្វើការនៅទំនប់១មករា។ នៅក្នុង<កំណត់ហេតុស្តាប់ចម្លើយ>របស់លោក<ស្រី> គឺឯកសារ E3/4790, ជាភាសាបារាំង ERNគឺ <00967205>, ERN ជាភាសាអង់គ្លេស 00940139 និងជាភាសាខ្មែរ 00582091។ លោកស្រីបានឆ្លើយថា លោកស្រីបានចាប់ផ្តើមការនៅទំនប់នោះ គឺនៅខែធ្នូ ឆ្នាំ៧៦ រហូតទៅដល់ខែមិថុនា ឆ្នាំ១៩៧៧។ តើចម្លើយហ្នឹងត្រឹមត្រូវដែរឬទេ?

[១៥:០៤:១៩]

**លោកស្រី ហ៊ុន សិត្ថានី៖**

**ឆ៖** ចាស ត្រឹមត្រូវ។

**ស៖** នៅក្នុងឯកសារដដែលនេះ លោកស្រីបានលើកឡើងអំពីរយៈកាលបីផ្សេងគ្នា ដែលក្នុងរយៈកាលទាំងបីហ្នឹង គឺមានពេលម៉ោងធ្វើការខុសគ្នា។ អ៊ីចឹង តើលោកស្រីចាំទេ ថាលោកស្រីបានលើកឡើងបែបនេះមែន គឺនៅខែដំបូងនោះ គឺមានពេលម៉ោងការងារហ្នឹងខុសពីខែបន្តបន្ទាប់មកទៀត។ តើលោកស្រីចាំថា លោកស្រីពិតជាបានឆ្លើយបែបហ្នឹងមែនទេ?

**ឆ៖** ចាស មែន ព្រោះមុនដំបូងធ្វើការជិត យើងម៉ោងប្រាំ។ ដល់ទៅធ្វើការឆ្ងាយ ត្រូវដើបពីយប់ដើរទៅ។ អ៊ីចឹង យើងត្រូវដើបពីយប់ ព្រោះយើងនៅឆ្ងាយជាងគេ។

**ស៖** ដើម្បីឲ្យត្រឹមត្រូវច្បាស់លាស់តែម្ដង ខ្ញុំសូមដកស្រង់នូវចម្លើយរបស់លោកស្រី ERN ជាភាសាបារាំង គឺ 00967207, ជាភាសាខ្មែរគឺ 00582094 រហូតទៅដល់ 95, ជាភាសាអង់គ្លេស 00940141។ នេះជាចម្លើយរបស់លោកស្រី ពាក់ព័ន្ធទៅនឹងពេលម៉ោងធ្វើការនៅខែដំបូង៖ "នៅម៉ោងប្រាំគេផ្លុំកញ្ចែ ប្រាំកន្លះចេញទៅរែកដី ម៉ោងដប់មួយសម្រាក រហូតដល់ម៉ោងពីរទើបធ្វើការ គឺធ្វើរហូតដល់ម៉ោងប្រាំល្ងាច ជួនកាលប្រាំមួយល្ងាច<។ យើងទៅដេកនៅម៉ោងប្រាំបីយប់>។ ម៉ោងប្រាំបួនព្រឹកគេឲ្យសម្រាកដប់នាទី បត់ជែបត់ជើង ល្ងាចម៉ោងបី គេឲ្យសម្រាក១០នាទីដែរ"។ សូមបញ្ចប់ការដកស្រង់។ អ៊ីចឹង តើការអានរបស់ខ្ញុំហ្នឹង ធ្វើឲ្យលោកស្រីនឹកឃើញឡើងវិញ អំពីពេលម៉ោងធ្វើការដែលលោកស្រីបានធ្វើការនៅខែដំបូងៗ នៅទំនប់នុ៎ងទេ?

[១៥:០៧:១៦]

**ឆ៖** ដូចខ្ញុំជម្រាបអ៊ីចឹង ថាកាលនោះនៅក្បែរវត្ត គឺពេលវេលាប៉ុណ្ណឹង។ នៅក្បែរកន្លែងយើងសម្រាកហ្នឹង គឺវត្តត្រពាំងជ្រៃហ្នឹង។

**ស៖** សំណួររបស់ខ្ញុំ គឺខ្ញុំចង់ដឹងថា តើអ្វីដែលខ្ញុំអានអម្បាញ់មិញហ្នឹង វាជាចម្លើយត្រឹមត្រូវទេ វាត្រូវតាមពេលម៉ោងដែលលោកស្រីធ្វើការនៅពេលនុ៎ងទេ?

**ឆ៖** ចាស គឺត្រឹមត្រូវហើយ។

**ស៖** នៅក្នុងឯកសារដដែលហ្នឹង គឺ ERN <លេខដូចគ្នាទាំង>ជាភាសាបារាំង និងជាភាសាខ្មែរ <និងភាសាអង់គ្លេស>ហ្នឹងគឺ 00582095<>។ លោកស្រីថា លោកស្រីប្ដូរកន្លែងធ្វើការហ្នឹង នៅខែកុម្ភៈ ហើយចាប់ពីខែកុម្ភៈទៅហ្នឹង គឺលក្ខខណ្ឌការងារ កាន់តែលំបាកលំបិនជាងមុន។ ហើយលោកស្រី

ពេលនោះ គឺចាប់ផ្តើមធ្វើការតាំងពីម៉ោងបីព្រឹក។ បន្ទាប់មកទៀត នៅទំព័របន្ទាប់មក<រយៈពេលដដែល ដែលលោកស្រីបានប្រាប់នៅខាងដើមសវនាការនេះ។ ហើយបន្ទាប់មកលោកស្រីបាននិយាយនៅក្នុងទំព័របន្ទាប់> គឺ ERN ជាភាសាបារាំង គឺ00967208, ជាភាសាអង់គ្លេស គឺ00940142, ជាភាសាខ្មែរ គឺ 00582095។ លោកស្រីបានឆ្លើយដោយបញ្ជាក់ថា មានការផ្លាស់ប្តូរពេលម៉ោង ខ្ញុំសូមដកស្រង់៖ “<ដោយសារម៉ោងប្រាំនៅតែ>ងងឹត <ទើបគេដាក់>ម៉ោងប្រាំកន្លះ<វិញ។ យើងចាប់ផ្តើមការងារពីម៉ោងប្រាំកន្លះ> ដល់ម៉ោងដប់មួយ ដោយមិនសម្រាកទេ។ ហើយជួនកាលយើងធ្វើទៅដល់ម៉ោង<មួយ ជួនកាលដល់ម៉ោង>ពីរ ហើយយើងបញ្ចប់នៅម៉ោងប្រាំ។ <បន្ទាប់មក> យើងចាប់ផ្តើមធ្វើការនៅម៉ោងប្រាំមួយ<ល្ងាច> ហើយបញ្ចប់ម៉ោងដប់<យប់> ហើយត្រឡប់ទៅរោងវិញ”។ <បញ្ចប់ការដកស្រង់។> អ៊ីចឹង ខ្ញុំចង់សួរថា៖ <តើលោកស្រីមានចាំបានដែរទេថា នៅពេលវានៅងងឹត លោកស្រីត្រូវក្រោកនៅម៉ោងផ្សេង?>

**ឆ៖** ដល់ពេលទៅឆ្ងាយយើងត្រូវការក្រោកពីយប់។ មុនដំបូង កាលណាគេហៅខក តែម៉ោងបី គេកញ្ចែទៅហើយ។ ដល់ទៅដល់កន្លែងហ្នឹងវានៅងងឹតពេក បានគេបន្ថយមកម៉ោងបួនវិញ ហើយគេកញ្ចែដាស់យើងហ្នឹងម៉ោងបួន។ បួនលើសបន្តិចហ្នឹងបានចេញដំណើរ កញ្ចែ១ពីរដង។ កញ្ចែទី៣ គឺចេញដំណើរហើយ ទី១ដាស់ឲ្យក្រោក រៀបចំខ្លួន, ទី២ចូលទៅជួរ, កញ្ចែទី៣ ចេញដំណើរហើយ។

[១៥:១១:២២]

**ស៖** ក៏ប៉ុន្តែលោកស្រីមិនបានឆ្លើយឲ្យបានជាក់លាក់ទៅនឹងសំណួររបស់ខ្ញុំទេ។ សំណួររបស់ខ្ញុំគឺថា ចម្លើយដែលលោកស្រីបានផ្តល់នៅក្នុងឯកសារ ហើយដែលលោកស្រីបានចុះហត្ថលេខាក្នុងនីតិវិធីហ្នឹង គឺលោកស្រីថា “ម៉ោងប្រាំ បើងងឹត គឺចេញធ្វើការម៉ោងប្រាំកន្លះវិញ”។<បញ្ចប់ការដកស្រង់។> អ៊ីចឹងខ្ញុំសួរលោកស្រីថា ៗលោកស្រីចាំទេថា លោកស្រីបានឆ្លើយអ៊ីចឹងមែន? ហើយគឺវាពិតជាអ៊ីចឹងមែនទេ ថាបើសិនជាងងឹតពេកហ្នឹង គេលើកពេលម៉ោងទៅមុខបន្តិចវិញ។ តើអ៊ីចឹងមែនទេ?

**ឆ៖** ខ្ញុំដូចជាសរសេរថា ម៉ោងបួនកន្លះទេ មិនមែនប្រាំឯណា។

**ស៖** អ៊ីចឹងលោកស្រីចង់និយាយថា នៅក្នុងឯកសារហ្នឹងចម្លើយហ្នឹង គឺខុសទេ អ៊ីចឹងមែនទេ?

**ឆ៖** ព្រោះសរសេរយូរហើយ--

**ប្រធានអង្គជំនុំ៖**

កុំអាលទាន់ឆ្លើយតប!

---

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

សូមអញ្ជើញលោកព្រះរាជអាជ្ញារងអន្តរជាតិ!

**លោក ឌេល លីសាក់៖**

សូមអរគុណលោកប្រធាន។ ខ្ញុំមិនដឹងថាតើមានភាពខុសគ្នារវាងការបកប្រែជាភាសាបារាំង ឬក៏យ៉ាងម៉េចទេ។ ក៏ប៉ុន្តែជាភាសាអង់គ្លេស<ក្នុងកថាខណ្ឌបន្ទាប់> គេនិយាយថាមានសំឡេងកញ្ចែដើម្បីដាស់កម្មករ<ឲ្យក្រោក។ កថាខណ្ឌនេះនិយាយអំពីពេលវេលាចាប់ផ្តើម>ធ្វើការ។ <លោកស្រីមេធាវីការពារក្តីដាក់ឯកសារពីរនេះឲ្យដូចគ្នា តែតាមពិត> ជាភាសាអង់គ្លេស<វា>ផ្សេង<ពីហ្នឹង>។ <សាក្សីនិយាយអំពីរឿងពីរផ្សេងគ្នា។>អ៊ីចឹង ខ្ញុំមិនដឹងថា ប្រហែលជាមានបញ្ហាបកប្រែជាភាសាបារាំង ឬក៏យ៉ាងម៉េច ក៏ប៉ុន្តែនៅក្នុងអង់គ្លេសគឺច្បាស់។

[១៥:១៣:២៣]

**កញ្ញា អង់តា ហ្គីសសេ៖**

<ក្នុងភាសាបារាំង វាពិតជាត្រឹមត្រូវហើយ តែមិនជាបញ្ហាអីទេ។>អ្វីដែលខ្ញុំអានអម្បាញ់មិញហ្នឹង ខ្ញុំអត់និយាយរឿងផ្លុកកញ្ចែទេ។ គឺខ្ញុំមើលច្បាស់ហើយគឺដាក់ថា “ម៉ោងប្រាំបើងងឹត គេចេញទៅធ្វើការម៉ោងប្រាំកន្លះវិញ”។ អ៊ីចឹងខ្ញុំសួរគាត់ថាតើពិតជាអ៊ីចឹងមែនទេ ថាពេលម៉ោងដែលចាប់ផ្តើមទៅធ្វើការហ្នឹង គឺគេលើកមកម៉ោងប្រាំកន្លះវិញ <ឲ្យប្រជាជនចេញទៅធ្វើការ>។

**ប្រធានអង្គជំនុំ៖**

សាក្សីកុំអាលទាន់ឆ្លើយតប!

សូមអញ្ជើញសហព្រះរាជអាជ្ញារងអន្តរជាតិ!

**លោក ឌេល លីសាក់៖**

<នេះហើយជាហេតុផលនៃការជំទាស់របស់ខ្ញុំ។ ពិតណាស់> ខ្ញុំមិនដឹងថាតើភាសាខ្មែរយ៉ាងម៉េចទេ ក៏ប៉ុន្តែជាភាសាអង់គ្លេសហ្នឹង <ឯកសារហ្នឹងមិនបានសរសេរ>ថា<ពួក>គាត់ចាកចេញទៅនៅម៉ោងប្រាំ<កន្លះនោះទេ តែក្នុងហ្នឹងសរសេរថា ពួកគេ>ត្រូវទៅដល់ការដ្ឋានហ្នឹងគឺនៅម៉ោង<ប្រាំ ឬម៉ោង>ប្រាំកន្លះ <ទៅតាមពេលវេលាក្នុងឆ្នាំ>។

**សួរដោយកញ្ញា អង់តា ហ្គីសសេ៖**

**ស៖** ខ្ញុំនឹង<ឲ្យសហភាគាខ្ញុំពិនិត្យមើលឯកសារជាភាសាខ្មែរ អ៊ីចឹងខ្ញុំសូម>បន្តសួរ<ទៅមុខ>ទៀត ហើយខ្ញុំនឹងត្រឡប់មកចំណុចនេះវិញនៅពេលក្រោយ។ សហភាគារបស់ខ្ញុំថា នៅខ្មែរ -- ភាសា

ខ្មែរហ្នឹងគឺច្បាស់ជា គឺសរសេរអ៊ីចឹងហើយ ថាម៉ោងប្រាំកន្លះ។ អ៊ីចឹងខ្ញុំសូមបញ្ចប់សំណួរនេះ។ គឺថាជាភាសាខ្មែរអត់មានបញ្ហាអីទេ គឺមានការបញ្ជាក់ច្បាស់ថាគេលើកពេលចាប់ផ្តើមហ្នឹងទៅម៉ោងប្រាំកន្លះវិញ។ អ៊ីចឹងលោកស្រីអាចបញ្ជាក់ពីចំណុចហ្នឹងបានទេ?

[១៥:១៤:៥៩]

**លោកស្រី ហ៊ុន សិត្ថានី៖**

**ឆ៖** នៅក្បែរវត្តទេ ដែលម៉ោងប្រាំហ្នឹងនោះ។ ទៅឆ្ងាយគឺវាម៉ោងបួន មិនមែនម៉ោងប្រាំទេ ម៉ោងប្រាំគឺនៅជិតវត្ត។ ខ្ញុំសរសេរហ្នឹងបញ្ជាក់ថាម៉ោងបួន យប់ពេកគេថែមទៅបួនកន្លះបន្តិចទៅ។

**ស៖** ឥឡូវខ្ញុំចូលទៅចំណុចផ្សេងទៀត។ កាលពីព្រឹកមិញនេះ នៅពេលដែលមេធាវី នួន ជា សួរលោកស្រីនោះ លោកស្រីឆ្លើយថា លោកស្រីមិនធ្លាប់ឮគេប្រកាស និងពេលដែលគេប្រើគ្រឿងផ្ទុះដើម្បីបំបែកថ្មទេ។ តើខ្ញុំយល់ចម្លើយរបស់លោកស្រីហ្នឹងគឺអ៊ីចឹងមែនទេ គឺថាមុនពេលគេប្រើគ្រឿងផ្ទុះបំបែកថ្មហ្នឹង គេអត់មានប្រកាសអីតាមមីក្រូទេ។ តើអ៊ីចឹងមែនទេចម្លើយលោកស្រីនៅពេលព្រឹកមិញនេះ?

**ឆ៖** ចាស មែន ខ្ញុំប្រាប់អ៊ីចឹងមែន។ ខ្ញុំថា តែគេដាក់គេអត់មាន "ហ៎! ស្រែកថាហ៎! ថយចេញគេដាក់ឆ្នួន" អីអត់ទេ តែគេចោះថ្មបានល្ងាចដែលគេសម្រាកការងារហ្នឹង គឺគេដាក់ហើយ អ្នកខ្លះនៅក្បែរៗហ្នឹង អង្គុយលេងអីហ្នឹង ទាល់តែដឹងថា ឃើញហុយអីបាននាំគ្នារត់ទៅ។ គេអត់មានប្រកាសប្រាប់អីអត់សោះ។

**ស៖** លោកស្រីទើបតែបញ្ជាក់ថា នៅពេលដែលមានៗការដាក់គ្រឿងផ្ទុះហ្នឹង គេឲ្យថយទៅឲ្យឆ្ងាយ។ តើអ្នកណាជាអ្នកប្រាប់ឲ្យថយទៅហ្នឹង?

**ឆ៖** គ្មានអ្នកណាប្រាប់ទេ គឺដឹងខ្លួនៗឯង តែឃើញគេរៀបចំ គេហៅថា "ដុតឆ្នួន" ហ្នឹង យើងដឹងហើយថាគេដុតឆ្នួន មនុស្សជុំៗនៅធ្វើការនៅហ្នឹង រួចទាំងគេទាំងខ្ញុំតែគេដាក់ទៅហុយៗហ្នឹងដឹងខ្លួនៗឯងនាំគ្នារត់ទៅ។ មានៗអ្នកបែកក្បាលអ៊ីចឹងដែរ ខ្ទាតដំថ្មអីត្រូវ រត់មិនទាន់។

[១៥:១៧:៥៩]

**ស៖** ខ្ញុំសួរសំណួរពាក់ព័ន្ធទៅនឹងបញ្ហានេះ ពីព្រោះថាយើងបានស្តាប់ឮសាក្សីពីររូប មុនលោកស្រី។ ទី១ គឺ ប៊ុច សុខា គឺនៅ<សវនាការ>ថ្ងៃទី២១ ឧសភា ឆ្នាំ២០១៥ នៅពេលនោះគេសួរចម្លើយដែលគាត់បានឆ្លើយពីមុន ហើយ<ជាអ្វីដែល>គាត់បាន<និយាយ> គឺនៅក្រោយម៉ោង ១១:២៩:៣២ វិនាទី គាត់បញ្ជាក់ថា "ខ្ញុំស្តាប់ឮគេប្រកាសតាមមីក្រូ ឲ្យបងប្អូនប្រយ័ត្នប្រយែង ព្រោះគេនឹងប្រើគ្រឿង

ផ្ទុះដើម្បីបំបែកថ្ម" សូមបញ្ចប់ការដកស្រង់។ ពេលនោះគេសួរសំណួរគាត់ថា "តើសារសុវត្ថិភាពហ្នឹង គេប្រកាសញឹកញាប់ទេនៅតាម -- នៅការដ្ឋានតាមមីក្រូហ្នឹង?" គាត់ឆ្លើយថា "បាទ គឺរៀងរាល់ពេល ដែលគេដាក់គ្រាប់បែកបំផ្ទុះហ្នឹង គឺគេតែងតែប្រកាសតាមមីក្រូ"។ តើលោកស្រីអាចចងចាំឡើងវិញទេ ថាមានការប្រកាសតាមមីក្រូឬក៏អត់?

**ឆ៖** ខ្ញុំចង់ដឹងថាគេហ្នឹងនៅស្រុកណា? តំបន់ខាងណា? បើខាងខ្ញុំគេមិនដែលប្រកាសផងនេះ។ ខាងបារាយណ៍នេះ។

**ស៖** សាក្សីមួយរូបទៀត គឺ មាស ឡៃហួរ នៅ<សវនាការ>ថ្ងៃទី២៦ ខែឧសភា ឆ្នាំ២០១៥ ក្រោយម៉ោង ១៤:២៤:៣៦វិនាទី គេសួរគាត់នៅមុនម៉ោង<១៤:២៦>ហ្នឹងបន្តិច។ សួរថា៖ "តើលោកស្រីចាំទេថា នៅពេលគេប្រើគ្រឿងផ្ទុះហ្នឹង គេមានប្រកាសផ្សាយតាមមីក្រូដើម្បីឲ្យអ្នកធ្វើការប្រយ័ត្នប្រយែងទេ?" គាត់ឆ្លើយដូចតទៅ៖ "ចាស គឺនៅពេលដែលគេប្រើគ្រាប់បែកដើម្បីបំផ្ទុះថ្មនោះ អ្នកធ្វើការត្រូវតែទៅឲ្យឆ្ងាយ គេហាមមិនឲ្យមកជិតកន្លែងផ្ទុះនោះទេដើម្បីកុំឲ្យត្រូវកម្ទេចថ្ម ដែលផ្ទុះទៅនោះ" ។ សូមបញ្ចប់ការដកស្រង់។ ហើយបន្ទាប់មកគាត់បានឆ្លើយបន្ត<បន្ថែម>ទៀតថា៖ "ខ្ញុំឃើញគេដេញមនុស្សចេញពីកន្លែងគេដាក់បំផ្ទុះហ្នឹង ហើយគេសួរបន្តទៀតថា៖ "ដេញចេញពីកន្លែងណា?" គាត់ឆ្លើយថា៖ "គេដេញចេញពីកន្លែងដែលគេដាក់គ្រាប់បែកបំផ្ទុះថ្ម។ គេដេញចេញឲ្យឆ្ងាយអ៊ីចឹងដើម្បីកុំឲ្យខ្ទាតថ្មត្រូវ។ ពេលគេប្រើគ្រាប់បែកបំផ្ទុះហើយកម្មករអាចត្រឡប់មកធ្វើការវិញបន្តទៀតបាន"។ សូមបញ្ចប់ការដកស្រង់។ អ៊ីចឹង ខ្ញុំចង់សួរលោកស្រីថា ប្រសិនបើលោកស្រីមិនឮគេប្រកាសតាមមីក្រូឲ្យប្រយ័ត្នប្រយែងហ្នឹង <នៅពេលណាមួយ តើ>លោកស្រីធ្លាប់ឮថា គេមានដេញប្រជាជនដេញកម្មករហ្នឹងឲ្យចេញឆ្ងាយពីកន្លែងដែលគេដាក់គ្រាប់បែកបំផ្ទុះថ្មហ្នឹងទេ?

[១៥:១៧:០២]

**ឆ៖** នៅខាងខ្ញុំហ្នឹងអាងថា ពេលក្រោយពេលសម្រាកដែលគេដុតឆ្នួនហ្នឹង មិនសូវមានមនុស្សនៅក្នុងអាប្រឡាយគេជីកហ្នឹងទេ។ អ៊ីចឹងគេអត់មានប្រកាសទេ។ យើងឃើញរៀងខ្លួនហ្នឹង នាំគ្នារត់ចេញ ដើរចេញអស់ទៅ មិនដែលមានអ្នកណាប្រកាសទេ។ អើគេអាងថាដល់ពេលសម្រាកហើយ យើងមិនថយចេញពីត្រង់នោះ ទៅរកកន្លែងសម្រាក។

**ស៖** អ៊ីចឹងលោកស្រី<ចង់ប្រាប់យើង>ថា "<ពាក់ព័ន្ធនឹងក្រុមរបស់យើង" ឃ្លានេះ លោកស្រីចង់និយាយថា ក្នុងកាលៈទេសៈហ្នឹង> គឺលោកស្រី<មិន>ដឹង<>រឿងរ៉ាវនៅក្នុងកងផ្សេងទៀត

<ទេ>។ តើអ៊ីចឹងមែនទេ?

**ឆ៖** ចាស គឺខ្ញុំមិនដឹងទេ ខាងកងគេ។ ខ្ញុំដឹងតែខាងខ្ញុំ ខាងបារាយណ៍ហ្នឹង ឃុំបារាយណ៍ហ្នឹង។

**កញ្ញា អង់តា ហ្គីសសេ៖**

លោកប្រធានខ្ញុំអស់សំណួរហើយ ហើយមេធាវីជាតិក៏<អត់មាន>សំណួរ<អី>ដែរ<។ ដូច្នេះ យើង>សូមបញ្ចប់ត្រឹមនេះ<ហើយ លោកស្រីដើមបណ្ដឹងរដ្ឋប្បវេណី>។ សូមអរគុណ។

**ប្រធានអង្គជំនុំ៖**

លោកស្រី ហ៊ុន សិត្ថានី ដូចយើងបានប្រាប់លោកស្រីរួចហើយថា នៅចុងក្រោយនៃការស្ដាប់សក្ខីកម្មរបស់លោកស្រី លោកស្រីអាចថ្លែងរៀបរាប់ដល់អង្គសវនាការអំពីរឿងហេតុទំនាក់ទំនងទៅនឹងបទឧក្រិដ្ឋដែលត្រូវបានចោទប្រកាន់លើជនជាប់ចោទទាំងពីររូប ដែលបានប៉ះពាល់ចំពោះលោកស្រីក្នុងអំឡុងរបបកម្ពុជាប្រជាធិបតេយ្យដែលនាំឲ្យលោកស្រីប្ដឹងសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណី ប្ដឹងទាមទារសំណងនិងជាសមូហភាពពីជនជាប់ចោទ និងអំពីស្ថានភាពព្យសនកម្មដែលមានចំពោះលោកស្រីមានជាអាទិ៍ ការខូចខាតខាងរាងកាយ សម្ភារៈ ឬផ្លូវចិត្ត និងជាផលវិបាកដោយផ្ទាល់ពីបទឧក្រិដ្ឋព្យសនកម្មផ្ទាល់ខ្លួននឹងបានកើតឡើងមានពិតប្រាកដដល់សព្វថ្ងៃនេះ ប្រសិនបើលោកស្រីមានបំណងធ្វើដូច្នេះ។

**លោកស្រី ហ៊ុន សិត្ថានី៖**

ផលវិបាកទាំងអស់ដែលធ្លាក់មកលើរូបខ្ញុំ គឺយើងធ្លាប់រស់នៅជួបជុំគ្រួសារ មានក្ដីសុខ ដល់ពេលរបបនោះចូលមក គឺយើងបាត់បង់អស់រលីង គឺបាត់បង់គ្រប់យ៉ាង បាត់បង់ផ្ទះសម្បែង ទ្រព្យសម្បត្តិ ឪពុកម្ដាយ បងប្អូន គឺខ្ញុំរស់នៅតែម្នាក់ឯង។ ខ្ញុំបាត់បង់គ្មានសល់ ទុក្ខលំបាកដែលខ្ញុំមិនធ្លាប់ស្គាល់ គឺខ្ញុំស្គាល់អស់ហើយ។ ភាពឯកោហ្នឹងយ៉ាងណា អ្នកណាដែលឯកោដូចខ្ញុំ អ្នកនោះនឹងដឹង អ្នកដែលគេមិនឯកោ គឺគេមិនដឹងទេ។ គេថាយើងនៅបានប្រយោជន៍អី អាយំយែកហ្នឹងនោះ។ ខ្ញុំមិនចង់យំទេ តែខ្ញុំទប់វាមិនបាន កាលខ្ញុំរំឭក គឺឃើញហាក់នៅថ្មីៗ ខ្ញុំស្ដាយ ខ្ញុំស្រណោះ ខ្ញុំអាឡោះអាល័យ។ ក្នុងជីវិត ខ្ញុំស្គាល់ហើយភាពពិបាកយ៉ាងណា។ ហេតុអីបានជាវេនខ្ញុំត្រូវជួបរឿងអ៊ីចឹងៗ។

[១៥:២៦:៣៤]

តើលោកអ្នកដឹកនាំ និងលោកដឹកនាំប្រទេសយ៉ាងម៉េច? លោកមានអាណិតអាសូរកូនខ្មែរទេ? លោកដឹងពីផលវិបាកទេ? ធ្លាប់ពីមានរបស់របរប្រើប្រាស់សព្វបែបយ៉ាងមកបាតដៃទទេ វេទនាប៉ុនណា។

ខ្ញុំខ្លាចណាស់ ខ្ញុំខ្លាចមែនទែន ខ្លាចបាក់ស្បាតអស់ហើយ អ្វីដែលជាទុក្ខសោក រស់នៅគ្មានសិទ្ធិសេរីភាព។

ខ្ញុំសូមជម្រាបថា សូមកុំឲ្យមានរបបនេះបន្តទៀតលោកអើយ កុំឲ្យមានឲ្យសោះ។ ឈឺចាប់ណាស់ក្នុងជីវិត ឈឺចាប់រកអ្វីប្រៀបពុំបានទេ ស្គាល់តែការប្រឹង ស្គាល់តែការខំ អ្នកដែលគ្មានកំហុស ខំធ្វើការហើយនៅតែសម្លាប់បានទៀត ប្រឹងអស់ពីកម្លាំងកាយចិត្ត។ ស្លាប់ដោយសារមាត់ សម្លាប់គ្នាដោយសារមាត់។ តែថាខុស គេយកទៅហើយ។ ការធ្វើទុក្ខបុកម្នេញ គ្មានអាសូរគ្នាយ៉ាងនេះ។ រស់នៅគ្មានប្រយោជន៍អីទេ ស្គាល់តែភាពព្រាត់ប្រាសគ្នា ប្តីព្រាត់ប្រពន្ធ កូនព្រាត់ម៉ែឪ អាងអី សង្ឃឹមអី បើនៅតូចៗ។ បើសិនជាអស់លោកដឹងចាប់ពីថ្ងៃនេះទៅ សូមកុំឲ្យមានទៀត ឈប់ហើយ ត្រឹមហ្នឹងហើយ។

ខ្ញុំសុំជាសំណួរបានដែរបង?

**ប្រធានអង្គជំនុំ៖**

អញ្ជើញបាទ! តាំងសំណួរ អាចសួរបាន ប៉ុន្តែកុំធ្វើផ្ទាល់ ធ្វើតាមរយៈយើង ជាប្រធានអង្គជំនុំជម្រះ។

**លោកស្រី ហ៊ុន សិត្ថានី៖**

នាងខ្ញុំចង់សួរលោកថា តើការស្លាប់ -- តើលោកទទួលខុសត្រូវយ៉ាងណា? ដូចថា ក្នុងការសម្លាប់មនុស្ស បាត់បង់ជីវិត ចំពោះជនរងគ្រោះ និងការធ្វើទុក្ខបុកម្នេញនេះ ទៅដល់ជនរងគ្រោះនេះនៅក្នុងរបបលោកនោះ តើលោកទទួលស្គាល់ ទទួលខុសត្រូវយ៉ាងម៉េច? និងមួយទៀត តើលោកទទួលស្គាល់ទេនូវអំពើទាំងឡាយនេះ? ខ្ញុំមានតែប៉ុណ្ណឹង។

[១៥:៣៣:៤៥]

**ប្រធានអង្គជំនុំ៖**

បាទ ហើយអង្គជំនុំជម្រះសូមជម្រាបលោកស្រី ហ៊ុន សិត្ថានី ថា នៅក្នុងសវនាការកាលពីថ្ងៃទី៨ ខែមករា ឆ្នាំ២០១៥ បន្ទាប់ពីអង្គជំនុំជម្រះបានស្តាប់ជនជាប់ចោទទាំងពីររូប ឆ្លើយបញ្ជាក់ពីការដែលខ្លួនគាត់រក្សាសិទ្ធិនៅស្ងៀមមិនឆ្លើយតបនឹងសំណួរ អង្គជំនុំជម្រះបានកត់សម្គាល់ថា ជនជាប់ចោទទាំងពីរនាក់នៅតែរក្សាជំហររបស់ខ្លួនបន្ត អនុវត្តសិទ្ធិនៅស្ងៀមមិនឆ្លើយតបដដែល។ លើកលែងតែ និងរហូតដល់ពេលណាដែលអង្គជំនុំជម្រះសាលាដំបូង ទទួលបានព័ត៌មានជាក់ច្បាស់ផ្សេងពីជនជាប់ចោទ ឬក៏សហមេធាវីការពារក្តីជនជាប់ចោទ។ ហើយនៅក្នុងសវនាការនោះ អង្គជំនុំជម្រះបានកំណត់ឲ្យជន

ជាប់ចោទ និងសហមេធាវីការពារក្ដីជនជាប់ចោទ ត្រូវទទួលខុសត្រូវក្នុងការជូនដំណឹងដល់អង្គជំនុំជម្រះឱ្យបានទាន់ពេលវេលា និងមានប្រសិទ្ធភាព ប្រសិនបើជនជាប់ចោទបានសម្រេចលះបង់សិទ្ធិនៅស្ងៀមមិនឆ្លើយតប ហើយយល់ព្រមឆ្លើយតបនឹងសំណួរនៅដំណាក់កាលណាមួយ នៃកិច្ចដំណើរការនីតិវិធីសវនាការ ដែលសួរដោយអង្គជំនុំជម្រះ ឬក៏ភាគីពាក់ព័ន្ធ។ ហើយរហូតមកដល់ពេលនេះ អង្គជំនុំជម្រះនៅមិនទាន់បានទទួលដំណឹងពីការផ្លាស់ប្ដូរជំហររបស់ជនជាប់ចោទទាំងពីរនាក់នៅឡើយទេ ពីការសម្រេចលះបង់សិទ្ធិក្នុងការនៅស្ងៀមមិនឆ្លើយតប ហើយយល់ព្រមឆ្លើយតបនឹងសំណួររបស់អង្គជំនុំជម្រះ ឬក៏ភាគីនោះ។

ហើយអង្គជំនុំជម្រះសូមអរគុណលោកស្រី ហ៊ុន សិត្ថានី សវនាការស្ដាប់សក្ខីកម្មរបស់លោកស្រី និងការថ្លែងរៀបរាប់អំពីទុក្ខសោកវេទនា និងព្យសនកម្មដែលលោកស្រីអះអាងថា លោកស្រីបានទទួលរងក្នុងអំឡុងកម្ពុជាប្រជាធិបតេយ្យបានដល់ទីបញ្ចប់ហើយ ហើយវត្តមានរបស់លោកស្រីនៅ អ.វ.ត.ក លែងមានភាពចាំបាច់ទៀតហើយ លោកស្រីអាចវិលត្រឡប់ទៅកាន់លំនៅដ្ឋាន ឬគោលដៅណាដែលលោកស្រីមានបំណងចង់ទៅបានហើយ ហើយសូមលោកស្រីមានសុខភាពល្អ ជួបតែសំណាងល្អ និងធ្វើដំណើរវិលត្រឡប់ទៅវិញប្រកបដោយសុវត្ថិភាព។

មន្ត្រីរដ្ឋបាលតុលាការសម្របសម្រួលជាមួយនឹងបុគ្គលិកនៃអង្គភាពគាំពារសាក្សី និងអ្នកជំនាញក្នុងការជូនលោកស្រី ហ៊ុន សិត្ថានី វិលត្រឡប់ទៅកាន់លំដ្ឋាន ឬក៏គោលដៅណាដែលគាត់មានបំណងចង់ទៅបានហើយ។ ហើយអង្គជំនុំជម្រះអរគុណលោកស្រី ឆាយ ម៉ារីដែន បុគ្គលិកអង្គការ ធី.ភី.អូ ដោយលោកស្រីត្រូវអង្គុយក្បែរដើមបណ្ដឹងរដ្ឋប្បវេណីបន្ទាប់ទៀតនេះ ដូច្នេះលោកស្រីគប្បីនៅអង្គុយនៅកន្លែងនោះដដែលចុះ រង់ចាំអង្គជំនុំជម្រះធ្វើសវនាការស្ដាប់សក្ខីកម្មដើមបណ្ដឹងរដ្ឋប្បវេណី 2-TCCP-230។

ហើយបង្គាប់ឱ្យមន្ត្រីរដ្ឋបាលតុលាការ អញ្ជើញដើមបណ្ដឹងរដ្ឋប្បវេណីដែលមានរហស្សនាម 2-TCW-230 ចូលមកកាន់កន្លែងផ្ដល់សក្ខីកម្មនៅក្នុងបន្ទប់សវនាការ។

*(ដើមបណ្ដឹងរដ្ឋប្បវេណីចូលក្នុងបន្ទប់សវនាការ)*

[១៥:៣៨:០៤]

**ការតាំងសំណួរដោយចៅក្រម**

**សួរដោយប្រធានអង្គជំនុំ៖**

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឱ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

**ស៖** សួស្តីលោកស្រីដើមបណ្តឹងរដ្ឋប្បវេណី! តើលោកស្រីឈ្មោះអី?

**លោកស្រី អ៊ុន រ៉ន៖**

**ឆ៖** អ៊ុន រ៉ន។

**ស៖** បាទ អរគុណលោកស្រី អ៊ុន រ៉ន។ តើលោកស្រីកើតនៅថ្ងៃខែឆ្នាំណា លោកស្រីចាំដែរទេ?

**ឆ៖** ២៤ ខែ១ ១៩៥៣។

**ស៖** បាទ អរគុណ។ ហើយលោកស្រី អ៊ុន រ៉ន តើលោកស្រីមានទីកន្លែងកំណើតនៅទីកន្លែងណា?

**ឆ៖** នៅភូមិតារាម ឃុំត្បែង ស្រុកកំពង់ស្វាយ ខេត្តកំពង់ធំ។

**ស៖** ចុះទីលំនៅសព្វថ្ងៃរបស់លោកស្រី តើរស់នៅទីកន្លែងណា?

**ឆ៖** នៅភូមិតារាម ឃុំត្បែង។

**ស៖** តើលោកស្រីប្រកបមុខរបរធ្វើអ្វីសព្វថ្ងៃនេះ?

**ឆ៖** ធ្វើស្រែ។

**ស៖** តើឪពុកបង្កើតរបស់លោកស្រីឈ្មោះអី? ហើយម្តាយបង្កើតរបស់លោកស្រីគាត់ឈ្មោះអី?

**ឆ៖** ឪពុកបង្កើតឈ្មោះ តូច នាង ម្តាយបង្កើតឈ្មោះ ចាយ លី។

**ស៖** ចុះប្តីរបស់លោកស្រីគាត់ឈ្មោះអី? ហើយលោកស្រីមានកូនប៉ុន្មាននាក់?

**ឆ៖** ឈ្មោះ ឡាញ់ វុទ្ធី ប៉ុន--

**ស៖** លោកស្រីមានកូនប៉ុន្មាននាក់?

**ឆ៖** កូនពីរ។

[១៥:៣៩:៥៧]

**ប្រធានអង្គជំនុំ៖**

លោកស្រី អ៊ុន រ៉ន ជាចុងក្រោយបង្អស់នៃការផ្តល់សក្ខីកម្មរបស់លោកស្រី ក្នុងឋានៈលោកស្រីជាដើមបណ្តឹងរដ្ឋប្បវេណី លោកស្រីមានសិទ្ធិថ្លែងរៀបរាប់អំពីស្ថានភាពទុក្ខសោក វេទនា និងស្ថានភាពព្យសនកម្មដែលកើតមានចំពោះលោកស្រីនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ប្រសិនបើលោកស្រីមានបំណងធ្វើដូច្នេះ នេះជាសិទ្ធិរបស់លោកស្រី ដែលយើងនឹងផ្តល់ឱកាសជូនលោកស្រីនាពេលចុងក្រោយបង្អស់នៃការផ្តល់សក្ខីរបស់លោកស្រីនៅចំពោះមុខអង្គជំនុំជម្រះ។

អនុវត្តតាមបទប្បញ្ញត្តិនៃវិធាន៩១ស្ទួននៃវិធានផ្ទៃក្នុង អ.វ.ត.ក អង្គជំនុំជម្រះផ្តល់វេទិកាជូនទៅសហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីសួរដេញដោលដើមបណ្តឹងរដ្ឋប្បវេណីរូបនេះ មុនភាគីដទៃទៀតនៃរឿងក្តី។ ហើយអង្គជំនុំជម្រះសូមជម្រាបថា សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី រួមនិងសហព្រះរាជអាជ្ញាមានរយៈពេលពីរវគ្គនៃថ្ងៃសវនាការក្នុងការសួរដើមបណ្តឹងរដ្ឋប្បវេណីរូបនេះ។ សូមអញ្ជើញបាទ!

[១៥:៤០:៥៩]

**លោកស្រី ម៉ារី ហ្គីរ៉ូដ៖**

សូមអរគុណលោកប្រធាន។ ខ្ញុំសូមអនុញ្ញាតផ្តល់វេទិកានេះជូនទៅសហភាតារបស់ខ្ញុំ គឺលោកស្រីមេធាវី ម៉ុច សុវណ្ណារី។

**ប្រធានអង្គជំនុំ៖**

បាទ អង្គជំនុំជម្រះអនុញ្ញាត។ សូមអញ្ជើញ!

**ការតាំងសំណួរដោយសហមេធាវីដើមបណ្តឹងរដ្ឋប្បវេណី**

**សួរដោយលោកស្រី ម៉ុច សុវណ្ណារី៖**

ចាសសូមអរគុណលោកប្រធាន។ ជាដំបូងខ្ញុំសូមគោរពលោកប្រធាន លោក លោកស្រីចៅក្រមអង្គសវនាការទាំងមូល។ ហើយសូមជម្រាបសួរដល់អ្នកស្រីដើមបណ្តឹងរដ្ឋប្បវេណី អ្នកស្រី អ៊ុន រ៉ន។

**ស៖** ខ្ញុំមានសំណួរមួយចំនួនតាំងទៅដល់អ្នកស្រី ហើយប្រសិនបើសំណួរខ្ញុំសួរអត់ច្បាស់ ឬក៏អ្នកស្រីអត់យល់សំណួរ អ៊ីចឹងអាចសួរត្រឡប់មកខ្ញុំវិញដើម្បីឱ្យខ្ញុំកែសម្រួលសំណួរ ឬក៏សួរសំណួរខ្ញុំម្តងទៀត។ ដំបូងខ្ញុំចង់ជម្រាបសួរអ្នកស្រីថា នៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ តើអ្នកស្រីរស់នៅទីកន្លែងណាដែរ?

**លោកស្រី អ៊ុន រ៉ន៖**

**ឆ៖** កាលហ្នឹងខ្ញុំនៅកំពង់ធំជាមួយឪពុកមា។ ដល់ពេលមានជម្លៀសចេញទៅ ទៅតាំងក្រសាំង ម្តាយខ្ញុំយកមកពីតាំងក្រសាំងមកនៅឃុំតារាមវិញ។

[១៥:៤២:១៦]

**ស៖** ចាស សូមអរគុណអ្នកស្រី។ អ៊ីចឹងនៅពេលដែលអ្នកស្រីនៅក្នុងភូមិតារាមហ្នឹង តើគេបានចាត់ចែងអ្នកស្រីឱ្យស្ថិតនៅក្នុងក្រុមណា នៅក្នុងកងណាដែរ អ្នកស្រីអាចជម្រាបតុលាការបានទេ?

**ឆ៖** កាលនោះនៅតាមភូមិអត់ទាន់មានក្រុម មានកងអីទេ ខ្ញុំមកពីនេះទៅ -- មកពីឪពុកមានៅជាមួយម្ដាយ ដកសំណាបធ្វើការងារនៅក្នុងភូមិហ្នឹង នៅឡើយទេ អត់ទាន់បានចេញទៅណាទេ។

**ស៖** បន្ទាប់ពីអ្នកស្រីធ្វើការនៅតាមភូមិហ្នឹង ដកស្ទូង ដកសំណាបអីហ្នឹងហើយ តើគេតម្រូវឱ្យអ្នកស្រីធ្វើការងារអ្វីខ្លះទៀត?

**ឆ៖** ឱ្យខ្ញុំចេញទៅនៅកងចល័តក្ដីសែន ចល័តតំបន់ នៅក្នុងវត្តក្ដីសែន។ ទៅនៅរយៈពេល ខ្ញុំចាំមិនច្បាស់ទេកាលនោះ នៅទៅដកសំណាប ធ្វើស្រែនៅឯណោះឯង។ រហូតដល់ទឹកជន់មកច្រើនខ្លាំង គេកេណ្ឌកម្លាំងទៅច្រើននៅហ្នឹងឯងទៅ ដកសំណាបមិនបានអីមិនបានហើយ គេឱ្យឡើងមកនេះ ឡើងមកនៅនឹងវត្តក្ដីសែនសិន សម្រាក។ ចេញពីនោះមកបានមកនៅ គេថាទៅការដ្ឋាននៅឯ ១មករា។ ចេញទៅដល់ ១មករាទៀត។ ទៅអង្កាល់នោះ នៅស្ទូងនឹងក្ដីសែន ដកសំណាបអត់បាន ដកទៅវាដាច់ទងសំណាបខ្លាំងពេក គេអត់ឱ្យដកទេ គេឱ្យឡើងមកខាងក្ដីសែនឡើងទៅខាងលើវិញទៅបានគេឱ្យ ដកខ្ញុំនេះទៅ១មករា។ មួយកងធំ ទៅ ១មករា។ ទៅដល់ ១មករា ទៅដល់ ទៅពីនេះគេឱ្យជិះឡានទៅៗទៅដល់ចាល់នឹងព្រៃ អត់ឡានចេញទៅអត់រួច ឱ្យយើងដើរ ទូលសាក់កាដូដើរទៅ។ ដើរទៅដល់កន្លែងនោះល្ងាចប្រហែលជាម៉ោង៧ប្រាំ ម៉ោងប្រាំមួយ រោងគេមានស្រេចហើយគ្រាន់ដេកនៅចាំរោង អត់មានកន្ទេលមានអីទេ ដេកចាំឡានគេត្រឡប់មកវិញព្រឹកស្អែកឡើង ត្រួសត្រាយព្រៃ កាប់ព្រៃកាប់អីនេះ យូរណាស់ កាប់ប្រហែលជាពីរខែ។ កាប់ព្រៃត្រួសត្រាយរួចទៅ បានគេឱ្យវាស់ដីចែកប្រធានកងៗ ប្រធានកងវាស់ដីរួចបានចែកមកតាមក្រុម មួយក្រុម១១០នាក់ទៅ ក្រុមបានចែកតាមសមាជិក ក្នុងម្នាក់ឱ្យ ៤ ម៉ែត្រគូប។

[១៥:៤៥:១៨]

**ស៖** ចាស សូមអរគុណអ្នកស្រី។ សូមទោស ខ្ញុំសូមកាត់អ្នកស្រីបន្តិចដោយសារខ្ញុំមានសំណួរមុននឹងឈានទៅដល់កន្លែងអ្វីដែលអ្នកស្រី ការងារដែលអ្នកស្រីត្រូវធ្វើនៅទំនប់១មករា។ អ្នកស្រីមុននេះបន្តិច មុននឹងត្រូវបានបញ្ជូនទៅការដ្ឋានទំនប់១មករា អ្នកស្រីបានបញ្ជាក់ថា អ្នកស្រីស្ថិតនៅក្នុងចល័ត តំបន់។ អ៊ីចឹងតើអ្នកស្រីអាចជម្រាបបានទេថា នៅក្នុងកងធំរបស់អ្នកស្រីដែលចែកចេញជាកងតូចៗ រួចហើយនៅក្នុងកងតូចៗ ចែកចេញជាក្រុមតូចៗ។ ខ្ញុំចង់សួរដំបូងថា តើនៅក្នុងកងធំរបស់អ្នកស្រីហ្នឹងតើមានចំនួនមនុស្សប៉ុន្មាននាក់ដែរនៅក្នុងកងនោះ? ហើយប្រធានកងនោះគាត់ឈ្មោះអ្វីដែរ?

**ឆ៖** មួយកងធំ មាន១០០នាក់ ចែកជាបីកងតូច។ មួយកងតូច៣៣នាក់ខ្លះ ៣៤នាក់ខ្លះ។ ចែក

បីកងតូច។ ដល់ហើយប្រធានកងធំ ឈ្មោះ ឈន។ ប្រធានកងតូច ឈ្មោះ ឈាង មួយ, ឈ្មោះ សឿន មួយ -- ឈ្មោះ ណៃ (សុំទោស) ឈ្មោះ ណៃ មួយ, ឈាង មួយ។

**ស៖** សូមអរគុណអ្នកស្រី។ មុននឹងអ្នកស្រីបានបញ្ជាក់ថា ចល័តតំបន់អ្នកស្រីហ្នឹងត្រូវបានគេចាត់តាំងឲ្យទៅធ្វើការនៅការដ្ឋានទំនប់១មករា អ៊ីចឹងតើអ្នកស្រីអាចជម្រាបបានទេថា តើអ្នកណាជាអ្នកចាត់តាំងកងចល័តរបស់អ្នកស្រីហ្នឹងទៅធ្វើការនៅទំនប់១មករា?

**ឆ៖** ខ្ញុំមិនដឹង អត់ដឹងពីណាគេចាត់តាំងឲ្យទៅទេ។ ដល់ពេលប្រធានកង គេថា "ឲ្យរៀបវ៉ាឡីស្អែកនេះត្រូវចេញទៅ ១មករា កំពង់ថ្ម" គេប្រាប់អ៊ីចឹងឯង។

**ស៖** សូមអរគុណអ្នកស្រី។ តើនៅពេលដែលគេចាត់តាំងឲ្យទៅអ៊ីចឹងយើងអាចប្រកែកបានទេ?

**ឆ៖** ប្រកែកអត់បានទេ មិនហ៊ានតថាមិនទៅ អត់មានហ៊ានតទេ។ ត្រូវតែទៅ។

[១៥:៤៧:៥៣]

**ស៖** អ្នកស្រីចាំបានទេថា នៅពេលដែលគេចាត់តាំងឲ្យអ្នកស្រីទៅធ្វើការនៅការដ្ឋានទំនប់ ១ មករា នោះតើនៅក្នុងខែណាដែរ? ឆ្នាំណាដែរ? ឬក៏បើមិនចាំកាលបរិច្ឆេទច្បាស់លាស់ទេ អាចចាំថា វានៅក្នុងរដូវណា? នៅពេលណា?

**ឆ៖** ខ្ញុំដឹងចេញពីក្ដីសែនទៅ ស្រូវនោះវាទុំហើយ ស្ទូងបាន ទុំហើយ តែអត់បានច្រូតទេៗ ចេញទៅ១មករា។ ទៅដល់ធ្វើការ១មករា រហូតដល់ទឹកមក ជីកដីអត់កើតគេឲ្យ ត្រឡប់មកវិញៗ។ ប៉ុន្តែថ្ងៃខែឆ្នាំ ខ្ញុំអត់ចាំ ប៉ុន្តែដឹងតែទឹកឡើងជន់ខ្លាំងជីកដីអត់កើតត្រឡប់មកវិញ។

**ស៖** ចាស សូមអរគុណអ្នកស្រី។ អម្បាញ់មិញ អ្នកស្រីបានបញ្ជាក់ថា អ្នកស្រី -- ក្រុមចល័តរបស់អ្នកស្រីបានទៅដល់កន្លែងសម្រាក គេធ្វើរោងឲ្យសម្រាក។ អ៊ីចឹងតើអ្នកស្រីអាចរៀបរាប់ពីកន្លែងសម្រាកហ្នឹងបានទេ ថានៅកន្លែងសម្រាកហ្នឹងមានរោងគេធ្វើរបៀបម៉េច រួចហើយវាមានរោងសម្រាកហ្នឹងចំនួនប៉ុន្មានអីដែរ? រួចហើយសំខាន់គឺទីតាំងនៃកន្លែងសម្រាកហ្នឹង ពីទីតាំងទៅការដ្ឋានដែលអ្នកស្រីត្រូវធ្វើការហ្នឹង តើវាមានចម្ងាយប៉ុន្មានពីគ្នាដែរ?

**ឆ៖** ពីរោងទៅការដ្ឋាន ទៅកន្លែងលើកទំនប់ ចម្ងាយប្រហែលជា ៥ ទៅ៦០០ ម៉ែត្រ។ ហើយរោងនោះ មានតែរនាបឈើទេ បើខ្លះមានកន្ទេលក៏កន្ទេលទៅ អ្នកអត់ក៏អត់ទៅ មានកន្ទេលកណ្ដាចមួយក្រាលដេកមួយកំណាត់ ដណ្ដប់មួយកំណាត់ទៅ។ ដូចរូបខ្ញុំជាដើម ដណ្ដប់មួយកំណាត់ ក្រាលដេកមួយកំណាត់។ ហើយរោងនោះធំវែង ចំណុះមួយកងធំ១០០នាក់ហ្នឹងឯង។ វែង ទទឹង ប្រហែលជា ៥ម៉ែត្រ

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

ទៅឲ្យវែងទៅ ដេកជើងទល់ជើងគ្នា ប្រឡោះកណ្ដាលគេដើរទៅ ក្បាលទៅខាងរៀងៗខ្លួន ជើងទល់គ្នាមក ប៉ុន្តែប្រឡោះកណ្ដាលនេះ គេដើរ ដាក់សសររោងកូឡោនកណ្ដាលទៅ ដើរតាមប្រឡោះកណ្ដាលហ្នឹងឯង។

[១៥:៥០:៣៥]

**ស៖** ចាស សូមអរគុណអ្នកស្រី។ នៅពេលដែលអ្នកស្រីទៅដល់ រោងសម្រាកហ្នឹងគេសង់ស្រេចហើយ គេមានស្រេច ឬក៏ទើបតែសាងសង់ទេ? ហើយតើដំបូលរោងហ្នឹងប្រក់ពីអីដែរ? ហើយនៅពេលដែលមានភ្លៀងមក តើវាសាចទឹកចូលទេ?

**ឆ៖** ប្រក់ស្លឹក ប៉ុន្តែអត់មានជញ្ជាំងបាំងទេ។ ដល់ពេលដេកទៅ បើមានភ្លៀងត្រូវទទឹកខាងក្បាលដំណេក វាជ្រាបចូលតាមក្បាលដំណេក អត់មានអីបាំងទេ។

**ស៖** នៅពេលដែលអ្នកស្រី ហើយក្រុមកងចល័តទាំងមូលហ្នឹងសម្រាក តើគេមានផ្ដល់មុងឲ្យទេ?

**ឆ៖** មុងក៏គ្មាន ភួយក៏គ្មាន គ្មានអីទាំងអស់ មានតែក្រមា មានក្រមា។ ក្រមាចាស់ទៀត គ្មានក្រមាថ្មីឲ្យធំក្រាស់ទេ ក្រមាតូចៗ។

**ស៖** អំមិញ អ្នកស្រីបានមានប្រសាសន៍ថា កន្លែងហ្នឹងជាព្រៃ អ៊ីចឹងហើយពេលដែលឡានទៅដល់ គឺអត់អាចឡានចូលបានទេ បានជាត្រូវធ្វើដំណើរថ្មើរជើងទៅ។ អ៊ីចឹង បើអត់មានមុងអ៊ីចឹង តើគេងនៅពេលយប់ឡើងមានមូសច្រើនទេ? រួចហើយមានសត្វល្អិតអីមករំខាននៅពេលដែលគេងទេ?

**ឆ៖** មាន មានមូស។ ប៉ុន្តែដុតភ្លើង គេឲ្យដុតភ្លើងពីលើខ្យល់ទៅ ឲ្យផ្សែងវាហុយៗទៅ។ មុងគ្មានទេ បើមូសមាន ខាំ។ ដុតភ្លើងទៅ វាអាចប៉ើងដែរ មូស។

**ស៖** ចាស សូមអរគុណអ្នកស្រី។ អ៊ីចឹង ដល់ពេលដែលអ្នកស្រីទៅធ្វើការនៅការដ្ឋាន ខ្ញុំចង់សួរថា អ្នកស្រីធ្វើការនៅទីនោះតែមួយកន្លែងហ្នឹងទេ ឬក៏អ្នកស្រី ក្រុមអ្នកស្រីហ្នឹងបានផ្លាស់ប្ដូរទៅធ្វើម្ដងការដ្ឋាននេះ ម្ដងការដ្ឋាននោះដែរ ឬក៏ធ្វើតែមួយកន្លែងទេ?

**ឆ៖** ធ្វើវាមួយកន្លែង នៅនេះឯង អត់មានផ្លាស់ទៅណាទេ ប៉ុន្តែដល់រួចទៅ ចេះតែរំកិលទៅមុខឆ្ងាយពីរោង ឆ្ងាយទៅៗ។ អត់មានដែលដកទៅណាទេ។

[១៥:៥៣:៥០]

**ស៖** ចាស សូមអរគុណអ្នកស្រី។ អ៊ីចឹងមួយរយៈពេលដែលអ្នកស្រីធ្វើការនៅការដ្ឋានទំនប់១មករាហ្នឹង អ្នកស្រីថាគេឲ្យធ្វើពីការដ្ឋានមួយលើកទំនប់ រួចហើយក៏កាន់តែដេញទៅឆ្ងាយទៅៗ អ៊ីចឹង

មួយរយៈពេលដែលអ្នកស្រីនៅការដ្ឋានទំនប់១មករា រហូតដល់ពេលដែលភ្លៀងធំ ដែលថាលើកដី រែកដីអត់កើត ហើយគេបញ្ជូនទៅភូមិវិញហ្នឹង អ៊ីចឹង តើរហូតមកដល់ពេលហ្នឹងលទ្ធផលការងារនៃការលើកទំនប់ហ្នឹង តើបានប្រវែងប៉ុន្មានដែរ ដែលក្រុមអ្នកស្រី មួយកងធំហ្នឹងបានធ្វើ តើបានប្រវែងប៉ុន្មានដែរ?

**ឆ៖** មួយកងធំ ចាប់ធ្វើចម្ងាយពីរោងទៅ ប្រហែលជា១គីឡូដីជាង ប៉ុន្តែអត់ទាន់រួច។ ដល់ពេលអត់រួច គេឲ្យមក ដល់ពេលទឹកឡើងធ្វើអត់កើត គេឲ្យឡើងមកកន្លែងភ្លសែនវិញ។ កងខ្ញុំ គេដកឲ្យទៅនៅបល្ល័ង្ក ទៅភ្ជួររាស់នៅបល្ល័ង្កជាមួយបុរស។

**ស៖** ចាស សូមអរគុណអ្នកស្រី។ អ៊ីចឹង ត្រឡប់មកការងារនៅការដ្ឋានទំនប់១មករាវិញ។ តើអ្នកស្រីអាចជម្រាបជូនតុលាការបានទេថា នៅការដ្ឋាននោះគេតម្រូវឲ្យអ្នកស្រីធ្វើអ្វីខ្លះ? ហើយគេបែងចែកការងារគ្នារបៀបម៉េច? ហើយអ្នកណាជាអ្នកបែងចែកឲ្យ?

**ឆ៖** គេបែងចែកដី ប្រធានកងធំចែកមកប្រធានកងតូច ប្រធានកងតូចមក ចែកនៅតាមក្រុមមក ចែកម៉ែត្រ ចែកជាម៉ែត្រគូបទៅ។ ក្នុងម្នាក់ ៤ម៉ែត្រគូប។ ដល់ហើយចូលគ្នាពីរនាក់ទៅ កាប់ម្នាក់ម្ដងៗ។ ឈឺដៃទៅ ឯងកាប់ម្ដង គេរែកម្ដង, គេរែកម្ដង ឯងកាប់ម្ដង។ ក្នុងម្នាក់ដឹង៤ម៉ែត្រគូប។ បើធ្វើមិនរួចទេ គេបង្អត់អាហារយើងហើយ គេមិនឲ្យយើងហូបទេ។ ម្ល៉ោះហើយ ចេះតែប្រឹង ខំ ទឹកច្រើន កក្នុងយ៉ាងណា ក៏នៅតែ -- រអិលកាំជណ្ដើរ គេឲ្យធ្វើជណ្ដើរឡើង ធ្វើជណ្ដើរកាប់ឲ្យរាងទេរទៅ កាប់កូនឈើដាក់ឲ្យក្រាលជណ្ដើរ វាយបង្គោលក្រាលជណ្ដើរ។ ឡើងមិនចង់រួចទេ រហូតម្នាក់ឈរនៅលើមាត់ច្រាំង ម្នាក់នៅក្រោម ហុចបង្គីទៅ យើងចាប់ខ្សែបង្គីលើកឡើងលើ។

[១៥:៥៦:៤៦]

**ស៖** អ្នកស្រីអាចបញ្ជាក់បានទេថា នៅពេលដែលគេឲ្យអ្នកស្រីកាប់ដីហ្នឹង ថាតើទីតាំងដែលកាប់ហ្នឹង ជាដី ឬក៏អាចមានថ្មដែរ ឬក៏យ៉ាងណា? តើជាដីសុទ្ធ ឬក៏ជាដីថ្ម?

**ឆ៖** គ្មានថ្មទេ ដីសុទ្ធ។

**ស៖** សូមអរគុណអ្នកស្រី។ ទាក់ទងជាមួយនឹងម៉ោង ពេលវេលានៃការធ្វើការងារ ខ្ញុំចង់សួរអ្នកស្រីថា តើអ្នកស្រីអាចជម្រាបបានទេ ពីពេលវេលានៃការធ្វើការងារ ថាតើពេលណាគេផ្លុំកញ្ចែហៅឲ្យកងអ្នកស្រីក្រោកឡើង? ហើយពេលណាជាពេលវេលាដែលត្រូវចាប់ផ្ដើមធ្វើការងារ? សម្រាកនៅពេលណា? ហើយធ្វើ -- ពេលយប់មានធ្វើការដែរឬទេ?

**ឆ៖** ម៉ោងប្រាំព្រឹក ម៉ោងបួនកន្លះស្មានទេមើលទៅ មិនមាន -- គ្មានម៉ោងមើលទេ ជំនាន់នោះ

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

ប៉ុន្តែថា មាន់រងាវ ភ្ញាក់ផ្អើលក៏ញ្ញ៉េ គេគោះដែប៉ុកៗ ក្រោក។ ទម្រាំរកម្ជុក រកកន្សែង រកខោ រកអាវទៅ លុបមុខ លុបអីទៅ ភ្លឺព្រាងៗគេឲ្យចេញដើរទៅ ផ្ទុកញ្ញ៉េច្រេចទៅ គេឲ្យក្រោកទៅតម្រង់ជួរ។ តម្រង់ជួរហើយ រាប់មនុស្សរួចចេញដំណើរទៅកន្លែងទំនប់។ ទៅដល់ទំនប់ ម៉ោងដប់មួយបានឲ្យឈប់ហូបបបរ។ ហូបបបរហើយ ត្រឡប់ទៅវិញទៅ ព្រោះកងខ្ញុំហូបក្រោយគេ។ ទៅៗបើថាដើរទៅទំនប់ទៅ បើបានប្រធានកងគេមិនទាន់ទៅទេ យើងអង្គុយបានបន្តិច។ បើថាមិននេះ គ្មានទេ គ្មានបានអង្គុយ ហូបបបររួចគឺវឹងទៅវិញ។ ដល់ម៉ោងប្រាំកន្លះល្ងាច ឲ្យឈប់ មកងូតទឹក ងូតអី ហូបបបរ។

[១៥:៥៨:៥៤]

បើគេមានផែនការប្រជុំ គេប្រជុំជីវភាពមួយបន្តិចហ្នឹងឯងទៅ យប់ឡើងមកវាស់ដីឲ្យ២ម៉ែត្រគូបទៀត ជីកយប់។ ផែនការគេក្តៅគគុកហើយ។ ជីកយប់ហ្នឹងឯង បើសិនជាជីកយប់ហ្នឹងឯង ក្នុងម្នាក់២ម៉ែត្រហ្នឹងឯង ៤ម៉ែត្រ បើមិនរួចទេ បន្សល់ទុកព្រឹក គឺព្រលឹមឡើងដឹងខ្លួនថាទាំងពីរនាក់នេះ ត្រូវងើបពីយប់ខ្លួនឯងទៅបង្ហើយអាចម៍ដីហ្នឹងឯង ដើម្បីឲ្យគេឃើញថាយើងធ្វើអស់ហើយ ព្រឹកឡើងគេវាស់ថ្មីឲ្យ។ បើសិនជាមិនអស់អាចម៍ដីដែលរែក ៤ម៉ែត្រគូប ពីរនាក់ហ្នឹងឯង – ម្នាក់ ២ម៉ែត្រគូបហ្នឹងឯង បើមិនអស់ គេយកយើងទៅកសាងអប់រំហើយ កសាង ណែនាំ ទៅប្រជុំហើយ។ ទាល់ងើបពីម៉ោងបួន ម៉ោងអី មាន់រងាវល្វើយៗ ពីរបីដងទៅ នាំគ្នាដាស់គ្នាទៅៗ។

**ស៖** សូមអរគុណអ្នកស្រី។ អម្បាញ់មិញអ្នកស្រីថា ប្រហែលជាម៉ោងបួនកន្លះមាន់រងាវ គេផ្ទុំកញ្ញ៉េ គេឲ្យតម្រង់ជួរ ហើយគេឲ្យចេញដំណើរទៅ។ អ៊ីចឹងនៅពេលដែលអ្នកស្រីទៅដល់ទីតាំងការដ្ឋានដែលត្រូវធ្វើការងារហ្នឹង ថាតើអ្នកស្រីទៅដល់ហ្នឹងត្រូវធ្វើការភ្លាម ឬក៏គេមានពេលវេលាដែលគេ -- ពេលវេលាកំណត់ដាក់លាក់ដើម្បីឲ្យចាប់ផ្តើមធ្វើការងារ ឬក៏ត្រូវទៅដល់ភ្លាម ហើយត្រូវទៅធ្វើការងារភ្លាម?

**ឆ៖** ទៅដល់ភ្លាម បើសិនជានៅងងឹតអង្គុយចាំបន្តិច ព្រាងៗឡើងជីកទៅ បានធ្វើការចាប់ផ្តើម។

**ស៖** សូមអរគុណអ្នកស្រី។

**លោកស្រី ម៉ុច សុវណ្ណារី៖**

លោកប្រធានខ្ញុំសង្កេតឃើញថា ពេលវេលាសម្រាកដល់ហើយ។ ដូច្នេះខ្ញុំសូមលោកប្រធានសម្រេច ថាតើបន្ត ឬក៏សម្រាក? សូមអរគុណ។

[១៦:០០:៥៩]

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ បាទ សវនាការនៅថ្ងៃនេះដល់ពេលឈប់សម្រាកហើយ អង្គជំនុំជម្រះប្រកាសផ្អាកកិច្ចដំណើរការសវនាការសម្រាប់ថ្ងៃនេះត្រឹមនេះ សវនាការលើកទៅបន្តធ្វើនៅថ្ងៃស្អែក ថ្ងៃព្រហស្បតិ៍ ទី២៨ ខែឧសភា ឆ្នាំ២០១៥ ចាប់ផ្តើមពីម៉ោងប្រាំបួនព្រឹកទៅ។ ហើយសវនាការនៅថ្ងៃស្អែកនេះ អង្គជំនុំជម្រះនឹងធ្វើសវនាការបន្តស្តាប់សក្ខីកម្មសាក្សី -- ដើមបណ្តឹងរដ្ឋប្បវេណី អ៊ុង រ៉ន សូមភាគីជ្រាប និងអញ្ជើញចូលរួមតាមពេលវេលាបានកំណត់នេះ។

អង្គជំនុំជម្រះអរគុណលោកស្រី អ៊ុង រ៉ន ដំណើរការស្តាប់សក្ខីកម្មលោកស្រីក្នុងឋានៈជាដើមបណ្តឹងរដ្ឋប្បវេណីនៅមិនទាន់ចប់នៅឡើយទេ អង្គជំនុំជម្រះកោះអញ្ជើញលោកស្រីឲ្យមកបន្តផ្តល់សក្ខីកម្មនៅថ្ងៃស្អែកទៀត ដែលនឹងចាប់ផ្តើមពីម៉ោងប្រាំបួនព្រឹកទៅ។

មន្ត្រីរដ្ឋបាលតុលាការសម្របសម្រួលជាមួយនឹងបុគ្គលិកនៃអង្គភាពគាំពារសាក្សី និងអ្នកជំនាញក្នុងការជូនលោកស្រី អ៊ុង រ៉ន វិលត្រឡប់ទៅកន្លែងដែលគាត់ស្នាក់នៅវិញចុះ និងសូមឲ្យអញ្ជើញគាត់មកចូលរួមផ្តល់សក្ខីកម្មនៅក្នុងបន្ទប់សវនាការនេះវិញ នៅថ្ងៃស្អែកឲ្យបានមុនម៉ោងប្រាំបួនព្រឹក។ ហើយអង្គជំនុំជម្រះក៏សូមអរគុណផងដែរ លោកស្រី ឆាយ ម៉ារីដែន បុគ្គលិកអង្គការ ធី.ភី.អូ អង្គជំនុំជម្រះអញ្ជើញលោកស្រីមកបន្តចូលរួមអង្គុយអមជាជំនួសស្មារតីដល់ដើមបណ្តឹងរដ្ឋប្បវេណីនេះ ក្នុងអំឡុងពេល សវនាការនៅថ្ងៃស្អែកទៀត ដែលនឹងចាប់ផ្តើមពីម៉ោងប្រាំបួកព្រឹកទៅ។

បង្គាប់ឲ្យអនុរក្សមន្ទីរឃុំឃាំងនាំខ្លួនជនជាប់ចោទទាំងពីររូប នួន ជា និង ខៀវ សំផន ត្រឡប់ទៅកាន់មន្ទីរឃុំឃាំងនៃ អ.វ.ត.ក វិញចុះ និងបង្គាប់ឲ្យនាំខ្លួនពួកគាត់ទាំងពីររូបត្រឡប់មកចូលរួមសវនាការនៅថ្ងៃស្អែកវិញឲ្យបានមុនម៉ោងប្រាំបួនព្រឹក។

សម្រាកចុះ៕

*(សវនាការផ្អាកនៅម៉ោង ១៦:០២ នាទី)*

*ប្រតិចារិកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារិកក្នុងភាសាទាំងបី។ ប្រតិចារិកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារិកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*